ទស្សនាវដ្តី

ប្រជាជន

THE PRACHEACHUN MAGAZINE

ឆ្នាំទី២០ លេខ ២៣១ ខែសីហា ឆ្នាំ ២០២០

និពន្ធនាយក :

លោក តាក សុនអ៊ុ

គណៈកម្មការនិពន្ធ

១. លោក ខ្សៀវ ណាវី

២. លោក អ៊ឹម សុន្ធរៈ

៣. លោក វង្ស សាវុធ

៤. លោក ទាវ សារៈមុនី

៥. លោក សុខ សុធន

លេខានិពន្ធ

១. លោក ម៉ក់ ឈិន

២. លោក ស្វាយ ភីរុណ

អ្នកបកប្រែភាសា

១. លោកស្រី ម៉ែន នារីសោភ័គ

អ្នកថតរូប

១. លោក សុផាត វីរៈមុនី

វិចិត្រករ

១. លោក ធា សាវុធ

អាស័យដ្ឋាន :

លេខ ២០៣

មហាវិថី ព្រះនរោត្តម

ភ្នំពេញ-កម្ពុជា

ទូរស័ព្ទលេខ :

០២៣ ២១៩ ០៦៥

Address :

No 203 Preah

Norodom Bld.

Phnom Penh Cambodia

Tel : 023 219 065

លទ្ធផលនៃដំណើរទស្សនកិច្ចផ្លូវការ ឯកឧត្តម ***ម៉ូតេហ្គិ តូស៊ីមីសឺ*** *រដ្ឋមន្ត្រីការបរទេសជប៉ុន.....*

៥

សម្តេចតេជោ *៖ យើងត្រូវម្ចាស់ការលើការងារជាអាទិភាពចម្បង២ គឺរក្សាស្ថិរភាពនយោបាយ....*

៦

សម្តេចអគ្គមហាពញាចក្រី *ជំរុញមន្ត្រី និងអាជ្ញាធរមូលដ្ឋាន បង្កលក្ខណសម្បត្តិ....*

៩

សម្តេចក្រឡាហោម *៖ ស្ថិរភាពជាតិអាចសម្រេចទៅបានអាស្រ័យសង្គមជាតិមានភាពយុត្តិធម៌...*

១០

សម្តេចវិបុលសេនាភក្តី *ក្រើនរំលឹកមន្ត្រីអនុវត្តឲ្យបានល្អតួនាទីភារកិច្ចរបស់ខ្លួន.....*

១១

ក្របមុខ

ប្រជាជនចូលរួមដើរលេងនៅប្រាសាទអង្គរវត្ត

មាតិកា
Contents

វិចារណកថា : កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន មានលក្ខណៈជាប្រវត្តិសាស្ត្រ..... ០១

Editorial : The Cambodia-China Free Trade Agreement ០១

អត្ថបទនយោបាយ : មិនអាចអត់ឱនឲ្យបានជនណា មួលបង្កាច់, ញុះញង់ អំពីបញ្ហាព្រំដែន ០៤

➪ *សកម្មភាពសមាជិក រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ១២*

➪ *សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស ១៦*

➪ *សមិទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច ១៨*

➪ *វិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍តឹតតែសំខាន់ ១៩*

➪ *កំពង់ផែទឹកជ្រៅលំដាប់អន្តរជាតិ ក្រុងព្រះសីហនុកំពុងត្រូវអភិវឌ្ឍឲ្យក្លាយជាកំពង់ផែ..... ២១*

➪ *ប្រកាន់ខ្ជាប់យុត្តិធម៌ ភាពម៉ឺងម៉ាត់ និងសុចរិតភាព ក្នុងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌..... ២២*

➪ *វប្បធម៌: ការទម្លាក់គ្រាប់បែកបរមាណូអាមេរិក លើទីក្រុងហ៊ីរ៉ូស៊ីម៉ា និង ២៤*

➪ *ចំណេះដឹងទូទៅ: ការទម្លាក់គ្រាប់បែកបរមាណូអាមេរិក លើទីក្រុងហ៊ីរ៉ូស៊ីម៉ា និង ២៥*

➪ *វិទ្យាសាស្ត្រ និងសុខភាព: ទឹកឃ្មុំមានប្រយោជន៍ចំពោះស្ត្រីមានផ្ទៃពោះតែវាក៏ផ្តល់..... ២៦*

➪ *ទឹកដី មាតុភូមិ: វឌ្ឍនភាពនៃស្រុកអូររាំងឪ.... សូមអរគុណសន្តិភាព!!..... ២៧*

➪ *កំណាព្យ: ភ្នំបិណ្ឌ..... .....សំណើច..... ៣០*

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន មានលក្ខណៈជាប្រវត្តិសាស្ត្រសម្រាប់កម្ពុជា

The Cambodia-China Free Trade Agreement – Historic for Cambodia

*កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន គឺជាផ្លែផ្កាថ្មីមួយទៀតនៃទំនាក់ទំនង ទ្វេភាគីរវាងប្រទេសទាំងពីរ ចាប់តាំងពីការចុះហត្ថលេខាលើផែនការសកម្មភាពដើម្បីបង្កើតសហគមន៍វាសនារួមកម្ពុជា-ចិនកាលពីខែមេសាឆ្នាំ២០១៩កន្លងទៅនេះ។ជាការពិតទំនាក់ទំនងរវាងប្រទេសទាំងពីរកម្ពុជា-ចិន ពិតជាបានផ្តល់នូវអត្ថប្រយោជន៍ជាច្រើនឲ្យគ្នាទៅវិញទៅមក ។ជាមួយគ្នានេះ ការបង្កើនកិច្ចសហប្រតិបត្តិការនៃប្រទេសទាំងពីរបានរួមចំណែកដល់ការអភិវឌ្ឍប្រទេសកម្ពុជាឲ្យកាន់តែរឹងមាំទ្វេឡើងថែមទៀត ។ គួរបញ្ជាក់ថា នៅក្នុងដំណើរទស្សនកិច្ចរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានៅសាធារណរដ្ឋប្រជាមានិត ចិន ក្នុងអំឡុងពីថ្ងៃទី ២០-២៣ ខែមករា ឆ្នាំ២០១៩ មានកិច្ចព្រមព្រៀងសំខាន់ៗមួយចំនួនត្រូវបានចុះហត្ថលេខា ។ នៅក្នុងឱកាសនោះ **សម្តេចតេជោ ហ៊ុន សែន** បានស្នើដល់ឯកឧត្តមប្រធានាធិបតីចិន **ស៊ី ជីនពីង** ដើម្បីធ្វើយ៉ាងណាជំរុញបង្កើតនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដោយសារប្រទេសទាំងពីរមានភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយរួចមកហើយតាំងពីឆ្នាំ២០១០ ។*

លើមូលដ្ឋាននេះ ក្រុមការងារកម្ពុជា-ចិន បានចរចាជាផ្លូវការចំនួនបីជុំ និងចរចាតាមក្រុមតូចៗជាច្រើនលើក ហើយបានប្រកាសបញ្ចប់ការចរចាជាផ្លូវការ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគីកម្ពុជា-ចិន ដោយរដ្ឋមន្ត្រីពាណិជ្ជកម្មកម្ពុជា និងចិន នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២០ ។ កិច្ចការនេះ គ្របដណ្តប់លើជំពូក និងវិស័យដែលបម្រើឲ្យផលប្រយោជន៍នៃប្រទេសទាំងពីររួមមាន៖ ការបើកច្រកទីផ្សារផ្នែកពាណិជ្ជកម្មទំនិញ, ការកំណត់លក្ខខណ្ឌលើពាណិជ្ជកម្មសេវាកម្ម, កិច្ចសហប្រតិបត្តិការ និងជំរុញវិនិយោគ, ការកំណត់វិធានប្រភពដើមទំនិញ, នីតិវិធីគយ និងកិច្ចសម្រួលពាណិជ្ជកម្ម, វិធានការនានាទាក់ទងនឹងអនាម័យ និងភូតគាមអនាម័យ, របាំងបច្ចេកទេសលើការធ្វើពាណិជ្ជកម្ម, សហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស និងគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវ,ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងផ្នែកវិនិច្ឆ័យ និងនីតិកម្ម ។ លើវិស័យពាណិជ្ជកម្ម កម្ពុជាទទួលបានទីផ្សារចិនសម្រាប់ទំនិញពីកម្ពុជាប្រមាណជា ៩៨% នៃមុខទំនិញសរុប បើធៀបជាមួយសម្បទានទទួលបានក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ដែលមានត្រឹមតែ ៩៤% ប៉ុណ្ណោះ ។កិច្ចព្រមព្រៀងនេះ បានបើកផ្លូវចរចាបន្តទៀតក្នុងការបើក

The Free Trade Agreement between Cambodia and China is a new fruit of bilateral relation since their signings in April 2019 of action plan to set up Cambodia-China Common Destiny Community. It is true that relations between the two countries – Cambodia and China, has scored numerous advantages for each other. At the same time, increasing cooperation between the two countries contributed further to Cambodia's development. It is worth mentioning that in the course of Samdech Akka Moha Sena Padei Techo Hun Sen's visit to the People's Republic of China between 20 and 23 January 2019, a number of important agreements had been signed. Samdech Techo Hun Sen on that occasion proposed to President Xi Jinping of China to strive for a realization of a Free Trade Agreement as the two countries have been strategic comprehensive partners since 2010.

On this foundation, the Cambodia-China working groups on the Cambodia-China Free Trade Agreement (CCFTA) conducted three rounds of negotiations and numerous other times in smaller groups, through which the Ministers of Trades of Cambodia and China wrapped up final agreement on 20 July 2020. Chapters and fields served the two countries' interests include – opening of trade markets for goods, setting conditions on trade in services, cooperation and investment promotion, setting rules of origin, customs procedures and trade facilitation, measures related to sanitation and phytosanitary, trade barriers, economic and technical cooperation and belt and road initiatives, e-commerce and litigation and Legislation.

In term of trade, Cambodia has access to the Chinese market for about 98% of the total goods from Cambodia compared to the concessions received under the ASEAN-China Free Trade Agreement, which is only 94%. The agreement paves the way for further negotiations to open more

ច្រកទីផ្សារបន្ថែមទៀតលើមុខទំនិញសំខាន់ៗ ដែលមិនទាន់បានសម្រួលលក្ខខណ្ឌទីផ្សារបានល្អប្រសើរនៅឡើយ ។ កម្ពុជាក៏បានផ្តល់ការបើកច្រកទីផ្សារឲ្យភាគីចិន ៩០% នៃបន្ទាត់ពន្ធគយសរុប ប៉ុណ្ណោះ គឺប្រហាក់ប្រហែលនឹងកម្រិតនៃការបើកច្រកទីផ្សារក្រោមក្របខណ្ឌនៃកិច្ចព្រមព្រៀងអាស៊ាន-ចិន ។ ភាគីចិនបានផ្តល់នូវកញ្ចប់សន្យាតាមវិស័យសេវាកម្ម ដោយបានធ្វើឲ្យល្អប្រសើរជាងមុននូវលក្ខខណ្ឌមួយចំនួនក្នុងផ្នែកច្រកចូលទីផ្សារ និងប្រព្រឹត្តិកម្ម-ជាតិ លើវិស័យសេវាកម្មមួយចំនួនដូចជា សេវាកម្មធានារ៉ាប់រង សេវាកម្មធនាគារ សេវាកម្មវេជ្ជសាស្ត្រ និងទន្តពេទ្យ សេវាកម្មស្រាវជ្រាវទីផ្សារ សេវាកម្មពិគ្រោះយោបល់ផ្នែកគ្រប់គ្រងសេវាកម្មពាក់ព័ន្ធនឹងរុក្ខសាស្ត្រ សេវាកម្មផ្គត់ផ្គង់បុគ្គលិក សេវាកម្មថតរូប សេវាកម្មទូរគមនាគមន៍ សេវាកម្មសោតទស្សន៍ សេវាកម្មអប់រំ សេវាកម្មបរិស្ថាន សេវាកម្មសណ្ឋាគារ និងភោជនីយដ្ឋាន សេវាដឹកជញ្ជូនតាមផ្លូវសមុទ្រ និងសេវាកម្មលើកដាក់ទំនិញ ។ភាគីកម្ពុជាបានផ្តល់នូវការបើកច្រកទីផ្សារ ដូចកម្រិតដែលបានសន្យាក្រោមក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោកនិងកិច្ចព្រមព្រៀងពាណិជ្ជ-កម្មសេរីអាស៊ាន-ចិន ។ក្នុងនោះ ក៏បានធ្វើការកែលម្អលើអនុវិស័យសេវាកម្មដែលបម្រើដល់ផលប្រយោជន៍ក្នុងវិស័យអប់រំនិងដឹកជញ្ជូនទំនិញតាមសមុទ្រផងដែរ ។

កិច្ចព្រមព្រៀងនេះ បានផ្តល់សារៈប្រយោជន៍យ៉ាងសំខាន់សម្រាប់កម្ពុជា ក្នុងការពង្រីកការធ្វើពាណិជ្ជកម្ម ជំរុញការវិនិយោគ និងការងារការបណ្តុះបណ្តាល និងបច្ចេកវិទ្យា ។ ជាក់ស្តែងផលប្រយោជន៍ដែលកម្ពុជាទទួលបានជាច្រើនដូចជា៖ ការបើកច្រកទីផ្សាបានធំជាងសម្រាប់មុខទំនិញកសិផល បន្លែផ្លែឈើ ផលិតផលកែច្នៃ និងសិប្បកម្ម និងផលិតផលជាច្រើនទៀត ក្នុងករណីដែលកម្ពុជាផលិតបាន និងមានអនាម័យ ព្រមទាំង ស្តង់ដារត្រឹមត្រូវ, មានលំហទីផ្សារផ្នែកសេវាកម្ម ដែលអាចនាំចេញក្នុងករណីមានការបណ្តុះបណ្តាលជំនាញត្រឹមត្រូវ, រាល់នីតិវិធីទាក់ទងនឹងវិធានដើមកំណើតទំនិញគយ និងសម្រួលពាណិជ្ជកម្មអនាម័យ និងភូតគាមអនាម័យ និងរបាំងបច្ចេកទេសលើការធ្វើពាណិជ្ជកម្មត្រូវបានកំណត់ច្បាស់លាស់ និងធ្វើសាមញ្ញនីយកម្ម ដើម្បីងាយស្រួលអនុវត្ត និងសម្រួលដល់ការធ្វើពាណិជ្ជកម្ម, បរិយាកាសវិនិយោគ និងនយោបាយទាក់ទាញវិនិយោគទុនពីបរទេសត្រូវបានរៀបចំ និងបង្កើតឡើង, កិច្ចសហ-ប្រតិបត្តិការផ្នែកសេដ្ឋកិច្ច និងបច្ចេកទេស តាមវិស័យនានាត្រូវបានកំណត់ ដើម្បីជួយដល់កម្ពុជា ក្នុងការកសាងធនធានមនុស្ស ពង្រឹងសមត្ថភាពស្ថាប័ន កសាងសមត្ថភាពផលិត និងផ្គត់ផ្គង់របស់វិស័យឯកជន, ហេដ្ឋារចនា សម្ព័ន្ធផ្នែកទន់ និងរឹងសម្រាប់ជួយដល់វិស័យពាណិជ្ជកម្ម និងត្រូវបានកសាង និងរៀបចំជាបណ្តើរៗ ។

សមិទ្ធផលនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កម្ពុជា-ចិន ដែល

markets for key commodities that have not yet improved market conditions. Cambodia also provided market access to the Chinese side with only 90% of the total tariff line, which is similar to the level of market access marked under the framework of the ASEAN-China Agreement.

The Chinese side has provided promising services sector packages by improving some of the conditions concerning market access and national treatment of services such as insurance, banking, medical and dental, market research, management consulting services related to botanical, staffing, photography, telecommunication, audio-visual, education, environmental, hotel and restaurant, sea freight services and freight forwarding. The Cambodian side has provided market access as promised under the framework of the World Trade Organization and the ASEAN-China Free Trade Agreement, which also improved the service sub-sector, which serves the interests of education and maritime transport.

This agreement has provided significant benefits for Cambodia in term of expanding trade, promoting investment and employment, and training and technology. Obviously, Cambodia has secured many benefits, such as opening a bigger market for agricultural products, vegetables, fruits, processed and handicraft products, and many other products in case Cambodia produces and ensures hygienic, as well as the right standards, there is a market space for services that can be exported in case of proper skills training.

All procedures related to the rules of origin, customs and trade facilitation, sanitation and hygiene, and technical barriers to trade have been clearly defined and simplified to facilitate the implementation and facilitation of trade, investment climate and policy of attracting foreign investment have been developed and established. Sectoral economic and technical cooperation has been identified to assist Cambodia in building human resources, institutional capacity strengthening, capacity building for private sector production and supply, software and hardware infrastructure to support trade have been developed and organized gradually.

The achievements of the Cambodia-China Free Trade Agreement also reflect absolutely the friendly

សម្រេចបាននេះក៏បានឆ្លុះបញ្ចាំងឲ្យឃើញយ៉ាងប្រត្យក្សនូវទំនាក់-ទំនងមិត្តភាពកិច្ចសហប្រតិបត្តិការ ប្រពៃណី ប្រវត្តិសាស្ត្រ និងយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ឈរលើគោលការណ៍ជឿជាក់លើគ្នាយោគយល់គ្នា ផ្តល់ផលប្រយោជន៍ឲ្យគ្នា ឈរលើមូលដ្ឋានឈ្នះ-ឈ្នះ។ រហូតមកដល់បច្ចុប្បន្ននេះ កម្ពុជា និងចិន ទទួលបានសមិទ្ធ-ផលជាច្រើនយ៉ាងច្រើន ហើយប្រទេសចិន គឺជាដៃគូពាណិជ្ជកម្ម ធំទី១ និងជាប្រភពទុនបរទេសធំបំផុតរបស់កម្ពុជា។ ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៧ ចិនបានដាក់ទុនវិនិយោគនៅកម្ពុជា គិតជាទឹកប្រាក់ប្រមាណ ៥៣០០លានដុល្លារ។ នៅឆ្នាំ២០១៨ទំហំពាណិជ្ជកម្ម សរុបនៅកម្ពុជា-ចិន បានកើនឡើងដល់ ៦.៤៥៧លានដុល្លារ ដោយការនាំចេញពីប្រទេសកម្ពុជាទៅចិន មានទំហំទឹកប្រាក់ ៨៧៤ លានដុល្លារ កើនឡើង ១៥% ធៀបឆ្នាំ២០១៧ ចំណែកការនាំចេញពីចិនមកកម្ពុជាទទួលមានទឹកប្រាក់ចំនួន ៥.៥៣៨លានដុល្លារ កើនឡើង ១៦% ធៀបនឹងឆ្នាំ២០១៧។ ដោយឡែក ទំហំពាណិជ្ជ-កម្មទ្វេភាគីរវាងកម្ពុជា និងចិនកាលពីឆ្នាំ២០១៩ មានជាង ៨.០០០ លានដុល្លារអាមេរិក ។ ក្នុងនោះកម្ពុជានាំចេញទៅចិនបានជាង ១.០០០លានដុល្លារ ហើយចិននាំចូលមកកម្ពុជាមានជាង ៧ពាន់ លានដុល្លារ ។ កម្ពុជា-ចិន រំពឹងសម្រេចទំហំពាណិជ្ជកម្មកើនដល់ ១០ពាន់លានដុល្លារ នៅឆ្នាំ២០២៣ ក្រោយពេលចុះកិច្ចព្រមព្រៀង ពាណិជ្ជកម្មសេរីនៅឆ្នាំនេះ ។

និយាយជារួម ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម សេរីកម្ពុជា-ចិន មានអត្ថន័យ ២យ៉ាង ទាំងសេដ្ឋកិច្ច និងនយោបាយ។ ក្នុងន័យសេដ្ឋកិច្ច កិច្ចព្រមព្រៀងនេះនឹងជួយឲ្យសេដ្ឋកិច្ចកម្ពុជា កាន់តែអភិវឌ្ឍ និងរីកចម្រើន ។ ចំពោះន័យនយោបាយវិញ វាជាសារមួយបញ្ជាក់ទៅកាន់បណ្តាប្រទេសនានាថា កម្ពុជាមានច្រកសេដ្ឋកិច្ចពិសេសមួយថែមទៀត ហើយនឹងបន្តបើកច្រកសេដ្ឋកិច្ចសំខាន់ៗ ជាច្រើនទៀតទៅកាន់ទីផ្សារពិភពលោក ។ កិច្ចព្រមព្រៀងនេះ បានផ្តល់ផលប្រយោជន៍សេដ្ឋកិច្ច និងសង្គមជាច្រើនដល់ប្រជាជននៃប្រទេសទាំងពីរ តាមរយៈការធ្វើសេរីភាវូបនីយកម្ម ពាណិជ្ជកម្ម ទំនិញ និងសេវា ការជំរុញការវិនិយោគទូលំទូលាយក៏ដូចជាកិច្ច-សហប្រតិបត្តិការលើវិស័យមួយចំនួនទៀត ។ កិច្ចព្រមព្រៀងនេះក៏បានឆ្លុះបញ្ចាំងអំពីទំនាក់ទំនងយូរអង្វែងជាប្រពៃណី ក៏ដូចជាកិច្ចសហប្រតិបត្តិការ ក្នុងភាពជាដៃគូគ្រប់ជ្រុងជ្រោយរវាងប្រទេសទាំងពីរ ៕

ទស្សនាវដ្តីប្រជាជន

relations, cooperation, tradition, history and comprehensive strategy based on the principles of trust, mutual understanding, mutual benefit and win-win foundation. To date, Cambodia and China have achieved numerous fruitful achievements, and China is Cambodia's first major trading partner and largest source of foreign capital.

From 2013 to 2017, China invested about 5.3 billion USD in Cambodia. In 2018, the total Cambodia-China trade volume will reach 6.457 million US dollars, with exports from Cambodia to China amounting to 874 million US dollars, an increase of 15% compared to 2017, while exports from China to Cambodia recorded at 5.538 million USD, an increase of 16% compared to 2017.

In particular, the bilateral trade volume between Cambodia and China in 2019 was more than eight billion US dollars. Of that volume, Cambodia exported more than one billion USD to China and China imported more than seven billion USD to Cambodia. Cambodia and China expect to reach a trade volume of ten billion US dollars by 2023 after signing the free trade agreement this year.

In whole, the signing of the Cambodia-China Free Trade Agreement bears two meanings -economical and political. In economic terms, this agreement will help the Cambodian economy to develop and grow. In political terms, it is a message to other countries Cambodia has one more special economic gateway, and will continue to have more portals with economic importance to the world market.

The agreement has brought numerous economic and social benefits to the people of the two countries through the liberalization of trade in goods and services, the promotion of comprehensive investment, as well as cooperation in a number of areas. The agreement also reflects the traditional long-term relation as well as cooperation in a comprehensive partnership between the two countries./.

THE PRACHEACHUN MAGAZINE

សម្តេចតេជោ ហ៊ុន សែន ៖ យើងត្រូវបង្ហាញពីសាមគ្គីភាពនិងការជឿទុកចិត្តគ្នាទៅវិញទៅមកក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ដើម្បីធានាថា ជំងឺនេះនឹងមិនបំផ្លិចបំផ្លាញសេដ្ឋកិច្ចនិងសុខភាពសាធារណៈរបស់ជាតិយើង

មិនអាចអត់ឱនឲ្យបានជនណា មួលបង្កាច់, ញុះញង់ អំពីបញ្ហាព្រំដែន

ពួកប្រឆាំងជ្រុលនិយម និងមជ្ឈដ្ឋានអគតិនៅតែបន្តប្រើប្រាស់ឧបាយកលគ្រប់បែបយ៉ាងប៉ុនប៉ងបង្កឲ្យមានចលាចលសង្គមអស្ថិរភាពនយោបាយ ធ្វើឲ្យបាត់បង់ជំនឿរបស់ប្រជាជនលើការដឹកនាំរបស់រាជរដ្ឋាភិបាល និងឈានទៅផ្តួលរំលំរាជរដ្ឋាភិបាលស្របច្បាប់ ។ ពួកគេបន្តញុះញង់អុចអាលឃោសនាសង្គ្រាមចិត្តសាស្ត្រជុំវិញបញ្ហាជំងឺកូវីដ-១៩ ព្រមទាំងបញ្ហាផ្សេងៗទៀត ហើយចុងក្រោយនេះបញ្ហាព្រំដែនត្រូវបានគេយកមកធ្វើការឃោសនា ច្នៃប្រឌិត បង្កើតជាព័ត៌មានក្លែងក្លាយក្នុងចេតនាទុច្ចរិត ដើម្បីវាយប្រហារដល់កិច្ចការព្រំដែនរបស់រាជរដ្ឋាភិបាល ហើយដែលសកម្មភាពទាំងអស់នោះនឹងប្រឈមមុខចំពោះផ្លូវច្បាប់ ។

បុគ្គល **រ៉ុង ឈុន** ប្រធានសហភាពសហជីពកម្ពុជា និងជាសមាជិកក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា ជាមនុស្សដែលមិនមាននូវការចេះដឹងបន្តិចណាទាល់តែសោះអំពីការងារព្រំដែន បែរជាហ៊ានចេញមកធ្វើសេចក្តីថ្លែងការណ៍ទាំងងងឹតងងុលបង្ហោះនៅលើទំព័រហ្វេសប៊ុករបស់ខ្លួនពាក់ព័ន្ធនឹងបញ្ហាព្រំដែន កម្ពុជា-វៀតណាម នៅឃុំត្រពាំងផ្លុង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ ។ ទង្វើរបស់ រ៉ុង ឈុន មានភាពប្រទាក់ក្រឡាគ្នាយ៉ាងច្បាស់លាស់នៅក្នុងយុទ្ធនាការរបស់ពួកប្រឆាំង ទាំងខាងក្នុង និងនៅក្រៅប្រទេស នៅក្នុងទម្រង់ថ្មីមួយទៀតនៃការបន្តធ្វើបដិវត្តន៍ពណ៌នៅកម្ពុជា ។

នៅថ្ងៃទី៣១ ខែកក្កដា សមត្ថកិច្ចបានអនុវត្តវិធានការច្បាប់ចាប់ខ្លួន រ៉ុង ឈុន ពីព្រោះថា អ្វីដែលបុគ្គលនេះ បានលើកឡើង គឺមានចេតនាបង្កើតប្រឌិតរឿង និងផ្សព្វផ្សាយព័ត៌មានក្លែងក្លាយដោយចេតនា មានលក្ខណៈទុច្ចរិត ដោយមានគោលបំណងច្បាស់លាស់ ក្នុងការបំភាន់សាធារណៈមតិជាតិ និងអន្តរជាតិ ធ្វើការចោទប្រកាន់ដោយគ្មានមូលដ្ឋានលើការងារព្រំដែនរបស់រាជរដ្ឋាភិបាលអំពីការធ្វើឲ្យបាត់បង់ទឹកដីក៏ដូចជាការបណ្តោយឲ្យមានការរំលោភបំពានទឹកដីពីប្រទេសជិតខាង ធ្វើឲ្យប្រជាជនបាត់បង់ជីវិស្រែចម្ការជាដើម ។ រ៉ុង ឈុន ត្រូវបានព្រះរាជអាជ្ញានៃតុលាការរាជធានីភ្នំពេញ ចោទប្រកាន់ពីបទញុះញង់ បង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ ។ ផ្នែកទី៣ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤៩៥ ដែលចែងអំពីបទញុះញង់ឲ្យប្រព្រឹត្តិបទឧក្រិដ្ឋជាអាទិ៍ បានចែងច្បាស់ថា ៖ **«អំពើញុះញង់ដោយផ្ទាល់ឲ្យប្រព្រឹត្តិបទឧក្រដ្ឋ ឬប្រព្រឹត្តិអំពើបង្កឲ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម តាមមធ្យោបាយណាមួយ ក្នុងចំណោមមធ្យោបាយដែលមានចែងនៅក្នុងមាត្រា ៤៩៤ (លក្ខខណ្ឌអត្ថិភាពនៃការញុះញង់) នៃក្រមនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ២ឆ្នាំ និងពិន័យជាប្រាក់ពី ១លានរៀល ទៅ ៤លានរៀល ប្រសិនបើការញុះញង់នេះ គ្មានប្រសិទ្ធភាពទេ»** ។

ដូច្នេះការអនុវត្តវិធានការច្បាប់របស់អាជ្ញាធរមានសមត្ថកិច្ច និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ គឺជាការត្រឹមត្រូវធ្វើឡើងស្របតាមច្បាប់ និងនីតិវិធីជាធរមាន ដើម្បីធានានូវសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ទប់ស្កាត់អំពើល្មើសច្បាប់ ដែលនេះជាវិធានការពង្រឹងនីតិរដ្ឋឲ្យបានរឹងមាំ ។ ដូចដែលគណៈកម្មការចម្រុះកិច្ចការព្រំដែនបានប្រកាសយ៉ាងច្បាស់លាស់ហើយថា ការខណ្ឌសីមា និងបោះបង្គោលព្រំដែនគោករវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ពុំបានធ្វើឲ្យកម្ពុជាបាត់បង់ទឹកដីនោះទេ និងពុំមានអាជ្ញាធរវៀតណាមចូលមករុញច្រានពលរដ្ឋខ្មែរមិនឲ្យដាំដុះក្នុងដីខ្មែរប្រមាណ ២០០ម៉ែត្រនោះដែរ ។ ជាគោលការណ៍ក្នុងការធ្វើព្រំដែន រាជរដ្ឋាភិបាលកម្ពុជាតែងតែបញ្ជាក់យ៉ាងច្បាស់ថា នឹងរក្សាទឹកដីឲ្យពលរដ្ឋខ្មែរ ដែលបាននឹងកំពុងគ្រប់គ្រងអាស្រ័យផលទាំងនោះ ឲ្យបន្តការគ្រប់គ្រង និងកាន់កាប់បង្កបង្កើនផលដដែល ។ រាជរដ្ឋាភិបាលគ្មានគោលការណ៍សងដីឲ្យពលរដ្ឋវិញក្រោយការបោះបង្គោលព្រំដែនដូចការលើកឡើងរបស់ជនខិលខូចនោះឡើយ ។ ជាមួយគ្នានេះប្រជាជនយើងទូទាំងប្រទេសសូមសម្តែងការអបអរសាទរ និងមានមោទនភាពយ៉ាងខ្លាំង ដែលរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងឈ្លាសវៃរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានអនុវត្តប្រកបដោយជោគជ័យ កិច្ចការខណ្ឌសីមា និងបោះបង្គោលព្រំដែនរវាងប្រទេសទាំងពីរ កម្ពុជា-វៀតណាម ធ្វើឡើងយ៉ាងម៉ត់ចត់ច្បាស់លាស់តាមគោលការណ៍ខ្សែព្រំដែនមិនកែប្រែក្រោយកម្ពុជាបានឯករាជ្យ ស្របតាមផែនទីផ្លូវការខ្នាត ១/១០០ ០០០ ដែលរហូតមកដល់បច្ចុប្បន្ននេះសម្រេចបានលទ្ធផល ៨៤% នៃខ្សែព្រំដែនរួម និងកំពុងបន្តធ្វើឲ្យបានចប់ជាស្ថាពរ ១០០% ដើម្បីធានាបាននូវផ្ទៃក្រឡាដី ១៨១.០៣៥គីឡូម៉ែត្រការ៉េ រក្សាបានបូរណភាពទឹកដី និងអធិបតេយ្យភាពជាតិ មិនឲ្យជាតិ និងប្រជាជនខាតបង់ឡើយ ។

ដោយឡែកនៅថ្ងៃទី៤ ខែសីហា គណៈកម្មាធិការចម្រុះកិច្ចការព្រំដែនក៏បានចេញសេចក្តីថ្លែងការណ៍ទាត់ចោលនូវសេចក្តីថ្លែងការណ៍ ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២០ របស់ក្រុមឧទ្ទាមក្រៅច្បាប់ ដែលបានចោទប្រកាន់បំផ្លើស មួលបង្កាច់អំពីសមិទ្ធផលការងារដែលសម្រេចបាន ដោយគណៈកម្មាធិការចម្រុះកិច្ចការព្រំដែននៃរាជរដ្ឋាភិបាលកម្ពុជា ហើយបែរជាត្រូវក្រុមឧទ្ទាមក្រៅច្បាប់ និងគូកនចោទថា ផែនទីឋានលេខាព្រំដែនខ្នាត ១/២៥ ០០០ ត្រូវបានគូសដោយវៀតណាមទៅវិញ ។ គួរបញ្ជាក់ថា ផែនទីឋានលេខាព្រំដែន ខ្នាត ១/២៥ ០០០ ជាផែនទីបង្ហាញពីលទ្ធផលប្រមាណជា ៨៤% ដែលកម្ពុជា និងវៀតណាមសម្រេចបានលើការងារព្រំដែន ជាផែនទីផលិតឡើងតាមរយៈការថតរូបភាពពីលើអាកាស (orthophoto-maps) តាមបែបបច្ចេកវិទ្យាថ្មីទំនើបមានភាពជាក់លាក់ដែលបង្ហាញយ៉ាងច្បាស់នូវទីតាំងបង្គោលព្រំដែន និងខ្សែព្រំដែន ដែលមានទាំងនិយាមកា និងឋានលេខាជាក់លាក់ ។

ករណីចាប់ខ្លួន រ៉ុង ឈុន នេះ អង្គការខុមហ្វ្រែលបានធ្វើការស្ទង់មតិនៅលើបណ្តាញសង្គមហ្វេសប៊ុក ដោយមានជម្រើសពីរ គឺ ទី១- ការចាប់លោក រ៉ុង ឈុន គឺរំលោភច្បាប់ និងសិទ្ធិ និងជម្រើសទី២- ការចាប់លោក រ៉ុង ឈុន មិនរំលោភច្បាប់ និងសិទ្ធិ ។ ការស្ទង់មតិនេះ បានចាប់ផ្តើមនៅម៉ោង ១២ និង ៥៥ នាទី រសៀលថ្ងៃទី៩ ខែសីហា ហើយបញ្ចប់នៅម៉ោង ១២ និង ៥៥ នាទី ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ ។ លទ្ធផលស្ទង់មតិ គឺ ក្នុងចំណោមមនុស្ស ១៣.៦០០នាក់ មាន ៨០% គាំទ្រជម្រើសទី២ និងប្រមាណ ២០% ប៉ុណ្ណោះ ដែលគាំទ្រជម្រើសទី១ ។ ប៉ុន្តែអង្គការខុមហ្វ្រែល ដែលអួតខ្លួនថា ឯករាជ្យ អត់ហ៊ានផ្សាយលទ្ធផលនេះទេ ។ ដូច្នេះ ជាការច្បាស់លាស់ហើយថា ប្រជាជនភាគច្រើនលើសលុបពិតជាគាំទ្ររាជរដ្ឋាភិបាល ក្នុងការងារព្រំដែន និងគាំទ្រដាច់ខាតចំពោះចំណាត់ការតាមវិធានការច្បាប់របស់រាជរដ្ឋាភិបាល ។ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា ការឈឺឆ្អាលនឹងព្រំដែន, រឿងទៅមើលព្រំដែន, រឿងស្រឡាញ់ទឹកដី គឺជារឿងដ៏ល្អរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបមិនមែនជារឿងខុសច្បាប់ទេ ។ ប៉ុន្តែអ្វីដែលជារឿងអាក្រក់ដែលយើងមិនអាចអត់ឱនឲ្យបាននោះ គឺការបំភ្លៃ, ការមួលបង្កាច់ និងការញុះញង់ដែលយកប្រធានបទព្រំដែនមកបំភ្លៃបំផ្លើសបង្កើតឲ្យមានចេតនា លាក់លៀមដ៏ អាក្រក់ ។ ការមួលបង្កាច់ខុសពីការពិត មិនមែនជាសេរីភាពនៃការបញ្ចេញមតិនៅក្នុងសង្គមប្រជាធិបតេយ្យទេ ។ ប៉ុន្តែវាជាបទល្មើសជាក់ស្តែងដែលរាជរដ្ឋាភិបាលអាចចោទប្រកាន់និងចាប់ខ្លួនបាន ៕

លទ្ធផលនៃដំណើរទស្សនកិច្ចផ្លូវការ ឯកឧត្តម ម៉ូតេហ្គី តូស៊ីមីសឺ រដ្ឋមន្ត្រីការបរទេសជប៉ុន នៅព្រះរាជាណាចក្រកម្ពុជា



*ឯកឧត្តម **ម៉ូតេហ្គី តូស៊ីមីសឺ** អញ្ជើញជួបសម្តែងការគួរសម **សម្តេចតេជោ ហ៊ុន សែន** ដើម្បីពង្រឹងពង្រីកទំនាក់ និងកិច្ចសហប្រតិបត្តិការទ្វេភាគី*

ចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម **ម៉ូតេហ្គី តូស៊ីមីសឺ** (MOTEGI ToShimitsu) រដ្ឋមន្ត្រីក្រសួងការបរទេសជប៉ុន បានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា ដើម្បីពង្រឹងពង្រីកទំនាក់ និងកិច្ចសហប្រតិបត្តិការទ្វេភាគី។ ក្នុងឱកាសបំពេញទស្សនកិច្ចផ្លូវការនេះ ឯកឧត្តម **ម៉ូតេហ្គី តូស៊ីមីសឺ** បានជួបសម្តែងការគួរសម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងចូលរួមពិសាអាហារថ្ងៃត្រង់រៀបចំដោយ**សម្តេចតេជោ ហ៊ុន សែន** ព្រមទាំងជួបពិភាក្សាទ្វេភាគីជាមួយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

ឯកឧត្តម **ម៉ូតេហ្គី តូស៊ីមីសឺ** បានសម្តែងការអបអរសាទរចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដែលសម្រេចបានវឌ្ឍនភាពសេដ្ឋកិច្ច-សង្គមយ៉ាងខ្លាំងក្លា និងទប់ស្កាត់បានដោយជោគជ័យនូវការឆ្លងរីករាលដាលជំងឺកូវីដ-១៩ ក្នុងប្រទេសកម្ពុជា។ ភាគីកម្ពុជា ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលជប៉ុនដែលបានចូលរួមចំណែកធំធេងដល់សន្តិភាព និងការអភិវឌ្ឍនៅកម្ពុជា ហើយថ្មីៗ បានផ្តល់ជំនួយដល់កម្ពុជាដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងបានជួយឧបត្ថម្ភដល់ពលរដ្ឋ និងកម្មសិក្សាការីខ្មែរស្នាក់នៅជប៉ុន ដែលជួបការលំបាកដោយសារជំងឺរាលដាលនេះ។ ភាគីកម្ពុជា បានកោតសរសើរដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងប្រជាជនជប៉ុនដែលបានចាត់វិធានការមុឺងម៉ាត់ ដើម្បីគ្រប់គ្រងការរាលដាលជំងឺកូវីដ-១៩។ ភាគីទាំងពីរបានប្តេជ្ញាចិត្តជាមួយគ្នាថា នឹងបន្តកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីប្រយុទ្ធនឹងជំងឺនេះ ទន្ទឹមគ្នានឹងការស្តារសេដ្ឋកិច្ច-សង្គមឡើងវិញ។ ភាគីទាំងពីរកម្ពុជា-ជប៉ុន បានសម្តែងការពេញចិត្តយ៉ាងខ្លាំងចំពោះវឌ្ឍនភាព នៃទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការទ្វេភាគីក្នុងនាមជាដៃគូយុទ្ធសាស្ត្រ ព្រមទាំងបានឯកភាពគ្នាបន្តពូនជ្រុំឲ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីបន្តជំរុញកិច្ចសហប្រតិបត្តិការ និងសកម្មភាពសេដ្ឋកិច្ចរវាងប្រទេសទាំងពីរ ដែលរងផលប៉ះពាល់ដោយជំងឺកូវីដ-១៩។ ភាគីទាំងពីរបានឯកភាពឲ្យបើកឡើងវិញតាមដំណាក់កាល និងជាបណ្តើរៗនូវការធ្វើដំណើរឆ្លងដែនរវាងកម្ពុជា និងជប៉ុន សម្រាប់អ្នកដំណើរក្នុងគោលដៅបំពេញការងារ និងធុរកិច្ច ដោយគោរពយ៉ាងម៉ឺងម៉ាត់នូវវិធានការទប់ស្កាត់ជំងឺរាតត្បាត។ ភាគីទាំងពីរនឹងធ្វើការជាមួយអាជ្ញាធរមានសមត្ថកិច្ចរៀងខ្លួនដើម្បីចាប់ផ្តើមការធ្វើដំណើរឆ្លងដែន សម្រាប់ការស្នាក់នៅរយៈពេលយូរលើស១៤ថ្ងៃ «**ច្រកចូលសម្រាប់ការស្នាក់នៅ**» នៅដើមខែកញ្ញា ឆ្នាំ ២០២០ និងពន្លឿនកិច្ចពិភាក្សាស្តីពីការអនុវត្តការធ្វើដំណើរឆ្លងដែនសម្រាប់ការស្នាក់នៅរយៈពេលខ្លីជាង១៤ថ្ងៃ « **ច្រកសម្រាប់ធុរកិច្ច**»។ ភាគីកម្ពុជាបានអរគុណរដ្ឋាភិបាលជប៉ុន ដែលបន្តផ្តល់ជំនួយដើម្បីអភិវឌ្ឍន៍ធនធានមនុស្ស និងកសាងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គមកិច្ចរបស់កម្ពុជា។ ឯកឧត្តម **ម៉ូតេហ្គី** បានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ជប៉ុន ក្នុងការបន្តគាំទ្រកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញដំណើរការលទ្ធិប្រជាធិបតេយ្យលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន និងការអភិវឌ្ឍប្រទេសកម្ពុជាលើគ្រប់វិស័យ។ ភាគីទាំងពីរក៏បានពិភាក្សាអំពីដំណើរការអនុវត្តគម្រោងសំខាន់ៗនៅកម្ពុជា រួមទាំង គម្រោងអភិវឌ្ឍន៍កំពង់ផែក្រុងព្រះសីហនុ ផែកុងតឺន័រថ្មីនៅក្រុងព្រះសីហនុ និងផ្លូវជាតិលេខ៥ ដែលនឹងរួមចំណែកដល់ការពង្រីកសកម្មភាពវិនិយោគ និងបង្កើនទំហំពាណិជ្ជកម្មរវាងប្រទេសទាំងពីរ ខណៈដែលកម្ពុជាបានប្តេជ្ញាបន្តខិតខំកែលម្អបរិយាកាសធុរកិច្ច និងវិនិយោគឲ្យកាន់តែប្រសើរឡើងថែមទៀត ។ ភាគីទាំងពីរ ក៏បានសម្តែងសេចក្តីប្រាថ្នារួមក្នុងការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យជាពិសេសកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ សុខាភិបាល អប់រំ និងវប្បធម៌។ ភាគីជប៉ុន បានសម្តែងនូវឆន្ទៈគាំទ្រកិច្ចប្រឹងប្រែងរបស់កម្ពុជាក្នុងការកសាងសមត្ថភាពឧស្សាហកម្មកែច្នៃកសិផល និងឧស្សាហកម្មប្រើបច្ចេកវិទ្យាទំនើប និងពង្រីកកិច្ចសហប្រតិបត្តិការអភិរក្សប្រាសាទបុរាណនៅកម្ពុជា។ ភាគីកម្ពុជា បានសម្តែងការពេញចិត្តចំពោះសកម្មភាពជំរុញការប្រាស្រ័យទាក់ទងផ្នែកវប្បធម៌ និងអប់រំរបស់ការិយាល័យទំនាក់ទំនងមជ្ឈមណ្ឌលអាស៊ីនៃមូលនិធិជប៉ុននៅភ្នំពេញ ហើយស្វាគមន៍ឲ្យការិយាល័យនេះ បន្តតាំងនៅជាអចិន្ត្រៃយ៍ក្នុងប្រទេសកម្ពុជា ។ ភាគីទាំងពីរ បានផ្លាស់ប្តូរទស្សនៈលើបញ្ហាក្នុងតំបន់ និងអន្តរជាតិមួយចំនួន ដែលជាប្រយោជន៍រួម ដូចជា បញ្ហាសមុទ្រចិនខាងត្បូង កិច្ចខិតខំដើម្បីសម្រេចឲ្យបានឆាប់នូវកិច្ចព្រមព្រៀងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ (RCEP) និងការលុបបំបាត់អាវុធនុយក្លេអ៊ែរពីឧបទ្វីបកូរ៉េ គំនិតនៃទស្សនវិស័យអាស៊ានស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក និងចក្ខុវិស័យឥណ្ឌូ-

តទៅទំព័រទី ៨

សម្តេចតេជោ ៖ យើងត្រូវម្ចាស់ការលើការងារជាអាទិភាពចម្បង២ គឺរក្សាស្ថិរភាពនយោបាយ និងរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច

ការមួលបង្កាច់ខុសពីការពិត មិនមែនជាសេរីភាពនៃការបញ្ចេញមតិនៅក្នុងសង្គមប្រជាធិបតេយ្យទេ

សម្តេចតេជោ ហ៊ុន សែន អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ដឹកនាំកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី

នៅថ្ងៃទី១៤ខែសីហាឆ្នាំ២០២០ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ដឹកនាំ កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យពិភាក្សា និងអនុម័តលើខ្លឹមសារសំខាន់ៗមួយចំនួនរួមមាន៖ **១**-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីដំឡូងមី ២០២០-២០២៥ **២**-សេចក្តីព្រាងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ (IDP) ក្នុងឆ្នាំ ២០១៧-២០១៨ និង៣-សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន - ហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន, សេចក្តីព្រាងច្បាប់ស្តីពីវិសោធនកម្មក្រុងគីហ្គាលីនៃពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន, សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាសមាជិកនៃអនុសញ្ញាមីណាម៉ាតា ស្តីពីបារ៉ត, សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើអនុសញ្ញាស្តីពីបត្យាប័នរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង, សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើសន្ធិសញ្ញា ស្តីពីការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ក្នុង វិស័យព្រហ្មទណ្ឌរវាងព្រះរាជាណាចក្រកម្ពុជា និងសហព័ន្ធរុស្ស៊ី។

ក្នុងឱកាសនោះ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា បើទោះបីពិភពលោកនៅបន្តស្ថិតនៅក្នុងស្ថានភាព មិនច្បាស់លាស់នៅឡើយអំពីថ្នាំព្យាបាលជំងឺកូវីដ-១៩ កម្ពុជាត្រូវតែមានភាពច្បាស់លាស់និងម្ចាស់ការលើការងារជាអាទិភាពចម្បងពីរគឺ៖ **ទី១**-ការបន្តរក្សានូវស្ថិរភាពនយោបាយដែលជាមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងស្ថានការណ៍ និង **ទី២**-ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចឲ្យបានល្អប្រសើរទប់ស្កាត់អតិផរណា និងការឡើងថ្លៃទំនិញក្នុងទីផ្សារ ។ **សម្តេចតេជោ ហ៊ុន សែន** បានណែនាំដល់ក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវអនុវត្តទិសដៅភារកិច្ចចំនួនរួមមានជាអាទិ៍៖ បន្តប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ កុំឲ្យឆ្លងរីករាលដាលក្នុងសហគមន៍ ហើយត្រូវបន្តអនុវត្តវិធានការសុខាភិបាលឲ្យបានជិតដល់ នៅកន្លែងដែលមានភ្ញៀវទេសចរទៅកម្សាន្តពិសេសក្នុងកំឡុងពេលឈប់សម្រាក ដើម្បីថែរក្សាសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ ក្រសួងសុខាភិបាលត្រូវខិតខំស្តាបនាមន្ទីរពិសោធន៍សម្រាប់ធ្វើតេស្តមើលមេរោគកូវីដ-១៩ បន្ថែមពីលើមន្ទីរពិសោធន៍នៅរាជធានីភ្នំពេញ នៅខេត្តសំខាន់ចំនួន ៣ទៀតគឺ ខេត្តព្រះសីហនុ ខេត្តសៀមរាប និងខេត្តបាត់ដំបង ។ បន្តរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សាធារណៈ និងធានាសុវត្ថិភាពចរាចរណ៍ដើម្បីការពារភាពសុខសាន្ត និងអាយុជីវិតរបស់ប្រជាពលរដ្ឋ។ បន្តអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រ និងងាយរងគ្រោះដោយសារផលប៉ះពាល់នៃជំងឺកូវីដ-១៩ ចំនួនពីរខែទៀត។ ជំរុញនិងលើកទឹកចិត្តការបង្កបង្កើតផលក្នុងវិស័យកសិកម្ម ដោយប្រមូលផ្តុំឡើងវិញនូវកម្លាំងពលកម្មពីវិស័យសេវាកម្ម និងឧស្សាហកម្ម ដែលបាននិងកំពុងរងផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩ ដើម្បីគាំទ្រដល់ផលិតកម្មកសិកម្ម សម្រាប់ផ្គត់ផ្គង់តម្រូវការក្នុងស្រុក និងការនាំចេញទៅទីផ្សារក្រៅប្រទេស ព្រមទាំងលើកទឹកចិត្តដល់ប្រជាកសិករទូទាំងប្រទេស ឲ្យធ្វើការចិញ្ចឹម ត្រីអណ្តែង ឲ្យបានច្រើន ដើម្បីផ្គត់ផ្គង់តម្រូវការទីផ្សារក្នុងស្រុក និងគាំទ្រដល់ការនាំចេញទៅលក់នៅក្រៅប្រទេស។ អនុញ្ញាត ឲ្យបើកដំណើរការឡើងវិញនូវគ្រឹះស្ថានសិក្សាចំណេះទូទៅ និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយត្រូវ មានការបាញ់ថ្នាំសម្លាប់មេរោគឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ជាពិសេសអគារសិក្សាដែលធ្លាប់ប្រើប្រាស់ធ្វើជាមណ្ឌលចត្តាឡីស័ក ។ក្នុងនាមរាជរដ្ឋាភិបាល **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងអំណរគុណ និងកោតសរសើរចំពោះសមត្ថភាព និងការទទួលខុសត្រូវខ្ពស់របស់ក្រុមគ្រូពេទ្យ និងមន្ត្រីសុខាភិបាលកម្ពុជា ដែលបានខិតខំរួមចំណែកលើកកម្ពស់គុណភាពវិស័យសុខាភិបាល ក្នុងស្រុកនាពេលបច្ចុប្បន្នមានការកើនឡើង ដែលជាការជំនួសការចេញទៅព្យាបាលនៅក្រៅប្រទេសរបស់ប្រជាពលរដ្ឋក្នុងកំឡុងវិបត្តិនៃជំងឺកូវីដ-១៩ ។ ជាមួយគ្នានេះ សម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានថ្លែងអំណរគុណចំពោះគ្រប់ក្រសួងស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិកងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់វិស័យឯកជន និងប្រជាជនទូទាំងប្រទេស ដែលបានខិតខំនិងចូលរួមយ៉ាងសកម្មជាមួយរាជរដ្ឋាភិបាល ក្នុងការរក្សានូវសុខសន្តិភាព ស្ថិរភាពនយោបាយ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក៏ដូចជាចូលរួមប្រយុទ្ធប្រឆាំងនិងទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីត- ១៩ នាពេលកន្លងមកនៅព្រះរាជាណាចក្រកម្ពុជា ។

សម្តេចតេជោ ហ៊ុន សែន អញ្ជើញជាអធិបតីភាពក្នុងពិធីបើកសម្ពោធសួនទឹក «ហ្គាឌិនស៊ីធី»

✵ នៅព្រឹកថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញទស្សនកិច្ច និងបើកសម្ពោធសួនទឹក **«ហ្គាឌិនស៊ីធី»** នៅសង្កាត់ព្រែកតាសេក ខណ្ឌជ្រោយចង្វា រាជធានីភ្នំពេញ។ សួនទឹក «ហ្គាឌិនស៊ីធី» នេះ គឺជាកន្លែងលេងទឹកកម្សាន្តដ៏ធំ និងដំបូងគេនៅក្នុងប្រទេសកម្ពុជា ត្រូវបានសាងសង់ឡើងនៅតំបន់អភិវឌ្ឍន៍របស់លោកឧកញ៉ា **លី យ៉ុងផាត់** ដែលជាតំបន់អភិវឌ្ឍន៍រណបមួយភាគខាងជើងឈាងខាងកើតរាជធានីភ្នំពេញ។ សួនទឹក «ហ្គាឌិនស៊ីធី» ត្រូវបានបោះទុនវិនិយោគសរុបជាង ៤៤លានដុល្លារអាមេរិក។ សួនទឹកនេះមានបុគ្គលិកបម្រើការរហូតដល់ទៅ ២៣០នាក់។

សម្តេចតេជោ ហ៊ុន សែន បានសម្តែងនូវមោទនភាពដែលកម្ពុជា យើងមានសួនទឹកកម្សាន្តដ៏ទំនើបបែបនេះ។ សម្តេចតេជោក៏បានកោតសរសើរដល់ក្រុមហ៊ុនវិនិយោគរបស់លោកឧកញ៉ា **លី យ៉ុងផាត់** ដែលបានមកវិនិយោគនៅក្នុងតំបន់នេះ ដែលពីមុនជាតំបន់មិនមានការអភិវឌ្ឍអ្វីនោះទេ ហើយក៏ជាតំបន់ពួនស្ទាក់របស់ពួកខ្មែរក្រហមក្នុងការត្រៀមវាយឆ្មក់ចូលទីក្រុងភ្នំពេញដែរ។ តែពេលនេះនៅតំបន់នេះ យើងមានទាំងសណ្ឋាគារផ្កាយ៥ ,សួនសត្ច, សួនទឹក, ជាពិសេសទឹកដីនៅទីនេះ ក៏បានជ្រើសរើសជាកន្លែងសាងសង់វិមានឈ្នះឈ្នះ ដែលតំណាងឲ្យការបញ្ចប់សង្ត្រាមនៅកម្ពុជា ព្រមទាំងជ្រើសរើសសម្រាប់សាងសង់ពហុកីឡដ្ឋានអន្តរជាតិ សម្រាប់ត្រៀមរៀប Sea Game ឆ្នាំ២០២៣ ខាងមុខ។

ទាក់ទងនឹងវិធានការទប់ស្កាត់ការរីករាលដាលជម្ងឺកូវីដ១៩ **សម្តេចតេជោ ហ៊ុន សែន** បានរំលឹកដាស់តឿនដល់ប្រជាពលរដ្ឋឲ្យមានការប្រុងប្រយ័ត្នក្នុងពេល ដែលទទួលបានការឈប់សម្រាកសងជំនួសការឈប់សម្រាកចូលឆ្នាំខ្មែរដែលមានចំនួន ៥ថ្ងៃ ជាពិសេស អាជ្ញាធរ កងកម្លាំងសមត្ថកិច្ចត្រូវចូលរួមការពារសេចក្តីសុខសុវត្តិភាពប្រជាពលរដ្ឋក្នុងថ្ងៃឈប់សម្រាកនេះ។ ក្នុងនោះក្រសួងសុខាភិបាល, ក្រសួងទេសចរណ៍ និងផ្នែកពាក់ព័ន្ធដ៏ទៃទៀត ត្រូវតាមដានស្ថានភាព និងទប់ស្កាត់ការឆ្លងជម្ងឺកូវីដ១៩នេះឲ្យបានហ្មត់ចត់បំផុត។ សម្តេចតេជោនាយករដ្ឋមន្ត្រីក៏បានអំពាវនាវឲ្យពលរដ្ឋរក្សាសុវត្ថិភាពផ្ទាល់ខ្លួនឯង ក្នុងនោះរមណីដ្ឋាន, ភោជនីយដ្ឋាន ត្រូវតែធានាឲ្យបាននូវអនាម័យល្អ ដើម្បីកុំឲ្យឆ្លងជំងឺកូវីដ-១៩ នេះឲ្យសោះ ជាពិសេសធានាឲ្យបានថាក្រោយថ្ងៃឈប់សម្រាកមិនមានអ្នកឆ្លងកូវីដ១៩ក្នុងសហគមន៍។ បងប្អូនប្រជាពលរដ្ឋក៏ត្រូវចូលរួមគោរពច្បាប់ចរាចរណ៍ កុំឲ្យកើតមានគ្រោះថ្នាក់ចរាចរណ៍ ក្នុងពេលឈប់សម្រាក គឺត្រូវបើកបរដោយមានការប្រុងប្រយ័ត្ននិងគ្មានជាតិស្រវឹង។

ទាក់ទងទៅនឹងបញ្ហាព្រំដែន **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា ផែនទីប្រើសម្រាប់កំណត់ព្រំដែនជាមួយប្រទេសវៀតណាម គឺបន្សល់ដោយបារាំងមិនមែនជាផែនទីកំណត់ដោយខ្មែរនោះទេ។ សម្តេចតេជោបានពន្យល់ថា ភូមិខ្មែរមួយចំនួនដែលចូលទៅភាគីវៀតណាម ដោយសារតែខ្សែបន្ទាត់ព្រំដែនរបស់បារាំងបានគូសបែបនោះ។ ហេតុនេះ ហើយទើបកម្ពុជា និងវៀតណាម បានព្រមព្រៀងគ្នាក្នុងការដោះដូរដីភូមិរៀងៗខ្លួន។ តាមរយៈខ្សែផែនទីនេះកម្ពុជាទទួលបានដីពីវៀតណាម ប្រមាណ២ពាន់ហិកតា។ ដីនេះត្រូវយកទុកជាដី សម្បទានសង្គមកិច្ច។ **សម្តេចតេជោ ហ៊ុន សែន** ថ្លែងថា រឿងព្រំដែនមិនមែនជារឿងលេងសើចទេកុំញុះញង់ឱ្យមានសង្ត្រាមជាមួយប្រទេសជិតខាង។ សម្តេចតេជោបានថ្លែងថា ការរៀបចំព្រំដែនរវាងកម្ពុជា និងវៀតណាម បានធ្វើតាមផែនទីបោន ១/១០០ ០០០ និងផែនទី UTM ១/៥០ ០០០។ សម្រាប់ផែនទី ១/២៥ ០០០ គឺធ្វើឡើងដើម្បីងាយស្រួលក្នុងការមើលនិយាមការលើព្រំដែនជាក់ស្តែង។ រឿងព្រំដែនឈប់រញ៉ៀរញ៉ៀ ប្រសិនបើអ្នកណានិយាយចេញមកប៉ុណ្ណាចាប់ប៉ុណ្ណឹង ហើយកុំចោទរាជរដ្ឋាភិបាលថាផ្តាច់ការ ព្រោះការនិយាយរឿងព្រំដែនមិនមែនជាការបញ្ចេញមតិនោះទេ។ ក្រុមប្រឆាំងបានលើកឡើងច្រើនដងហើយលើបញ្ហាព្រំដែន ហើយសម្តេចក៏បានបកស្រាយច្រើនដងរួចហើយ ព្រមទាំងក្នុងរដ្ឋសភាផងដែរ។ សម្តេចតេជោបានចោទសួរក្រុមប្រឆាំងថា ស្នេហាជាតិអីតែខ្លួនឯង តើព្រះមហាក្សត្រ រដ្ឋសភា រាជរដ្ឋាភិបាលមិនស្នេហាជាតិទេឬអី?។ ព្រំដែនរវាងកម្ពុជា និងប្រទេសជិតខាង មិនស្ថិតនៅលើមាត់របស់ក្រុមប្រឆាំងទេ គឺស្ថិតនៅលើច្បាប់អន្តរជាតិ។ ជុំវិញករណីចាប់ខ្លួន រ៉ុង ឈុន **សម្តេចតេជោ ហ៊ុន សែន** ថ្លែងថា តើអង្គការខុមហ្វ្រែលក្រុមវិទ្យុបរទេសផ្សាយជាខេមរភាសា និងអង្គការសិទ្ធិមនុស្សនានា ហ៊ានផ្សាយលទ្ធផលស្ទង់មតិលើការចាប់ខ្លួនលោក រ៉ុង ឈុន ដែរឬយ៉ាងណា? បើអង្គការ ខុមហ្វ្រែលវិទ្យុបរទេសផ្សាយខេមរភាសា និងអង្គការសិទ្ធិមនុស្ស ព្រមទាំងក្រុមប្រឆាំងផង មិនផ្សាយលទ្ធផលស្ទង់មតិនេះ គឺជាតិវិច្ឆានហើយ។ ការស្ទង់មតិនេះ មាន ៧៨% គាំទ្រចំណាត់ការរាជរដ្ឋាភិបាល និងមាន ២២%ប៉ុណ្ណោះ មិនគាំទ្រ។ ក្នុងឱកាសនោះ **សម្តេចតេជោ ហ៊ុន សែន** បានអំពាវនាវជាថ្មីដល់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុមានការយោគយល់ចំពោះអ្នកជំពាក់ប្រាក់ទាំងអស់ ដោយកុំឲ្យមានការរឹបអូសយកទ្រព្យសម្បត្តិរបស់ពួកគេ និងរៀបចំនូវកម្ចីតណទានឡើងវិញ។ ប៉ុន្តែសម្តេចតេជោក៏បានប្រកាសបន្តរក្សាជំហរឲ្យរឹបអូសទ្រព្យសម្បត្តិរបស់អ្នកជំពាក់ទាំងឡាយណា ដែលស្តាប់តាមការអំពាវនាវរបស់មេឧទ្ទាមមិនឲ្យសងប្រាក់ទៅធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។

✵ នៅព្រឹកទី២៥ ខែសីហា ឆ្នាំ២០២០ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ដឹកនាំប្រជុំបូកសរុបការងារឆមាសទី៤ របស់ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់។ ក្នុងកិច្ចប្រជុំនេះ ប្រធានគណៈប្រតិភូ នៃគណបក្សនយោបាយជាសមាជិក ត្រូវបានអនុញ្ញាតឱ្យផ្តល់នូវទស្សនទាន ដើម្បីផ្តល់ធាតុចូលក្នុងន័យស្ថាបនាអំពីបរិបទបច្ចុប្បន្នភាពសង្គម ដោយផ្អែកលើការរកឃើញតម្រុយ និងភស្តុតាងនានា តាមរយៈបេសកកម្មការងារបន្ថែមជាមួយនឹងការប្រឈមនឹងជំងឺ

កូវីដ-១៩ផងដែរ។

សម្តេចតេជោ ហ៊ុន សែន បានស្នើឱ្យប្រតិភូគណបក្សនយោបាយនៅក្នុងឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ ចូលរួមជាមតិយោបល់ជុំវិញបញ្ហាកូវីដ-១៩ ដែលរាជរដ្ឋាភិបាលបានដាក់ចេញវិធានការឆ្លើយតប រួមទាំងបញ្ហាផ្សេងៗ ដែលជាដំណោះស្រាយលើបញ្ហាសេដ្ឋកិច្ច-សង្គម។ សម្តេចតេជោ បានថ្លែងថា បញ្ហាជំងឺកូវីដ-១៩ មិនមែនជាបញ្ហាដាច់ដោយឡែករបស់កម្ពុជានោះទេ វាជាបញ្ហារួមរបស់សកលលោក។ សម្តេចចង់ឱ្យតំណាងប្រតិភូគណបក្សនយោបាយ នៃឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ ចូលរួមផ្តល់នូវមតិទៅលើបញ្ហាការដោះស្រាយរបស់រាជរដ្ឋាភិបាល ទៅលើបញ្ហាកូវីដ-១៩នេះ ថាតើ បានដោះស្រាយសមស្រប ឬនៅ តើនៅមានអ្វីទៀតជាចន្លោះប្រហោង។

ទាក់ទងទៅនឹងបញ្ហាព្រំដែន **សម្តេចតេជោ ហ៊ុន សែន** បានណែនាំ ឯកឧត្តម **ខ៉ា គឹមហុង** ប្រធានគណៈកម្មាធិការចម្រុះកិច្ចការព្រំដែនកម្ពុជា ចុះទៅជួបប្រជាពលរដ្ឋ ដែលអះអាងថា បាត់ដីនៅខេត្តត្បូងឃ្មុំក្រោយការបោះបង្គោលព្រំដែន។ជាមួយគ្នានេះដែរ**សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃកម្ពុជា បានណែនាំទៅកាន់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប៊ិន ឈិន រដ្ឋមន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី ឲ្យបើកសិក្ខាសាលាមួយដើម្បីឲ្យប្រជាពលរដ្ឋសិស្សនិស្សិតចូលស្តាប់និងសួរអំពីរឿងព្រំដែន ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ការឈឺឆ្អាលនឹងព្រំដែន, រឿងទៅមើលព្រំដែន, រឿងស្រឡាញ់ទឹកដី គឺជារឿងដ៏ល្អរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូបមិនមែនជារឿងខុសច្បាប់ទេ ។ ប៉ុន្តែអ្វីដែលជារឿងអាក្រក់ដែលយើងមិនអាចអត់ឱនឲ្យបាននោះគឺការបំភ្លៃ, ការមួលបង្កាច់ និងការញុះញង់ដែលយកប្រធានបទព្រំដែនមកបំភ្លៃបំផ្លើសបង្កើតឲ្យមានចេតនា លាក់លៀមដ៏ អាក្រក់។ ការមួលបង្កាច់ខុសពីការពិត មិនមែនជាសេរីភាពនៃការបញ្ចេញមតិនៅក្នុងសង្គមប្រជាធិបតេយ្យទេ។ ប៉ុន្តែវាជាបទល្មើសជាក់ស្តែងដែលរាជរដ្ឋាភិបាលអាចចោទប្រកាន់ និងចាប់ខ្លួនបាន ។

សម្តេចតេជោ ហ៊ុន សែន អញ្ជើញដឹកនាំប្រជុំបូកសរុបការងារឆមាសទី៤ របស់ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់

សូមបញ្ជាក់ថា ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ ត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យចុះថ្ងៃទី៦ខែកញ្ញាឆ្នាំ២០១៨ដោយមានការស្នើសុំរបស់**សម្តេចតេជោ ហ៊ុន សែន** ក្រោយពេលបោះឆ្នោតជាតិអាណត្តិទី៦។ ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ មានសមាសភាពមកពីគណបក្សយោបាយចំនួន១៦ ក្នុងចំណោមគណបក្សនយោបាយចំនួន២០ ដែលបានចូលរួមការបោះឆ្នោតជាតិឆ្នាំ២០១៨។ ឧត្តមក្រុមប្រឹក្សាពិគ្រោះ និងផ្តល់យោបល់ មានតួនាទីផ្តល់យោបល់ជូនរាជរដ្ឋាភិបាលក្រៅក្របខណ្ឌសភា ក្នុងគោលដៅលើកស្ទួយប្រសិទ្ធភាពការងារ ដើម្បីជាប្រយោជន៍ដល់ការបម្រើសេវាប្រជាពលរដ្ឋ និងការអភិវឌ្ឍសង្គមប្រកបដោយសក្តានុពល៕

តមកពីទំព័រទី ៥



*ឯកឧត្តម **ហ្វាក់ សុខុន** អញ្ជើញជួបពិភាក្សាទ្វេភាគីជាមួយឯកឧត្តម **ម៉ូតេហ្គី តូស៊ីមីស៊ី***

ប៉ាស៊ីហ្វិកសេរី និងបើកចំហរ ដែលផ្តួចផ្តើមដោយជប៉ុន។ ភាគីទាំងពីរបានឯកភាពបន្តគាំទ្រគ្នាទៅវិញទៅមក ទាំងក្នុងក្របខណ្ឌតំបន់ និងអន្តរជាតិ និងធ្វើការជិតស្និទ្ធដើម្បីធ្វើការបន្សុីគ្នានូវរាល់គំនិតផ្តួចផ្តើមទាំងអស់ ដែលមានគោលដៅក្នុងការលើកកម្ពស់សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រកបដោយបរិយាបន្ន។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា ក្នុងឆ្នាំ២០១៩ កម្ពុជា-ជប៉ុនមានទំហំពាណិជ្ជកម្មប្រមាណ២ពាន់លានដុល្លារសហរដ្ឋអាមេរិក ក្នុងនោះកម្ពុជានាំចេញទៅជប៉ុន១,២ ពាន់លានដុល្លារ ហើយជប៉ុននាំចូលមកកម្ពុជាវិញ០,៨ ពាន់លានដុល្លារ ។ ដោយឡែកនៅក្នុងឆ្នាំ២០២០ នេះ រយៈពេល៩ខែ ទំហំពាណិជ្ជកម្មប្រទេសទាំងពីរមានប្រមាណ៨០០លានដុល្លារសហរដ្ឋអាមេរិក ក្នុងនោះកម្ពុជានាំចេញទៅជប៉ុនប្រមាណ ៥០០លានដុល្លារ និងជប៉ុននាំចូលមកកម្ពុជាប្រមាណ ៣០០លានដុល្លារ ។ **សម្តេចតេជោ ហ៊ុន សែន** បានមានប្រសាសន៍បន្ថែមថា ចំពោះការបើកដំណើរការឡើងវិញនៃប្រទេសទាំងពីរ សម្តេចបានស្នើឲ្យមានការហោះហើរឡើងវិញរបស់ក្រុមហ៊ុនអាណាណា ដែលការហោះហើរនេះ នឹងអាចនាំឲ្យការធ្វើដំណើររវាងប្រទេសទាំងពីរមានសភាពការណ៍ធម្មតាឡើងវិញ ជាពិសេសត្រូវអនុវត្តនូវវិធានការមួយចំនួនផងដែរ។ សម្តេចតេជោបន្តថា ការហោះហើរឡើងវិញនេះ នាំឲ្យមានការកើនឡើងក្នុងទំហំពាណិជ្ជកម្ម និងការវិនិយោគផងដែរ។

សម្តេចតេជោ ហ៊ុន សែន ក៏បានថ្លែងអំណរគុណចំពោះប្រទេសជប៉ុន ដែលបានជួយដល់កម្ពុជា ជាពិសេសជាមួយនឹងកម្មវិធីជំនួយក្រៅប្រទេស ដែលរាល់គម្រោងទាំងនោះមិនមានការពន្យា ឬបញ្ឈប់នោះទេ ផ្ទុយទៅវិញកំពុងតែដំណើរការជាប្រក្រតី៕

សម្តេចអគ្គមហាពញាចក្រី ជំរុញមន្ត្រី និងអាជ្ញាធរមូលដ្ឋាន បង្កលក្ខណសម្បត្តិ ដល់ប្រជាពលរដ្ឋ ក្នុងការពង្រីកមុខរបរកសិកម្ម និងចិញ្ចឹមសត្វ

សម្តេចអគ្គមហាពញាចក្រី ហោ ង សំរិន អញ្ជើញជ្រាវជ្រាវពិធីសូត្រមន្តប្រោះព្រំ "អាស្រមមរតកចក្រី" នៅក្នុងភូមិអភិវឌ្ឍន៍អន្លង់ជ្រៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ

នៅព្រឹកថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ បន្ទាប់ពីប្រារព្ធពិធីសូត្រមន្តប្រោះព្រំ **"អាស្រមមរតកចក្រី"** នៅក្នុងភូមិអភិវឌ្ឍន៍អន្លង់ជ្រៃ ឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំរួចមក **សម្តេចអគ្គមហាពញាចក្រី ហោ ង សំរិន** ប្រធានកិត្តិយសគណបក្សប្រជាជនកម្ពុជា ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីជួបសំណេះសំណាលជាមួយមន្ត្រីរាជការ សមាជិក សមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ និងស្រុក នៃខេត្តស្វាយរៀង ខេត្តព្រៃវែង និងខេត្តត្បូងឃ្មុំ។

ក្នុងឱកាសនោះ សម្តេចបានថ្លែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ និងក្តីនឹករលឹកចំពោះបងប្អូន សមាជិក សមាជិកាក្រុមប្រឹក្សាឃុំ ស្រុកនៃខេត្តទាំងបី និងបានគូសបញ្ជាក់ថា ឆ្នាំ២០១៩កន្លងទៅ រាជរដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ធ្វើឲ្យសម្រេចជោគជ័យធំធេងលើគ្រប់វិស័យ ទាំងនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់ និងសេដ្ឋកិច្ចសង្គម។ល។ ជាក់ស្តែង សេដ្ឋកិច្ចមានកំណើន៧,១% ធលិតផលសរុបសម្រាប់ប្រជាជនម្នាក់ៗមានជាង១៦០០ដុល្លារអាមេរិក អត្រាភាពក្រីក្រស្ថិតក្នុងរង្វង់១០% ដែលធ្វើឲ្យជីវភាពរស់នៅរបស់ប្រជាជនមានលក្ខណៈល្អប្រសើរ។ ទន្ទឹមនឹងការអភិវឌ្ឍរួមរបស់ប្រទេស ក៏ដូចជាខេត្ត ស្រុក តំបន់ភូមិអន្លង់ជ្រៃនេះ ក៏មានការអភិវឌ្ឍ តាំងពីព្រៃរហូតមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ ជាពិសេសសម្រេចបាននូវការកសាងបាននូវ **"អាស្រមមរតកចក្រី"** ដែលទើបសូត្រមន្តប្រោះព្រំរួច ទុកជាមរតកប្រវត្តិសាស្ត្រសម្រាប់ប្រជាជនតំបន់នេះ។ ហើយសន្និបាតគណៈកម្មាធិការកណ្តាលលើកទី៤២ បានធ្វើការវាយតម្លៃអំពីសភាពការណ៍ឆ្នាំ២០២០ នឹងត្រូវបន្តជំរុញដំណើរការកែទម្រង់ស៊ីជម្រៅ និងមុតស្រួចសំដៅលើកកម្ពស់ជីវភាពរស់នៅ របស់ប្រជាជនប្រកបដោយក្តីសុខដុមរមនាលើមាគ៌ាឆ្ពោះទៅរកចក្ខុវិស័យកម្ពុជា ក្លាយជាប្រទេសមានចំណូលមធ្យមខ្ពស់ឆ្នាំ២០៣០ និងចំណូលខ្ពស់ឆ្នាំ២០៥០។

សម្តេចអគ្គមហាពញាចក្រី បានថ្លែងថា ប៉ុន្តែក្នុងឆមាសទី១នេះ ជំងឺកូវីដ-១៩បានបង្កផលប៉ះពាល់ទាំងសេដ្ឋកិច្ចនិងសង្គមដល់មនុស្សជាតិ និងបានធ្វើឲ្យពិភពលោក និងកម្ពុជាប្រឈមជាមួយរបត់ថ្មីមួយ។ តែទោះបីកម្ពុជាបានជួបបញ្ហាប្រឈមជាច្រើន បណ្តាលពីជំងឺនេះក្តី រាជរដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានគ្រប់គ្រង និងដោះស្រាយវិបត្តិនេះ បានទាន់ពេលវេលាតាមរយៈការដាក់ចេញនូវយុទ្ធសាស្ត្រ និងវិធានការច្បាស់លាស់ ម៉ឺងម៉ាត់ ហ្មត់ចត់ និងគ្រប់ជ្រុងជ្រោយ។ សម្តេចចក្រីបន្តថា រាជរដ្ឋាភិបាល បានដាក់ចេញកម្មវិធីជំនួយសង្គម ពិសេសការឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលកូវីដ១៩ កម្មករបាត់បង់ការងារ ស្ត្រីមានផ្ទៃពោះ និងក្មេងអាយុក្រោម២ឆ្នាំ និងវិធានការអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច ដែលក្នុងនោះការអនុគ្រោះពន្ធ ការអនុញ្ញាតមិនឱ្យបង់ប្រាក់វិភាគទានធានារ៉ាប់រងហានិភ័យការងារ និងថែទាំសុខភាព ការផ្តល់ភាពអនុគ្រោះលើលក្ខខណ្ឌឥណទាន និងការជួយឧបត្ថម្ភសហគ្រាសខ្នាតតូច និងមធ្យមផងដែរ។ រហូតមកដល់ពេលនេះ មានគ្រួសារពលរដ្ឋក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងកូវីដ១៩ មិនតិចជាង ៥៧ម៉ឺនគ្រួសារទេ បានទទួលបានប្រាក់ឧត្ថម្ភពីរដ្ឋ ក្នុងនោះរាជរដ្ឋាភិបាលបានបញ្ចេញថវិកាប្រមាណជាង ៥០លានដុល្លារ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលក៏កំពុងបន្តស្រាវជ្រាវកំណត់រកគ្រួសារក្រីក្របន្តទៀត ដោយមិនទុកឱ្យពលរដ្ឋណាម្នាក់ស្លាប់ដោយសារអត់បាយនោះឡើយ។

ក្នុងឱកាសនោះ **សម្តេចចក្រី ហោ ង សំរិន** បានជំរុញលើកទឹកចិត្តដល់មន្ត្រី និងអាជ្ញាធរមូលដ្ឋានទាំងអស់ បង្កលក្ខណសម្បត្តិដល់ប្រជាពលរដ្ឋក្នុងការពង្រីកមុខរបរកសិកម្ម ការបង្កបង្កើនផល និងចិញ្ចឹមសត្វ ដើម្បីលើកកម្ពស់ជីវភាពគ្រួសារ និងសេដ្ឋកិច្ចជាតិ។ សម្តេចចក្រីប្រធានរដ្ឋសភា ក៏បានជំរុញដល់អាជ្ញាធរមូលដ្ឋានលើកកម្ពស់ការផ្តល់សេវាសាធារណៈឲ្យបានកាន់តែល្អបន្ថែមទៀត ជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ដូចជាការងារអត្រានុកូលដ្ឋាន និងបន្តអនុវត្តឱ្យបានល្អនូវគោលនយោបាយ «ភូមិឃុំមានសុវត្ថិភាព» ជាពិសេសការចូលរួមអនុវត្ត និងផ្សព្វផ្សាយវិធានការការពារ ទប់ស្កាត់ ការរីករាលដាលជំងឺកូវីដ១៩ តាមការណែនាំរបស់ក្រសួងសុខាភិបាលឲ្យមានប្រសិទ្ធភាពខ្ពស់៕

សម្តេចក្រឡាហោម ៖ ស្ថិរភាពជាតិអាចសម្រេចទៅបាន អាស្រ័យសង្គមជាតិមានភាពយុត្តិធម៌

***សម្តេចក្រឡាហោម ស ខេង** អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុង ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់សមិទ្ធិផលមួយចំនួននៅស្រុកបាណន់*

នៅព្រឹកថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២០ **សម្តេចក្រឡាហោម ស ខេង** អនុប្រធានគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានខេត្តបាត់ដំបង បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុង ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ស្ពានដែកបេឡេត៏១ខ្សែប្រវែង១២៦ម៉ែត្រ និងអគារសិក្សាចំនួន០២ខ្នង នៅក្នុងសាលាបឋមសិក្សាស្វាយព្រៃ និងអនុវិទ្យាល័យកន្ទឺ១ ស្ថិតនៅស្រុកបាណន់ ខេត្តបាត់ដំបង ។ **សម្តេចក្រឡាហោម ស ខេង** បានសម្តែងការពេញចិត្ត និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះថ្នាក់ដឹកនាំក្រុមការងាររាជរដ្ឋាភិបាល និងក្រុមការងារគណបក្សដែលបានកសាងសមិទ្ធផលគ្រប់វិស័យជូនប្រជាពលរដ្ឋ និងបានឆ្លើយតបទាន់ពេលវេលារាល់សេចក្តីត្រូវការរបស់ប្រជាជន។

សម្តេចក្រឡាហោមបានរំលឹកថា របបពីអតីតកាល គឺនៅរៀងរាល់ថ្ងៃសៅរ៍ឬអាទិត្យថ្នាក់ដឹកនាំ និងមន្ត្រីជាន់ខ្ពស់ភាគច្រើនប្រើពេលវេលាឈប់សំរាកនេះដើម្បីធ្វើដំណើរកំសាន្ត រាំលេងសប្បាយ ប៉ុន្តែរាជរដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជា ចាប់តាំងពីពេលមុនរហូតមកដល់ពេលនេះមានវប្បធម៌ចាត់តាំង និងបែងចែកមន្ត្រីក្រុមការងារយកពេលវេលានេះ ឆ្លៀតចុះមូលដ្ឋាន ស្វែងយល់ពីសុខទុក្ខ និងតម្រូវការប្រជាពលរដ្ឋ ដើម្បីដោះស្រាយឱ្យទាន់ពេលវេលា។ សម្តេចក្រឡាហោមបានថ្លែងថា ការចុះមូលដ្ឋាន ការចុះជួបប្រជាពលរដ្ឋ ការរៀបចំវេទិកាសាធារណៈជាទៀងទាត់ និងយ៉ាងសកម្ម បានធ្វើឱ្យរាជរដ្ឋាភិបាល និងគណបក្សប្រជាជនកម្ពុជា ដាក់ចេញគោលនយោបាយ កម្មវិធីនយោបាយព្រមទាំងយុទ្ធសាស្ត្រនានាត្រូវនឹងសភាពការណ៍ជាក់ស្តែង ត្រូវនឹងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋ ធ្វើឱ្យប្រជាពលរដ្ឋមានការពេញចិត្តហើយចូលរួមគាំទ្រក្នុងដំណើរការអភិវឌ្ឍន៍ជាតិ នាំឱ្យជីវភាពពួកគាត់កាន់តែមានភាពប្រសើរពីមួយថ្ងៃទៅមួយថ្ងៃ។

សម្តេចក្រឡាហោមគូសបញ្ជាក់ថា រហូតមកដល់ពេលនេះ រាជរដ្ឋាភិបាលបាន និងកំពុងគ្រប់គ្រងជំងឺកូវីដ១៩យ៉ាងល្អ ដ្បិតពេលនេះកម្ពុជាមិនទាន់មានការឆ្លងជំងឺនេះជាលក្ខណៈសហគមន៍ដូចប្រទេសមួយចំនួននោះឡើយ។ ការរកឃើញករណីឆ្លងថ្មី គឺមានតែអ្នកដំណើរមកពីក្រៅប្រទេសប៉ុណ្ណោះ ខណៈពលករខ្មែរជាង១០ម៉ឺននាក់ ដែលធ្វើដំណើរឆ្លងដែនពីប្រទេសថៃនាអំឡុងពេលកូវីដ-១៩នេះ ក៏ត្រូវបានអាជ្ញាធរគ្រប់គ្រងបាន និងមិនមានការឆ្លងជំងឺដែរ។

សម្តេចក្រឡាហោម ស ខេង បានបន្តគូសបញ្ជាក់អំពីសុខសន្តិភាព និងស្ថេរភាពនយោបាយដោយសម្តេចបានរំលឹកឡើងវិញអំពីស្ថានភាពដ៏លំបាកវេទនាក្នុងភ្លើងសង្គ្រាម ការបញ្ចប់សង្គ្រាម រហូតកសាង និងរក្សាបានសុខសន្តិភាពដូចសព្វថ្ងៃ ខណៈបណ្តាប្រទេសមួយចំនួននៅបន្តស្ថិតក្នុងភ្លើងសង្គ្រាម នៅឡើយ ធ្វើឱ្យប្រពលរដ្ឋជាជនស៊ីវិលរងគ្រោះស្លាប់របួសព្រាត់ប្រាស់ជារៀងរាល់ថ្ងៃ។ សម្តេចក្រឡាហោមបានបន្តថាស្ថេរភាពជាតិ អាចសម្រេចទៅបានអាស្រ័យលើសង្គមមានភាពយុត្តិធម៌ គ្មានការរំលោភបំពានសិទ្ធិ សេរីភាព និងផលប្រយោជន៍ប្រជាពលរដ្ឋ។

សម្តេចក្រឡាហោមក៏បានជំរុញឱ្យមានការខិតខំដោះស្រាយទំនាស់ក្នុងមូលដ្ឋាន តាមរយៈគ្រប់យន្តការ និងមធ្យោបាយ ដោយប្រកាន់ខ្ជាប់នូវភាពគ្រប់ជ្រុងជ្រោយ និងយុត្តិធម៌។ សម្តេចក្រឡាហោមក៏បានបង្ហាញការចាប់អារម្មណ៍ចំពោះវិធីសាស្ត្រនៃការសម្របសម្រួល និងដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការរបស់អភិបាលខេត្តពោធិ៍សាត់។ សម្តេចក្រឡាហោមបានបន្តគូសបញ្ជាក់អំពីការដាក់ចេញយុទ្ធនាការបង្ក្រាបគ្រឿងញៀន និងណែនាំឱ្យសមត្ថកិច្ចព្រមទាំងប្រជាពលរដ្ឋទប់ស្កាត់កុំឱ្យគ្រឿងញៀនហូរចូលក្នុងសហគមន៍ និងបន្តអនុវត្តគោលនយោបាយភូមិឃុំមានសុវត្ថិភាព។

ជាមួយគ្នានេះ **សម្តេចក្រឡាហោម ស ខេង** បានបន្តថាគ្រោះថ្នាក់ចរាចរណ៍នៅតែបន្តសម្លាប់អាយុជីវិតប្រជាពលរដ្ឋធ្វើឱ្យបាក់បែកបាត់បង់សមាជិកគ្រួសារ ធ្វើឱ្យពលរដ្ឋរងរបួស មានពិការភាពខូចខាតទ្រព្យសម្បត្តិឯកជន និងសាធារណៈជារៀងរាល់ថ្ងៃ ការរឹតបន្តឹងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកបានធ្វើឱ្យអត្រាគ្រោះថ្នាក់ ចរាចរណ៍មានការថយចុះប្រមាណ៥០ភាគរយ និងបានអំពាវនាវឱ្យប្រជាពលរដ្ឋបង្កើនស្មារតីគោរពច្បាប់ចរាចរណ៍ឱ្យបានខ្ជាប់ខ្ជួន និងសូមឱ្យសមត្ថកិច្ចបង្កើនការរឹតបន្តឹងច្បាប់ដោយគ្មានការលើកលែង៕

សម្តេចវិបុលសេនាភក្តី ក្រើនរំលឹកមន្ត្រីអនុវត្ត ឲ្យបានល្អតួនាទីភារកិច្ចរបស់ខ្លួន

*សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** អញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខមន្ត្រី និងអាជ្ញាធរសង្កាត់ ស្នឹងមានជ័យទី២*

នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២០ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** អនុប្រធានគណបក្ស ប្រធានគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមការងារចុះជួយរាជធានីភ្នំពេញ បានអញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខមន្ត្រី និងអាជ្ញាធរសង្កាត់ ស្នឹងមានជ័យទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ក្នុងឱកាសនោះ **សម្តេចភក្តី សាយ ឈុំ** បានសម្តែងនូវក្តីសប្បាយរីករាយ និងវាយតម្លៃខ្ពស់ចំពោះការអនុវត្តតួនាទីភារកិច្ចរបស់អាជ្ញាធរសង្កាត់ និងមន្ត្រីមូលដ្ឋានក្នុងការបម្រើសេវាសាធារណៈ ជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព ។

សម្តេចភក្តី សាយ ឈុំ បានគូសបញ្ជាក់ពីសភាពការណ៍រីកចម្រើនការអភិវឌ្ឍ និងសមិទ្ធផលធំៗថ្មីៗរបស់ប្រទេសជាតិជូនដល់មន្ត្រីអាជ្ញាធរសង្កាត់ស្នឹងមានជ័យ។ ព្រមជាមួយគ្នានេះ **សម្តេចភក្តី សាយ ឈុំ** បានផ្តល់នូវអនុសាសន៍សំខាន់ៗមួយចំនួនមានជាអាទិ៍ ត្រូវខិតខំអនុវត្តឲ្យកាន់តែល្អតាមតួនាទីភារកិច្ច ជាពិសេសគប្បីយកចិត្តទុកដាក់ចំពោះការអនុវត្តគោលនយោបាយភូមិ សង្កាត់មានសុវត្ថិភាពដោយផ្តោតលើការរក្សាសន្តិសុខសណ្តាប់សាធារណៈក្នុងមូលដ្ឋាន ចាត់វិធានការបង្ក្រាប ទប់ស្កាត់បទល្មើសនានា និងបញ្ហាគ្រឿងញៀន។ ត្រូវផ្តល់សេវាសាធារណៈបម្រើប្រជាជនដោយគ្មានការរើសអើង និងប្រកបដោយគុណភាព តម្លាភាព ប្រសិទ្ធភាព និងឆាប់រហ័ស។ បង្កើនស្មារតីទទួលខុសត្រូវខ្ពស់បញ្ហារក្សាការពារធនធានទ្រព្យសម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធដែលមាននៅក្នុងមូលដ្ឋានសង្កាត់របស់យើង។ **សម្តេចភក្តី សាយ ឈុំ** ក៏បានក្រើនរំឭកដល់មន្ត្រី កងកម្លាំងមានសមត្ថកិច្ច ត្រូវបន្តយកចិត្តទុកដាក់អប់រំ និងផ្សព្វផ្សាយដល់ប្រជាជន ឲ្យខិតខំអនុវត្តរាល់វិធានការដែលរាជរដ្ឋាភិបាល និងក្រសួងជំនាញបានណែនាំជាក់ស្តែងគឺៈអនាម័យខ្លួនប្រាណឲ្យបានល្អ និងជាប្រចាំ ដោយប្រើសាប៊ូ ទឹកអាល់កុល អនុវត្តគម្លាតសុវត្ថិភាពសង្គម និងបុគ្គល ប្រើម៉ាស់ ការពារក្នុងពេលធ្វើដំណើរតាមមធ្យោបាយសាធារណៈ ក្នុងពេលធ្វើការងារ ឬក្នុងទីសាធារណៈដែលមានមនុស្សច្រើន។ ក្នុងករណីមានអាការៈមិនស្រួលខ្លួនត្រូវប្រញាប់ប្រញាល់ទៅមន្ទីរពេទ្យ ជួបគ្រូពេទ្យជំនាញឲ្យពិនិត្យព្យាបាល ឬទាក់ទងផ្តល់ព័ត៌មានទៅខ្សែទូរស័ព្ទ១១៥ ដែលប្រចាំការ ផ្តល់ការពិគ្រោះផ្តល់យោបល់ពាក់ព័ន្ធជម្ងឺរាតត្បាតកូវីដ-១៩ នោះ៕

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២០ **ឯកឧត្តមកិត្តិនីតិ-កោសលបណ្ឌិត ឌួន ញ៉ិល** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អនុប្រធានទី១ រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមការងារគណបក្សថ្នាក់កណ្តាលចុះមូលដ្ឋានខេត្តកំពង់ធំ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ដឹកនាំកិច្ចប្រជុំជាមួយគណៈអចិន្ត្រៃយ៍គណៈកម្មាធិការគណបក្សខេត្ត និងអស់លោកជាប្រធានគណបក្សស្រុក-ក្រុង ទាំងអស់ក្នុងខេត្តកំពង់ធំ នៅភូមិគ្រឹះ ឯកឧត្តម ក្នុងភូមិត្រពាំងស្វាយ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ឯកឧត្តមបានណែនាំដល់អង្គប្រជុំយកចិត្តទុកដាក់ត្រៀមលក្ខណៈឆ្ពោះទៅកាន់ការបោះឆ្នោត ជ្រើសរើស ក្រុមប្រឹក្សាឃុំ-សង្កាត់ នាពេលខាងមុខ។

ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** សមាជិកាគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច បានអញ្ជើញជាអធិបតីក្នុងពិធីជួបសំណេះសំណាល និងចែកអំណោយជួយដល់ពលរដ្ឋក្រីក្រចំនួន ១១៦គ្រួសារនៅក្នុងឃុំត្រពាំងក្រញូង ស្រុកត្រាំកក់ ខេត្តតាកែវ ។

ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ឆ្នាំង បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរដ្ឋបាលស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ដើម្បីពិនិត្យសភាពការណ៍ទូទៅក្នុងស្រុក។ ឯកឧត្តមបណ្ឌិតសភាចារ្យក៏បាននាំយកអំណោយមួយចំនួនរួមមាន៖ អង្ករ មី ទឹកត្រី ទឹកស៊ីអ៊ីវ ម៉ាស សាប៊ូ អាល់កុល ប្រេងឆា ជូនដល់រដ្ឋបាលស្រុកសម្រាប់ចែកជូនគ្រួសារក្រីក្ររងផលប៉ះពាល់ជំងឺកូវីដ-១៩ និងថ្នាំងរូបភាពអំពីរបៀបលាងសម្អាតដៃ និងថ្នាំងរូបភាពអប់រំអំពីវិធីកាត់បន្ថយហានិភ័យពីការឆ្លងជំងឺកូវីដ១៩ផងដែរ។

ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០ **លោកជំទាវកិត្តិសង្គហបណ្ឌិត ឃួន សុដារី** សមាជិកាគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាអនុប្រធានទី២នៃរដ្ឋសភា និងជាប្រធានក្រុមសភាជាតិកម្ពុជានៃអ្នកនយោបាយសភាស្ត្រី បានអញ្ជើញជាគណៈអធិបតីក្នុងពិធីប្រគល់ ទទួលប្រឡាយ ១ខ្សែជូនដល់បងប្អូនប្រជាពលរដ្ឋ ៥៥០គ្រួសារអាស្រ័យផលនៅក្នុងភូមិអំពិលទឹក ឃុំកំពង់ភ្នំ ស្រុកលើកដែក ខេត្តកណ្តាល។ ប្រឡាយ ១ខ្សែដែលត្រូវជីកស្តារឡើងវិញមានប្រវែង ២.២០០ម៉ែត្រ ដែលមានមាត់លើប្រវែង១០ម៉ែត្រ បាតក្រោមប្រវែង៧ម៉ែត្រ និងជម្រៅ ២,៥០ម៉ែត្រ គិតជាអាចម៌ដីស្មើនឹង ២៧.៦០៣,៧៥ម៉ែត្រគីប ចំណាយអស់ថវិកាសរុបចំនួន ៥៥.២០៧,៥០$។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២០ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជាប្រធានក្រុមការងារគណបក្សចុះជួយខេត្តកែប បានអញ្ជើញជាអធិបតីភាពដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារគណបក្សខេត្តកែប និងលើកទិសដៅភារកិច្ចការងារខែសីហា ឆ្នាំ ២០២០ នៅទីស្នាក់ការគណបក្សខេត្តកែប។

ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម **ង្រុំ សុខា** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះជួយស្រុកបាភ្នំ បានអញ្ជើញជួបសំណេះសំណាលជាមួយបងប្អូនចំណាកស្រុក ដែលបានមកលេងស្រុកកំណើតក្នុងឱកាសឈប់សម្រាកពីការងារដែលរាជរដ្ឋាភិបាលបានសងជូនថ្ងៃចូលឆ្នាំខ្មែរ នៅស្រុកបាភ្នំ ខេត្តព្រៃវែង ។

ថ្ងៃទី០២ខែសីហាឆ្នាំ២០២០ឯកឧត្តម**ច័ន្ទ សារុន**តំណាងរាស្ត្រមណ្ឌលខេត្តតាកែវ បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធស្រះទឹកទំហំ (៣៥មx៤៥មx ៥,៥ម) នៅភូមិតាតៃ ឃុំញៀងញ៉ង ស្រុកត្រាំកក់ដែលជាអំណោយរបស់ឯកឧត្តមផ្ទាល់។ក្នុងឱកាសនោះឯកឧត្តមបាននាំយកអំណោយចែកជូនប្រជាពលរដ្ឋចំនួន ២៥០គ្រួសារ ក្នុង១គ្រួសារទទួលបានអង្ករ២៥គ.ក ក្រម៉ា១ សាប៊ូដុះខ្លួន១ដុំ ប្រេងកូឡា១ប្រអប់ ដើមក្រូចឆ្មារ២ដើម និងថវិកា១៥.០០០រៀល និងឧបត្ថម្ភកម្មវិធី ចំនួន៦៥០.០០០រៀល ឧបត្ថម្ភប្រជាការពារ និងប៉ូលីសចំនួន១១នាក់ ទទួលបានថវិកា១០.០០០រៀល/ម្នាក់ នារី ខ្សែបូ៥នាក់ទទួលបានថវិកា២០.០០០ រៀលនិងសារុង១/ម្នាក់, មន្ត្រីសុខាភិបាល៥នាក់ទទួលបានសារុង១ /ម្នាក់។

ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម **ភេង សាខុន** សមាជិកគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអញ្ជើញជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋ និងនាំយកកូនឈើហូបផ្លែ (ដូង ខ្នុរ មាន ឫស្សី ស្វាយ ត្របែក ស្វាយចន្ទី និងស្តៅ) ពូជមាន់ និងចំណីមាន់ មកចែកជូនប្រជាពលរដ្ឋចំនួន ២០០គ្រួសារ សម្រាប់អនុវត្តន៍ប្រព័ន្ធកសិកម្មចំរុះ នៅភូមិសេរីវង្ស ឃុំពាម ស្រុកសាមគ្គីមានជ័យ។

ថ្ងៃទី០៧ខែសីហាឆ្នាំ២០២០ឯកឧត្តម**ម៉ុម ឌីមហ៊ុយ**សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មការទី៧ នៃព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយ ឯកឧត្តម **អ៊ុន ចាន់ដា** អភិបាលនៃគណៈអភិបាលខេត្តនិងឯកឧត្តមខ្លួតផនក្រុមប្រឹក្សាខេត្តកំពង់ចាម ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម លោកជំទាវ អភិបាលរងខេត្ត លោកប្រធានមន្ទីរពាក់ព័ន្ធ និងមន្ត្រីពាក់ព័ន្ធ ដើម្បីស្វែងយល់ពីការវិវត្តរីកចម្រើនថ្មី បញ្ហាប្រឈម និងវិធានការនានារបស់អាជ្ញាធរខេត្ត និងការងារពាក់ព័ន្ធវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការទី៧ ។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម **ម៉ម ប៊ុនឆាង** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មការអង្កេតបោសសម្អាត និងប្រឆាំងអំពើពុករលួយនៃព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូគណៈកម្មការ ចុះជួបពិភាក្សាការងារជាមួយ ឯកឧត្តម **គង់ សោភ័ណ្ឌ** អភិបាលនៃគណៈអភិបាលខេត្តកណ្តាល ដើម្បីសិក្សាឈ្វេងយល់អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអភិវឌ្ឍមូលដ្ឋាន ការអនុវត្តច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ការអនុគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងការគ្រប់គ្រងច្រកព្រំដែនអន្តរជាតិក្អមសំណ ស្ថិតនៅឃុំក្អមសំណ ស្រុកលើកដែក ខេត្តកណ្តាល ។

ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម **ប៊ូ ឆ្នាំ** តំណាងរាស្ត្រមណ្ឌលខេត្តរតនគិរី និងជាសមាជិកគណៈកម្មការមហាផ្ទៃ ការពារជាតិ និងមុខងារសាធារណៈនៃរដ្ឋសភា ព្រមទាំងលោកជំទាវ បានអញ្ជើញចូលរួមក្នុងពិធីដង្ហែព្រះពុទ្ធរូបអង្គស្តាន់ ទៅតម្កល់នៅវត្តរស្មីសាមគ្គីរតនារាម (ហៅវត្តថ្មី) ដើម្បីឲ្យពុទ្ធបរិស័ទទូទៅគោរពបូជា។ ពិធីនេះក៏មានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ ជាថ្នាក់ដឹកនាំខេត្ត សមាជិកក្រុមប្រឹក្សាខេត្ត ព្រះសង្ឃ លោកអាចារ្យ គណកម្មការចំណុះជើងវត្ត ពុទ្ធបរិស័ទជិតឆ្ងាយ សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ ព្រមទាំងមន្ត្រីរាជការគ្រប់ស្ថាប័ន ស្ថិតនៅភូមិថ្មី សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី។

ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម **ជាម ប៉េអា** តំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែង និងជាសមាជិកគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ ឃោសនាការ និងព័ត៌មាន នៃរដ្ឋសភា បានដឹកនាំក្រុមការងារឃុំ នៃស្រុកស៊ីធរកណ្តាល រៀបចំកម្មវិធីជួបសំណេះសំណាលជាមួយពលករចំណាកស្រុកសរុប ១៩កន្លែង ដែលមានពលករ កម្មករចូលរួមសរុបមានចំនួន ៧២៦នាក់ ក្នុងនោះស្រី ៤១៦នាក់ ដើម្បីប្រាស្រ័យទំនាក់ទំនងរឹងមាំក្រោមម្លប់សន្តិភាព និងពង្រឹងភាពជឿទុកចិត្តរបស់បងប្អូនចំណាកស្រុកមកលើការដឹកនាំរបស់រាជរដ្ឋាភិបាល ដែលមានសម្តេចតេជោជាប្រមុខដឹកនាំដ៏ឆ្នើម និងគិតគូរគ្រប់ជ្រុងជ្រោយចំពោះប្រជាជន។

ក្នុងខែសីហា ឆ្នាំ២០២០ ឯកឧត្តម **ម៉ុម សារឿន** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង បានដឹកនាំមន្ត្រីជំនាញពាក់ពន្ធ័ អញ្ជើញបានចុះត្រួតពិនិត្យវឌ្ឍនភាព លើកិច្ចការស្ថាបនាផ្លូវបេតុងសរសៃដែក និងសមិទ្ធផលនានា ក្នុងក្រុងស្ទឹងត្រែង ។ ឯកឧត្តមបានជំរុញមន្ត្រីជំនាញពន្លឿនការស្ថាបនាសមិទ្ធផលនានាស្របតាមគម្រោងអភិវឌ្ឍន៍របស់ខេត្ត ដែលបានដាក់ចេញសម្រាប់ឆ្នាំ ២០២០ និងបានសំណូមពរដល់ប្រជាពលរដ្ឋ ដែលកំពុងរស់នៅ តាមបណ្តោយផ្លូវ បេតុង ជួយថែរក្សា និងបង្កលក្ខណៈងាយស្រួលដល់កិច្ចដំណើរការ សាងសង់ស្ថាបនា សម្រេចបានជោគជ័យតាមផែនការបានដាក់ចេញ ។

ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម **ភួង ចំរើន** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ និងលោកជំទាវ បានអញ្ជើញចុះសាកសួរសុខទុក្ខ និងនាំយកអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកត្តិព្រឹទ្ធបណ្ឌិត ជូនគ្រួសារអតីតយុទ្ធជន ចំនួន៤គ្រួសារ នៅស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម **សុខ លូ** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ និងជាប្រធានគណៈកម្មាធិការគណបក្សប្រជាជន កម្ពុជាខេត្តកំពង់ធំ អញ្ជើញជាអធិតបតីក្នុងពិធីប្រកាសបញ្ចូលសមាជិកថ្មីគណបក្សប្រជាជកម្ពុជា ចំនួន ២០០នាក់ នៅឃុំសណ្តាន់ ស្រុកសណ្តាន់ ខេត្តកំពង់ធំ។

ថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម **ជាវ តាយ** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាលខេត្តកំពត បានអញ្ជើញចុះពិនិត្យស្ថានភាពជំនន់ទឹកភ្លៀង ក្នុងក្រុងកំពត និងស្រុកទឹកឈូ។ ឯកឧត្តមក៏បានចុះពិនិត្យទីតាំងប្រឡាយព្រែកជីកភូមិតាអេង និងប្រឡាយភូមិត្រពាំងធំ ដែលជាប្រភពសំខាន់នៃការរំដោះទឹកចេញពីសង្កាត់ក្រាំងអំពិលសង្កាត់កំពង់កណ្តាលនិងឃុំត្រពាំងធំហូរទៅកាន់ព្រែកកំពង់បាយ។

ថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម **អ៊ុំ រាត្រី** អភិបាលនៃគណៈអភិបាលខេត្តបន្ទាយ បានអញ្ជើញចុះពិនិត្យមើលសកម្មភាពស្ថាបនាផ្លូវក្រាលកៅស៊ូ ជាជំហានដំបូងក្នុងឆ្នាំ២០២០ ដែលមានប្រវែង ៣០០០ ម៉ែត្រ ដោយប្រើប្រាស់គម្រោងថវិកាអភិវឌ្ឍន៍ខេត្ត ចាប់ពីចំណុចចុងផ្លូវបេតុង ស្ថិតក្នុងឃុំឫស្សីក្រោក ទៅដល់ភូមិព្រះស្រែ ឃុំតាឡំ ខេត្តបន្ទាយមានជ័យ។

ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម **ឈួរ ច័ន្ទឌឿន** អភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងឯកឧត្តម **ឡូ ឈុនឡៃ** ប្រធានក្រុមប្រឹក្សាខេត្តកំពង់ឆ្នាំង បានអញ្ជើញជាអធិបតីភាពក្នុងកិច្ចប្រជុំផ្សព្វផ្សាយ និងពង្រឹងវិធានការ ការពារ សន្តិសុខសណ្តាប់ធ្នាប់ និងការទប់ស្កាត់ការរីករាលដាលជំងឺកូវីដ១៩ ក្នុងឱកាសមន្ត្រីរាជការ កម្មករឈប់សម្រាក ពីការងារ ដល់អភិបាលរងខេត្ត នាយករដ្ឋបាលសាលាខេត្ត ប្រធាន អនុប្រធានមន្ទីរជុំវិញខេត្តកងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទ អភិបាលក្រុង ស្រុក អធិការស្រុក នាយប៉ុស្តិ៍ នគរបាលរដ្ឋបាល មេឃុំចៅសង្កាត់ទូទាំងខេត្តផងដែរ នៅសាលាខេត្តកំពង់ឆ្នាំង។

ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម **ចាន់ ស៊ីណាត** អនុរដ្ឋលេខាធិការនៃក្រសួងធនធានទឹក និងឧតុនិយម និងជានាយក PMU-ADB and WB MOWRAM បានអញ្ជើញចុះទៅធ្វើការត្រួតពិនិត្យ ការជីកប្រព័ន្ធប្រឡាយជើងភ្នែប នៅក្នុងតំបន់ប្រព័ន្ធធារាសាស្ត្រក្រសាំង ក្នុងស្រុកសៀមបូក ខេត្តស្ទឹងត្រែង។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

ថ្ងៃទី០១ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល និងជាប្រធានយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានដឹកនាំកិច្ចប្រជុំយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ដើម្បីពិនិត្យវឌ្ឍនភាពការងាររបស់យុវជនគណបក្សថ្នាក់កណ្តាល និងពិសាអាហារសាមគ្គី ដែលមានការចូលរួមពីអនុប្រធានគណៈអចិន្ត្រៃយ៍ និងសមាជិក សមាជិកាយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ចំនួន ១៣១នាក់ នៅទីស្នាក់ការកណ្តាលគណបក្សប្រជាជនកម្ពុជា (**វិមាន ៧មករា**)។

ថ្ងៃទី០៥ សីហា ឆ្នាំ២០២០ ឯកឧត្តម **ហោ សួរ** សមាជិកគណៈកម្មាធិការកណ្តាល ជាសមាជិកគណៈអចិន្ត្រៃយ៍យុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានក្រុមការងារៀបចំអង្គការចាត់តាំងយុវជនគណបក្សនៅសាធារណៈរដ្ឋកូរ៉េ ជប៉ុន និងម៉ាឡេស៊ី បានរៀបចំពិធីជួបជុំសំណេះសំណាលជាមួយប្អូនៗនិស្សិតដែលនឹងត្រូវបន្តការសិក្សានៅប្រទេសជប៉ុន របស់ក្រុមការងាររៀបចំអង្គការចាត់តាំងយុវជនគណបក្សនៅសាធារណៈ រដ្ឋកូរ៉េ ជប៉ុន និងម៉ាឡេស៊ី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល និងជាប្រធានយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ដែលមាននិស្សិតអាហារូបករណ៍ចូលរួមចំនួន ១២១នាក់ នៅសណ្ឋាគារភ្នំពេញ។

ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម **គីម សន្តិភាព** សមាជិកគណៈកម្មាធិការកណ្តាលជាសមាជិកគណៈអចិន្ត្រៃយ៍យុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានផ្នែកក្រៅប្រទេស នៃយុវជនគណបក្ស ថ្នាក់កណ្តាល បានបើកកិច្ចប្រជុំផ្សព្វផ្សាយការបែងចែកភារកិច្ច និងការទទួលខុសត្រូវដល់ថ្នាក់ដឹកនាំ និងក្រុមជំនួយការតាមផែន ព្រមទាំងរៀបចំផែនការសកម្មភាពការងាររបស់ខ្លួន ក្រោយពីកិច្ចប្រជុំផ្នែកក្រៅប្រទេសក៏បានអាហារជួបជុំគ្នាដើម្បីពង្រឹងកិច្ចសហការនិងសាមគ្គីភាពនៃផ្នែកក្រៅប្រទេសយុវជនគណបក្សថ្នាក់កណ្តាលផងដែរដោយមានការចូលរួមពីអនុប្រធាន សមាជិក សមាជិកា និងក្រុមជំនួយការ សរុបប្រមាណ១៤០រូប។

ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ ផ្នែកក្រៅប្រព័ន្ធ នៃយុវជនគណបក្សថ្នាក់កណ្តាល ដឹកនាំដោយ លោក **ហោ សេរីវុឌ្ឍន៍** សមាជិកគណៈអចិន្ត្រៃយ៍យុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានផ្នែកក្រៅប្រព័ន្ធ នៃយុវជនគណបក្សថ្នាក់កណ្តាលព្រមទាំងអនុប្រធាន និងសមាជិក បានចូលជួបសម្តែងការគួរសមជាមួយ ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** សមាជិកគណៈកម្មាធិការកណ្តាល និងជារដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីទទួលបានបទពិសោធន៍ និងអនុសាសន៍ណែនាំ ពាក់ព័ន្ធនឹងបច្ចុប្បន្នភាពវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជូនដល់សមាជិកផ្នែកក្រៅប្រព័ន្ធ នៃយុវជនគណបក្សថ្នាក់កណ្តាល ។

ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២០ ក្រុមការងារយុវជនគណបក្សរាជធានីភ្នំពេញ ដឹកនាំដោយ ឯកឧត្តម **ឆួន ឆាវ័ត្ន** សមាជិកគណៈកម្មាធិការកណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សរាជធានីភ្នំពេញ បានបើកកិច្ចប្រជុំពិភាក្សាអំពីវឌ្ឍនភាពការងារ និងផ្សព្វផ្សាយខ្លឹមសារ នៃកិច្ចប្រជុំរបស់យុវជនគណបក្សថ្នាក់កណ្តាល ដើម្បីបន្តពង្រឹងរចនាសម្ព័ន្ធអង្គការចាត់តាំង និងបន្តពង្រឹងសាមគ្គីភាពផ្ទៃក្នុងដោយស្វែងយល់ឱ្យបានច្បាស់អំពីរចនាសម្ព័ន្ធរបស់គណបក្ស និងប្រកាន់ខ្ជាប់នូវរបបការងាររបស់គណបក្ស នៅមន្ទីរគណបក្សរាជធានីភ្នំពេញ។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តបន្ទាយមានជ័យ ដឹកនាំដោយឯកឧត្តម **អ៊ុំ រាត្រី** សមាជិកយុវជនគណបក្សថ្នាក់កណ្តាល ជាប្រធានគណៈកម្មាធិការគណបក្សខេត្ត និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្តបន្ទាយ-មានជ័យ បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីកំណត់លេខ ២០៦ របស់គណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល និងសេចក្តីសម្រេចលេខ០៦៨/២០ របស់យុវជនគណបក្សថ្នាក់កណ្តាល ដោយមានការចូលរួមពីអស់លោក លោកស្រី អនុប្រធានក្រុមការងារ យុវជនគណបក្សខេត្ត ប្រធានគណៈកម្មាធិការគណបក្សស្រុក ក្រុង ប្រធានគណៈកម្មាធិការគណបក្សមូលដ្ឋាន មន្ទីរអង្គភាព និងប្រធាន-អនុប្រធានក្រុមផ្នែកចំណុះក្រុមការងារយុវជនគណបក្សខេត្តបន្ទាយមានជ័យ ។

ថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២០ ក្រុមការងារយុវជនគណបក្សខេត្តកំពត ដឹកនាំដោយ ឯកឧត្តម **ភុន សារពេជ្រ** សមាជិកយុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានយុវជនគណបក្សខេត្តកំពត បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តចុះជួយស្រុកឈូក និងប្រធាន អនុប្រធាន សមាជិកយុវជនគណបក្សប្រជាជនកម្ពុជា ស្រុក-ឃុំ ក្នុងស្រុកឈូក ខេត្តកំពត មានការចូលរួមពីក្រុមការងារយុវជនគណបក្សខេត្ត ប្រធានគណបក្សស្រុក អចិន្ត្រៃយ៍គណបក្សស្រុក ប្រធានគណបក្សមូលដ្ឋានឃុំ និងក្រុមការងារយុវជនគណបក្សស្រុក សរុបចំនួន ១៧៩នាក់។

ថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០ ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តត្បូងឃ្មុំ ឯកឧត្តម **ហាក់ សុខមករា** សមាជិកយុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្តត្បូងឃ្មុំ បានដឹកនាំកិច្ចប្រជុំក្រុមការងារយុវជនគណបក្សខេត្តដើម្បីត្រួតពិនិត្យលទ្ធផលការងារប្រចាំខែ និងផ្សព្វផ្សាយសេចក្តីសម្រេច និងសេចក្តីណែនាំនានារបស់យុវជនគណបក្សថ្នាក់កណ្តាល ដែលមានសមាជិក សមាជិកាជាយុវជនចូលរួមចំនួនសរុប ៤០នាក់ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តត្បូងឃ្មុំ។

ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម **អ៊ុក ប្រជា** សមាជិកគណៈកម្មាធិការកណ្តាលជាសមាជិកយុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានកិត្តិយសក្រុមការងារយុវជនគណបក្សក្រសួងពាណិជ្ជកម្ម ឯកឧត្តម **រាជ ង៉ា** សមាជិកយុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សក្រសួងពាណិជ្ជកម្ម បានដឹកនាំកិច្ចប្រជុំក្រុមការងារយុវជនគណបក្សដើម្បីផ្សព្វផ្សាយអំពីលទ្ធផលនៃកិច្ចប្រជុំយុវជនគណបក្សប្រជាជនកម្ពុជា ថ្នាក់កណ្តាល និងត្រួតពិនិត្យរបាយការណ៍នៃការអនុវត្តការងារយុវជនគណបក្សក្រសួងរយៈពេល ៧ខែ ដើមឆ្នាំ២០២០ នៅក្រសួងពាណិជ្ជកម្ម។

ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០ ឯកឧត្តម **ហោ ណាន** សមាជិកគណៈកម្មាធិការកណ្តាលជាសមាជិកយុវជនគណបក្សថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សក្រសួងឧស្សាហកម្ម រ៉ែ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងវានុវត្តន៍ បានរៀបចំពិធីសំណេះសំណាលជាមួយយុវជន និងកសិករ ផ្សារភ្ជាប់ជាមួយវិស័យកសិកម្ម ដោយមានការចូលរួមពីយុវជន និងកសិករចំនួន ១៦៥នាក់ នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម។

សមិទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

❋ **៦ខែ ដើមឆ្នាំ ៖**

-កម្ពុជាបាននាំចេញម៉ាស និងសម្ភារៈពេទ្យទៅកាន់ទីផ្សារអន្តរជាតិ មានតម្លៃ ១៩១,៣លានដុល្លារអាមេរិក កើនឡើង ១៣០% ធៀបនឹងរយៈពេលដូចគ្នា កាលពីឆ្នាំមុន ដែលមានចំនួន ៨៣,៣៦លានដុល្លារ ។

-កម្ពុជាបាននាំចូលមធ្យោបាយធ្វើដំណើរពីក្រៅប្រទេស មានតម្លៃសរុបជិត ៦៣៥លានដុល្លារឬស្មើនឹង ៤១៤.៧២៥គ្រឿង ក្នុងនោះការនាំចូលរថយន្ត មានតម្លៃ ៥៣១,៦៤លានដុល្លារ ។ ចំណែកការនាំចូលម៉ូតូមានតម្លៃ ៩៩លានដុល្លារ ស្មើនឹង ១៨០.៥៩០ គ្រឿង និងកង់មានតម្លៃ ៤,៣៥លានដុល្លារ ស្មើនឹង ១៩២.៣៩៧ គ្រឿង ។

❋ **៧ខែ ដើមឆ្នាំ ៖**

- កម្ពុជាបាននាំចេញផលិតផលកសិកម្ម សរុបជាង ២,៦៨ លានតោន កើនខ្ពស់ជាងរយៈពេល ៧ខែ ឆ្នាំ២០១៩ ដែលមានត្រឹមតែជាង ២,៥៨លានតោន ។ ដំណាំសំខាន់ៗដែលត្រូវបាននាំចេញរួមមានអង្ករ ដំឡូងមី គ្រាប់ពោត ដូងប្រេង ថ្នាំជក់ ផ្លែស្វាយ គ្រាប់ស្វាយចន្ទីរ ចេកអំបុងលឿងស្រស់ និងម្រេច ជាដើម ។

- កម្ពុជានាំចេញអង្ករសម្រេចបាន ៤២៦.០៧៣តោន កើនឡើងប្រមាណ ១១៨.០៦០តោន ស្មើនឹង ៣៨,៣៣% បើធៀបទៅនឹងរយៈពេល៧ខែដើមឆ្នាំ២០១៩ ដែលមានចំនួន ៣០៨.០១៣តោន ។ ដោយឡែកសម្រាប់ខែកក្កដា ឆ្នាំ២០២០ ការនាំចេញអង្ករបាន ចំនួន ២៨.៤១៣តោនដែលក្នុងនេះមាន៖ អង្ករក្រអូបគ្រប់ប្រភេទ មានចំនួន ១៨.៥២៣តោន, អង្ករចម្រុះគ្រប់ប្រភេទមានចំនួន ៩.២០៨តោន, អង្ករចំហុយមានចំនួន ៦៨២ តោន និងអង្ករក្រហម មានចំនួន ២៨,៤១តោន ។ ប្រទេសដែលបានបញ្ជាទិញអង្ករពីកម្ពុជាក្នុងរយៈពេល ៧ខែនេះ មានចំនួន ៥៧ប្រទេស នៅក្នុងសហភាពអឺរ៉ុបមានប្រទេសចំនួន ២៤ ក្នុងចំណោម ២៨ ប្រទេស, ប្រទេសចិន, ប្រទេសសមាជិកអាស៊ានចំនួន៦ និងនៅទ្វីបដទៃទៀតចំនួន ២៦ ប្រទេស ។ ការនាំចេញអង្ករកម្ពុជាក្នុងរយៈពេល ៧ខែដើមឆ្នាំដូចគ្នាប្រៀបធៀបទៅនឹងឆ្នាំ ២០១៩ មានកំណើននៅគ្រប់គោលដៅនាំចេញទាំងអស់៖ សហភាពអឺរ៉ុបកើនចំនួន ៣៧,៧០%, ប្រទេសចិនកើនចំនួន ២៥,៩១%, បណ្តាប្រទេសសមាជិកអាស៊ានកើន ចំនួន ៤៤,០៣%, និងគោលដៅដទៃទៀតបានកើនឡើងចំនួន ៧២,៤០% ។

-គិតត្រឹមថ្ងៃទី២៦ខែសីហាឆ្នាំ២០២០ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា CDC បានអនុម័តគម្រោងវិនិយោគចំនួន៧ ស្មើទុនវិនិយោគ សរុប ៧១,៧ លានដុល្លារអាមេរិក បង្កើតការងារធ្វើបានចំនួន៤០១៦កន្លែង។

- ភ្ញៀវទេសចរបរទេស ចំនួន ៣៨៩.៦៣០នាក់ បានទិញបណ្ណចូលទស្សនាមណីយដ្ឋានអង្គរដោយទទួលបានចំណូលសរុបប្រមាណ ១៨.១៧០.៩៩០ដុល្លារអាមេរិក ។ មានការថយជាង ៧២ភាគរយ បើធៀបនឹងឆ្នាំ២០១៩កន្លងទៅ ។ ដោយឡែក នៅក្នុងខែកក្កដា ឆ្នាំ២០២០នេះ មានអ្នកទិញបណ្ណចូលទស្សនាប្រមាណ ១.៧៩០ នាក់ រកចំណូលបាន ៧៨.៤៤០ដុល្លារអាមេរិក។

- ខែកក្កដា ឆ្នាំ២០២០នេះ ភ្ញៀវទេសចរផ្ទៃក្នុងដែលបានធ្វើដំណើរកម្សាន្តទូទាំងប្រទេសមានចំនួនសរុប ៧៤០.០២៨នាក់ កើនឡើង ១៥,២% ធៀបនឹងខែមិថុនា ក្នុងនោះភ្ញៀវជាតិមាន ៧២៣.២៣៨នាក់ កើនឡើង ១៥,៣៥% និងភ្ញៀវបរទេសមាន ១៦.៧៩០នាក់ កើនឡើង ៩,៩៩% ។ ជាការកត់សម្គាល់ ក្នុងខែ កក្កដា ចំនួនភ្ញៀវទេសចរផ្ទៃក្នុងបានកើនឡើងដល់ជាង ៧៤ម៉ឺន នាក់ គឺស្មើនឹងប្រមាណ ៧៥% នៃភ្ញៀវទេសចរផ្ទៃក្នុងមុនកូវីដ១៩ ដែលលើសពីបណ្តាខែកន្លងមក ដែលមានចំនួនត្រឹមតែ ៦០-៦៥% ដែលនេះបង្ហាញពី សញ្ញាកាន់តែវិជ្ជមាននៃចលនាទេសចរណ៍ផ្ទៃក្នុង ខណៈដែលអាជីវកម្មទេសចរណ៍កាន់តែច្រើន ពិសេសសណ្ឋាគារ និងសេវាស្នាក់នៅនានា បានបើកដំណើរការឡើងវិញជាហូរហែ ។

ដោយឡែកក្នុងខែសីហានេះ នៅពេលដែលរាជរដ្ឋាភិបាលអនុញ្ញាតមន្ត្រីរាជការ កម្មករ-កម្មការនី និយោគជិត បានឈប់សម្រាកជំនួសឲ្យពិធីបុណ្យចូលឆ្នាំភ្ញៀវទេសចរណ៍ក្នុងស្រុកមានជាង ១,៤សែននាក់ បានធ្វើដំណើរកម្សាន្តទូទាំងប្រទេស។ គោលដៅទេសចរណ៍សំខាន់ៗ ដែលប្រជាជនទៅលេងភាគច្រើនដូចជា ខេត្តសៀមរាប រតនគិរី មណ្ឌលគិរី កែប កំពត និងខេត្តព្រះសីហនុ។

- ចំណូលពន្ធ-អាករគ្រប់ប្រភេទដែលអគ្គនាយកដ្ឋានពន្ធដារ ប្រមូលបាន (តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ) មានចំនួន ៧៨៦.២៤ប៊ីលានរៀល (ប្រមាណជា ១៩៤.១៣ លានដុល្លារអាមេរិក) ស្មើនឹង ៦,៨១% នៃផែនការប្រចាំឆ្នាំ បើធៀបនឹងឆ្នាំ២០១៩ ថយចុះ ៧៥,៧១ ប៊ីលានរៀល (ប្រមាណជា ១៦.២២ លានដុល្លារអាមេរិក) ស្មើនឹង ៧,៧១% ។ ដោយឡែកចំណូលពន្ធ-អាករដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន (តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ) មានចំនួន ៧.៦០៥.៤៦ប៊ីលានរៀល (ប្រមាណជា ១.៨៧៧.៨៩លានដុល្លារអាមេរិក) ស្មើនឹង ៦៥,៨៩% នៃផែនការប្រចាំឆ្នាំ ធៀបនឹងរយៈពេលដូចគ្នា កើនឡើង ៦៧០.១១ប៊ីលានរៀល (ប្រមាណជា ១៦៥.៤៦លាន ដុល្លារអាមេរិក) ស្មើនឹង ៩,៦០% ។ គួរបញ្ជាក់ថារយៈពេល ៧ខែ ឆ្នាំ២០២០ ចំណូលពីប្រភេទពន្ធ ០២ នៅរក្សាកំណើនក្នុងនោះ អាករលើតម្លៃបន្ថែមកើនឡើង ៣,១៧% និងពន្ធលើប្រាក់ចំណូល កើនឡើង ២២,៧១% ធៀបនឹងរយៈពេលដូចគ្នា ។ សម្រាប់ ឆ្នាំ២០២០នេះ ដើម្បីធានានូវប្រសិទ្ធភាពក្នុងការអនុវត្តការប្រមូលចំណូលពន្ធបានគ្រប់តាមផែនការច្បាប់ ចំនួនប្រមាណ ១១.៥៤៣.៣១ប៊ីលានរៀល (ប្រមាណ ២.៨៨៥.៨៣លានដុល្លារអាមេរិក) ។

- ចំណូលពន្ធ-អាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន (តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ) មានចំនួន ៧.៦០៥.៤៦ប៊ីលានរៀល (ប្រមាណជា ១.៨៧៧.៨៩ លានដុល្លារអាមេរិក) ស្មើនឹង ៦៥,៨៩% នៃផែនការប្រចាំឆ្នាំ ធៀបនឹងចំណូលពន្ធ-អាករក្នុងរយៈពេលដូចគ្នា ឆ្នាំ២០១៩ ឃើញថាកើនឡើង ចំនួន ៦៧០.១១ប៊ីលានរៀល (ប្រមាណជា ១៦៥.៤៦លានដុល្លារអាមេរិក) ស្មើនឹង ៩,៦០% ។ គួរបញ្ជាក់ផងដែរថា ក្នុងរយៈពេល ០៧ខែ ឆ្នាំ២០២០ ចំណូលពីប្រភេទពន្ធ ០២ នៅរក្សាកំណើនក្នុងនោះ អាករលើតម្លៃបន្ថែមកើនឡើង ៣,១៧% និងពន្ធលើប្រាក់ចំណូលកើនឡើង ២២,៧១% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០១៩ ។ គួរបញ្ជាក់ថា ក្នុងខែកក្កដា ឆ្នាំ២០២០ ចំណូលពន្ធ-អាករគ្រប់ប្រភេទដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបាន (តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ) មានចំនួន ៧៨៦.២៤ប៊ីលានរៀល (ប្រមាណជា ១៩៤.១៣លានដុល្លារអាមេរិក) ស្មើនឹង ៦,៨១% នៃផែនការប្រចាំឆ្នាំ បើធៀបនឹងចំណូលពន្ធ-អាករប្រចាំខែកក្កដាឆ្នាំ២០១៩ ឃើញថាថយចុះចំនួន ៧៥.៧១ប៊ីលានរៀល (ប្រមាណជា ១៦.២២ លានដុល្លារអាមេរិក) ស្មើនឹង ៧,៧១% ៕

វិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ តែងតែសំខាន់ នៅពេលដែលប្រទេសជាតិកាន់តែរីកចម្រើន

*ឯកឧត្តមកិតិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** អញ្ជើញចុះពិនិត្យរោងចក្រប្រព្រឹត្តិកម្មទឹកស្អាតចំការមនក្នុងការ ផ្គត់ផ្គង់ទឹកក្នុងរាជធានីភ្នំពេញ*

រាជរដ្ឋាភិបាលបានសម្រេចប្តូរឈ្មោះក្រសួងឧស្សាហកម្ម និងសិប្បកម្មទៅជាក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីតម្រូវតាមភាពចាំបាច់របស់ប្រទេសជាតិ ក្នុងយុគសម័យឧស្សាហកម្មជំនាន់ទី៤ ដែលប្រទេសកម្ពុជាស្ថិតនៅក្នុងប្រទេសមួយក្នុងចំណោមប្រទេសទាំងឡាយជាង ២០០ នៅលើពិភពលោក ។ និន្នាការនៃបណ្តាប្រទេសនៅក្នុងតំបន់អាស៊ានដែលកម្ពុជាជាសមាជិកដែរនោះ បានធ្វើសមាហរណកម្មសេដ្ឋកិច្ចរួចហើយ នៅក្នុងឆ្នាំ២០១៥។ បច្ចុប្បន្នអាស៊ានទាំងមូល កំពុងជំរុញការអនុវត្តការងារបច្ចេកទេសវិទ្យាសាស្ត្រ និងនវានុវត្តន៍ និងខ្សែចង្វាក់ផលិតកម្ម ពិភពលោក ដែលសម័យនេះបច្ចេកវិទ្យាដើរលឿនឈានដល់ ៥Gហើយគឺដើរលឿន ១០០០ដងលើ 4G ។ មូលហេតុទាំងនេះ ហើយចាំបាច់ ដែលកម្ពុជាយើងត្រូវដើរឲ្យទាន់នៅសភាពការណ៍ពិភពលោកនេះដែរ។

ឯកឧត្តម **សុខ គង់** រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានឲ្យដឹងថា វិស័យឧស្សាហកម្មគឺជាវិស័យមួយកាន់តែសំខាន់នៅពេលដែលប្រទេសជាតិកាន់តែរីកចម្រើនទៅ ។ វិស័យនេះបានចូលរួមផ្តល់ប្រភពចំណូលទៅក្នុង GDP របស់ជាតិប្រមាណ ៣២ ភាគរយកាលពីឆ្នាំ ២០១៩ កន្លងទៅ ។

ឯកឧត្តមរដ្ឋលេខាធិការក៏បានឲ្យដឹងថានៅឆ្នាំ២០១៩ តម្លៃសរុបនៃបរិមាណផលិតមានរហូតដល់១៤.៨៧៥លានដុល្លារ កើន ១៣ ភាគរយបើប្រៀបធៀបឆ្នាំ២០១៨ ក្នុងបរិមាណផលិតនាំចេញមានប្រមាណជា ១១.១៨៥ លានដុល្លារអាមេរិកកើន ១៤ភាគរយនឹងតម្លៃផលិតលក់ក្នុងស្រុកសរុបមានប្រមាណ ៣.៦៩០លានដុល្លារអាមេរិកកើន១១ភាគរយ ។ រហូតមកដល់ពេលនេះ សហគ្រាសធុនតូចនិងមធ្យមមានជាង៥០ ម៉ឺន សហគ្រាស។ ការប្រើប្រាស់ ទឹកនៅក្នុងរាជធានីភ្នំពេញមានភាពរអាក់រអួល ដោយសារការកកើត ឡើងនូវអគារខ្ពស់ៗជាច្រើនលឿនពេកដោយ ពួកគេប្រើប្រាស់នូវម៉ាស៊ីនធំៗបូមទឹកយកទៅខាងលើ ដើម្បីប្រើប្រាស់តាមតម្រូវការរបស់ដែលធ្វើឲ្យអ្នកដែលប្រើប្រាស់ទឹកខាងក្រោយទុយោរបស់ពួកគេមានសម្ពាធទឹកប្រើប្រាស់ខ្សោយ។ ឯកឧត្តម **ហេង សុខគង់** បានអះអាងថា ទឹកស្អាតនៅរាជធានីភ្នំពេញ និងខេត្តសៀមរាប មានគុណភាពល្អដូចទឹកស្អាតនៅទីក្រុងតូក្យូប្រទេសជប៉ុន។ពេលដែលនិយាយពីទឹកស្អាតគឺជាទឹកដែលហូរកាត់ប្រព័ន្ធបំពង់ទុយោ មានប្រព្រឹត្តកម្មច្បាស់លាស់។ នៅកម្ពុជាបច្ចុប្បន្ន មានរោងចក្រផលិតទឹកស្អាតទូទាំងប្រទេសចំនួន២៩០ ក្នុងនោះ មានរដ្ឋាករស្វយ័តរាជធានី ភ្នំពេញ និងសៀមរាប រដ្ឋាករទឹករបស់រដ្ឋមានចំនួន១១ និងរដ្ឋាករទឹកឯកជនរបស់អង្គការ World Bank ។

ក្នុងការដាក់ដំណើរការសាកល្បង នៃគម្រោងពង្រីកសមត្ថភាពរោងចក្រ ប្រព្រឹត្តិកម្មទឹក ដែលមានសមត្ថភាពបូមទឹកល្អក់ពីទន្លេបាសាក់ចំនួន ៥៧ពាន់ម៉ែត្រត្រីគុណ ដោយមានសមត្ថភាពផលិតចំនួន៥២ ពាន់ ម៉ែត្រត្រីគុណ ក្នុងមួយថ្ងៃកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ឯកឧត្តមកិតិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានប្រសាសន៍ថា នេះ គឺជា សមិទ្ធិផល នៃការពង្រីកសមត្ថភាពរោងចក្រប្រព្រឹត្តិកម្មទឹកស្អាតចំការមនប្រកបដោយ ជោគជ័យ គឺជាជំនួយដ៏សំខាន់ ក្នុងការ ផ្គត់ផ្គង់ទឹកក្នុងរាជធានីភ្នំពេញ ជាពិសេសក្នុងខ័ណ្ឌចំការមន ដែលកំពុងមានការរីកដុះដាលយ៉ាងព្រោងព្រាតនូវ សំណង់អគារធំៗ ខ្ពស់ៗ។ ឯកឧត្តមបានឱ្យដឹងទៀតថា ការអភិវឌ្ឍន៍ទឹកស្អាតនេះ រដ្ឋាករទឹក ស្វយ័តក្រុងភ្នំពេញ ត្រូវខិតខំបន្ថែមទៀតក្នុងការពង្រីកសមត្ថភាពផលិតរបស់ខ្លួន ដើម្បីបំពេញតម្រូវការស្របពេល ដែលរាជធានីភ្នំពេញ បច្ចុប្បន្ន ត្រូវបានពង្រីកផ្ទៃក្រឡាធំ ជាងមុន ហើយការអភិវឌ្ឍសំណង់អគារធំៗ ក៏មានច្រើនប្រជាពលរដ្ឋក៏មាន ការកើនឡើងយ៉ាងឆាប់រហ័ស។ ដោយឡែកការពង្រីកទុន និងការទាក់ទាញវិនិយោគ ការស្វែងរកប្រភពជំនួយ និងដៃគូអភិវឌ្ឍន៍ គឺជាការងារ ចាំបាច់ដើម្បីដោះស្រាយការផ្គត់ផ្គង់ទឹកស្អាតឲ្យដល់ ទីប្រជុំជន និងឈានដល់តំបន់ជនបទ តាមចក្ខុវិស័យរបស់ប្រមុខថ្នាក់ដឹកនាំដែលចង់ឲ្យប្រជាពលរដ្ឋទទួលបានទឹកស្អាតប្រើប្រាស់ចៀសផុតនូវជម្ងឺដង្កាត់ផ្សេងៗដោយសាការប្រើប្រាស់ទឹកមិនស្អាត។

គម្រោងសាងសង់ពង្រីកសមត្ថភាពរោងចក្រប្រព្រឹត្តិកម្មទឹកស្អាតចំការមន គឺជាគម្រោងដែលបានកំណត់ ក្នុងផែនការមេទី៣ របស់អង្គភាពរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ក្រោមគម្រោងហិរញ្ញប្បទានរួមគ្នាដោយទីភ្នាក់ងារ បារាំង AFD និងថវិកាបដិភាគ ដោយអង្គភាពរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ មានទំហំទឹកប្រាក់ ចំនួនជាង១៥លានដុល្លារ និងជិត០៨លានអឺរ៉ូ ។ គម្រោងនេះបានចុះហត្ថលេខាជាផ្លូវការនៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០១៨ ដោយក្រុមហ៊ុន វ៉ាំង ស៊ី (VINCI) ជាអ្នកទទួលខុសត្រូវក្នុងការសាងសង់ និងស្ថិតក្រោមការ ត្រួតពិនិត្យដោយទីប្រឹក្សាបច្ចេកទេស ក្រុមហ៊ុន សាហ្វេរ (Safage) និងបានចាប់ផ្តើម

*ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** ថ្លែងថា នៅក្នុងអាណត្តិទី៦ នេះ អង្គភាពរដ្ឋាករទឹក នឹងបន្តពង្រីកបណ្តាញទឹកស្អាតទៅដល់ជនបទ*

បើកការដ្ឋានពង្រីក សមត្ថភាពអាងប្រព្រឹត្តិកម្មរបស់ខ្លួននាថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៧។

ចំពោះសមិទ្ធផលនិងទិសដៅសំខាន់ ក្នុងវិស័យឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងមានផែនការក្នុងការរុញប្រទេសកម្ពុជាឲ្យក្លាយជាប្រទេសឌីជីថលនៅក្នុងឆ្នាំ ២០២៣ ហើយរោងចក្រសហគ្រាសទាំងអស់នឹងក្លាយទៅជារោងចក្រវៃឆ្លាត (Smart Factory) ស្របតាមបច្ចេក វិទ្យា ឧស្សាហកម្ម ៤.០ ។ ឯកឧត្តម **ហេង សុគន់** រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បានអោយដឹងថា នៅឆ្នាំ២០២៣ ខាងមុខប្រទេស កម្ពុជានឹងត្រូវរុញឲ្យទៅជាប្រទេសឌីជីថល ដែលយើងត្រូវការចាំបាច់បញ្ជ្រាបការយល់ដឹងទៅដល់កម្មករ, មន្ត្រីរាជការ និយោជិតក្រុមហ៊ុន ឯកជនទាំងអស់ អំពីបច្ចេកវិទ្យា អំពីនវានុវត្តន៍ វិទ្យាសាស្ត្រ ដើម្បីឲ្យពួកគេបង្កើនសមត្ថភាព ផងនិងបង្កើនផលិតភាពខ្លួនឯងផង ។

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក៏បានបង្ហាញនូវឆន្ទៈរបស់ខ្លួនក្នុងការឈានទៅធ្វើគំរូគេនៅក្នុងប្រទេសកម្ពុជា ដោយកាត់បន្ថយការប្រើប្រាស់ក្រដាសជាឯកសារ ហើយផ្លាស់ប្តូរទៅប្រើប្រាស់ប្រព័ន្ធឌីជីថលជំនួសវិញ។ ក្នុងនោះក្រសួងក៏នឹងជំរុញអោយមន្ត្រីទាំងអស់ត្រូវសិក្សា និងស្វែងយល់ពីការប្រើប្រាស់បច្ចេកវិទ្យានិងអោយស្របបជិវត្តន៍ឧស្សាហកម្មទី ៤.០ ។បញ្ហាប្រឈមគឺក្រសួងនៅខ្វះធនធានមនុស្ស ដែលមាន សមត្ថភាព និងធនធានវិភាគ, ឧបករណ៍មន្ទីរពិសោធន៍ជាដើម។

ក្រសួងត្រូវខិតខំធ្វើបន្តនោះគឺច្បាប់ផ្ទេរបច្ចេកវិទ្យាដែលជាច្បាប់មួយដ៏សំខាន់ដែលអាចធ្វើឱ្យយើងអាចផ្ទេរបច្ចេកវិទ្យាពីប្រទេសផ្សេងៗចូលមកប្រទេសរបស់យើងនិងផ្ទេររបស់យើងទៅកាន់ប្រទេសផ្សេងៗបាន។ នេះក្រសួងនឹង បន្តជំរុញអនុវត្តន៍នូវគោលនយោបាយឧស្សាហកម្មឆ្នាំ ២០១៥ -២០២៥ ឲ្យសម្រេចបាន ជោគជ័យ និងត្រៀមធ្វើ ពិពិធកម្មវិស័យឧស្សាហកម្មដោយមិនពឹងផ្អែកទៅលើវិស័យឧស្សាហកម្មអតិពលកម្មទៀត នោះទេ ។ ជាមួយនេះ ក្រសួងក៏នឹងត្រៀមចេញនូវច្បាប់ស្តីពីសហគ្រាសធុនតូច និងមធ្យមហើយយើងក៏បានត្រៀមនូវគោលនយោបាយសម្រាប់វិស័យសហគ្រាសធុនតូចនិងមធ្យមផងដែរ។ ក្រសួងក៏នឹងខិតខំពង្រឹងនូវគុណភាពមន្ទីរពិសោធន៍របស់យើងដើម្បីធ្វើយ៉ាងណាជំរុញឲ្យការធ្វើរង្វាស់រង្វាល់មានភាពស្រួក្រិត និងប្រសិទ្ធភាពខ្ពស់ ។ ចំណុចសំខាន់មួយទៀត ដែលជាទិសដៅនិងផែនការរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គឺក្រសួងបាននិងកំពុងសិក្សា ដើម្បីបង្កើតតំបន់ឧស្សាហកម្ម, តំបន់សហគ្រាសធុនតូចនិងមធ្យម, ជាសួនវិទ្យាសាស្ត្រ, សួនបច្ចេកវិទ្យា, សួននវានុវត្តន៍ និងសួនឌីជីថល ដោយធ្វើ ការប្រមូលផ្តុំខេត្ត៤ ឬ៥ បញ្ចូលគ្នា ទៅតាមសក្តានុពល នៃខេត្តជាប់ៗគ្នា ហើយបង្កើតជាតំបន់បង្កើតជាសួនតែម្តងដើម្បីធ្វើឲ្យខ្សែសង្វាក់ផលិតកម្មត្រូវ បានភ្ជាប់គ្នា។ ក្រសួងក៏កំពុងរៀបចំត្រៀមធ្វើឱ្យតាមបណ្តារោងចក្រសហគ្រាសទាំងអស់នៅកម្ពុជាក្លាយទៅជា smart Factory ស្របតាមបច្ចេកវិទ្យា ឧស្សាហកម្ម ០៤ ។ ការងារសំខាន់មួយទៀតគឺកិច្ចសហប្រតិបត្តិការចុះប្រកាសនីយបត្រតក្តកម្ម សម្រាប់អ្នកដែលមានស្នាដៃបង្កើតថ្មីចំនួន ៣០៨ ស្នាដៃនៅឆ្នាំ ២០១៩ និងការចេញប្រកាស សនីយបត្រតក្តកម្ម ចំនួន ៨១ ។ ពាក់ព័ន្ធវិស័យសហគ្រាសធុនតូចនិងមធ្យមដែលដើរតួនាទីជាឆ្អឹងខ្នង ដ៏សំខាន់នៃសេដ្ឋកិច្ចជាតិ បច្ចុប្បន្ន រាជរដ្ឋាភិបាលបានបង្កើតឲ្យមានធនាគារសម្រាប់សហគ្រាសធុនតូចនិងធម្យម(SME) ដែលមានដើមទុន ១០០ លានដុល្លារហើយអត្រាការប្រាក់ទាបបំផុតត្រឹមតែ ៧ភាគរយប៉ុណ្ណោះក្នុងមួយឆ្នាំ ។ វិស័យឯកជនក៏បាន ចូលរួមយ៉ាងសកម្មនៅក្នុងវិស័យ SME នេះជាក់ស្តែងតាំង ពីឆ្នាំ ២០១៨ មកធនាគារកាណាឌីយ៉ាក៏បានផ្តល់កម្ចី ដល់សហគ្រាស ធុនតូចនិងមធ្យមមានចំនួនប្រមាណ១៥០លានដុល្លារ។ កម្ពុជាក៏កំពុងអនុវត្តន៍ នូវគម្រោងមួយចំនួន ទៀតដើម្បីជួយដល់វិស័យ SME ដូចជាគម្រោង PROGRAME FOR COUNTRY PARTNERSHIP (PCP)។ គឺកម្ពុជាជាប្រទេសទី១ នៅអាស៊ីដែលទទួលបាន គម្រោងនេះ ពីអង្គការ UNIDO ដែលជាអង្គការមួយ របស់អង្គការ សហប្រជាជាតិ ដែលទទួលបន្ទុកអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។ គម្រោងនេះ សំខាន់ណាស់ ក្នុងការប្រែក្លាយវិស័យកសិកម្មទៅជាកសិឧស្សាហកម្មទៅជាកសិទេសចរណ៍ផ្សារភ្ជាប់ជាមួយវិស័យទេសចរណ៍។ ជាមួយគ្នា នេះរាជរដ្ឋាភិបាលក៏បាន កំណត់គោលដៅប្រែក្លាយទៅជាតំបន់សេដ្ឋកិច្ចពហុបំណងតាមផែនការសកម្មភាពនៃវិស័យឧស្សាហកម្ម ២០១៥-២០២៥ ផងដែរ៕

គម្រោងសួនឧស្សាហកម្មទំហំ ៥០០ ហិកតា របស់ក្រុមហ៊ុនវិនិយោគទុនអាណិកជនកម្ពុជា (OCIC) នៅខេត្តកំពង់ស្ពឺ

កំពង់ផែទឹកជ្រៅលំដាប់អន្តរជាតិ ក្រុងព្រះសីហនុកំពុងត្រូវអភិវឌ្ឍ ឲ្យក្លាយជាកំពង់ផែកុងតឺន័រទឹកជ្រៅដ៏ធំក្នុងតំបន់

***កំពង់ផែទឹកជ្រៅ** លំដាប់អន្តរជាតិ ក្រុងព្រះសីហនុ នឹងបង្កើនលទ្ធភាពកប៉ាល់ចូលចតរហូតដល់ជម្រៅ១៨ម៉ែត្រ*

អនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កំពង់ផែខេត្តព្រះសីហនុ កំពុងត្រូវបានអភិវឌ្ឍពង្រីកសមត្ថភាព ក្លាយជាកំពង់ផែកុងតឺន័រទឹកជ្រៅដ៏ធំក្នុងតំបន់។

ក្រោមជំនួយរបស់រដ្ឋាភិបាលជប៉ុន កំពង់ផែអន្តរជាតិទឹកជ្រៅនៅក្រុងព្រះសីហនុ នឹងបង្កើនលទ្ធភាពកាន់តែធំទូលាយ និងមានជម្រៅរហូតដល់១៨ម៉ែត្រដែលអាចទទួលការចូលចតនាវាដឹកជញ្ជូនធំៗដែលកំពុងចរាចរណ៍នៅលើសមុទ្រអន្តរជាតិ។ បច្ចុប្បន្ននេះ កំពង់ផែដែលបម្រើដល់វិស័យដឹកជញ្ជូនតាមផ្លូវទឹកក្នុងខេត្តព្រះសីហនុមានចំនួន៣ រួមមាន កំពង់ផែស្វយ័តក្រុងព្រះសីហនុ កំពង់ផែឧកញ៉ាម៉ុង និងកំពង់ផែអន្តរជាតិស្ទឹងហាវ ស្ថិតនៅក្នុងស្រុកស្ទឹងហាវ។ បច្ចុប្បន្នកំពង់ផែអន្តរជាតិទឹកជ្រៅដែលកំពុងដំណើរការនៅក្រុងព្រះសីហនុមានជម្រៅ ៨,៥ ម៉ែត្រ ប៉ុន្តែនៅក្នុងផែនការមេរបស់រាជរដ្ឋាភិបាល នឹងធ្វើការអភិវឌ្ឍពង្រីកវិសាលភាពឱ្យកាន់ធំទូលាយជាងនេះ។ កំពង់ផែទាំង ៣ នេះគឺមានសារសំខាន់ណាស់ ក្នុងការគាំទ្រវិស័យដឹកជញ្ជូនតាមផ្លូវទឹកដែលនាំយកទំនិញពីកម្ពុជាឆ្ពោះទៅកាន់ទីផ្សារប្រទេសនានា ក៏ដូចជានាំយកទំនិញពីបណ្តាប្រទេសដទៃ មកកាន់កម្ពុជាផងដែរ ដែលនេះគឺជាសរសៃឈាមនៃសេដ្ឋកិច្ចជាតិយ៉ាងសំខាន់” ។

ពេលនេះគម្រោងនៃការអភិវឌ្ឍ និងពង្រីកវិសាលភាពកំពង់ផែអន្តរជាតិទឹកជ្រៅ ក្រុងព្រះសីហនុ ស្ថិតក្នុង ការសិក្សា និងការដាក់ដេញថ្លៃក្នុងដំណាក់កាលទី១ ដែលមានជម្រៅត្រឹម១៤,៥ម៉ែត្រ ដែលគ្រោងសាងសង់ នៅត្រឹមពាក់ កណ្តាលឆ្នាំ២០២១ និងបញ្ចប់នៅឆ្នាំ២០២៤ ជាមួយការចំណាយ ប្រមាណ ជាង២០០លានដុល្លារ។ ដំណាក់កាលទី២ និងទី៣នឹងត្រូវអនុវត្តព្រមគ្នា ដែលអាចពង្រីកវិសាលភាពកាន់តែធំទូលាយ និងមានជម្រៅរហូតដល់ ១៨ម៉ែត្រ ហើយគម្រោងនេះនឹងបញ្ចប់ការសាងសង់នៅឆ្នាំ២០២៨ ។ ជាមួយនឹងរូបភាពថ្មីការអភិវឌ្ឍកំពង់ផែអន្តរជាតិ ទឹកជ្រៅក្រុងព្រះសីហនុ ដែលមានជម្រៅរហូតដល់ ១៨ម៉ែត្រនេះ អាចមានលទ្ធភាពទទួលការចូលចតនាវាដឹកទំនិញ ធំៗកំពុងចរាចរណ៍នៅលើផ្ទៃសមុទ្រអន្តរជាតិ ដោយការអភិវឌ្ឍទាំងនេះគឺស្ថិតនៅក្រោមជំនួយពីប្រទេសដៃគូអភិវឌ្ឍន៍រដ្ឋាភិបាលជប៉ុន។

ឯកឧត្តម **ស៊ុន ចាន់ថុល** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូនបានអោយដឹងថា គម្រោងនេះត្រូវបានគាំទ្រហិរញ្ញប្បទានពីទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)។ ឯកឧត្តមថ្លែងថា៖ «ចំណតផែកុងតឺន័រក្រុងព្រះសីហនុនេះនឹងអនុញ្ញាតឲ្យនាវាដឹកទំនិញធំៗប្រ មាណ ៩៣ ភាគរយ ដែលធ្វើដំណើរឆ្លងកាត់តំបន់អាស៊ីប៉ាស៊ីហ្វិកចូលចតនៅកម្ពុជា ។ យើងអាចនាំចេញទំនិញដោយផ្ទាល់ទៅកាន់ប្រទេសបញ្ជាទិញ ដោយមិនចាំបាច់មានការផ្ទេរទំនិញនៅកំពង់ផែសិង្ហបុរី និងហុងកុងទៀតនោះទេ»។ ឯកឧត្តម **ឈៀង ពេជ្រ** អគ្គនាយកនៃអគ្គនាយកដ្ឋានភ័ស្តុភារកម្មក្រសួងសាធារណការ និងដឹកជញ្ជូនបានប្រាប់ឲ្យដឹងថា គម្រោងកំពង់ផែទឹកជ្រៅនេះបានសិក្សាចប់សព្វគ្រប់ហើយដោយអង្គការ JICA ហើយគម្រោងនេះកំពុងបន្តអនុវត្ត។ ឯកឧត្តមថ្លែងថា៖ «កំពង់ផែកុងតឺន័រនេះនឹងជួយសម្រួលដល់អ្នកនាំចូល និងនាំចេញទំនិញទូទាំងតំបន់អាចចូលចតនៅកំពង់ផែនេះ ដោយវានឹងជួយកាត់បន្ថយតម្លៃដើមផងដែរ»។ លោក **ស៊ុន ចន្ថី** ប្រធានសមាគមភ្នាក់ងារបញ្ជូនទំនិញកម្ពុជាបានប្រាប់ថា កំពង់ផែកុងតឺន័រនេះនឹងជួយធ្វើឲ្យប្រសើរឡើងដល់កន្លែងផ្ទុកកុងតឺន័រ ខណៈកំពង់ផែស្វយ័តក្រុងព្រះសីហនុមិនទាន់អាចបំពេញតម្រូវការកំណើនទីផ្សារបាននៅឡើយ។ លោកថ្លែងថា៖ **«វាជាសញ្ញាល្អសម្រាប់វិស័យដឹកជញ្ជូនតាមផ្លូវទឹកដែលយើងគាំទ្រគម្រោងនេះ។ កំពង់ផែកុងតឺន័រនេះនឹងជួយសម្រួល និងកាត់បន្ថយការកកស្ទះការផ្ទុកកុងតឺន័រនៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ ហើយវាក៏នឹងជួយជំរុញកំណើនប្រាក់ចំណូលរបស់រដ្ឋាភិបាលផងដែរ ប្រសិនបើយើងមានចំណតថ្មីនេះ»**។

តាមរបាយការណ៍ប្រចាំឆ្នាំរបស់ក្រសួងសាធារណការ និងដឹកជញ្ជូនបានឲ្យដឹងថា ប្រាក់ចំណូលសរុបរបស់កំពង់ផែនេះបានកើនឡើងដល់ប្រហែល ៨០ លានដុល្លារ សម្រាប់ឆ្នាំ ២០១៩ កើនឡើង ១៧,៥ ភាគរយ បើធៀបនឹងប្រហែល ៦៨ លានដុល្លារ កាលពីឆ្នាំ ២០១៨ ។ របាយការណ៍របស់ក្រសួងឲ្យដឹងទៀតថា ចំនួនកុងតឺន័រដែលផ្ទុកនៅកំពង់ផែព្រះសីហនុ បានកើនឡើង ១៧ ភាគរយ កើនឡើងដល់សរុប ៦៣៣ ០៩៩ TEU ត្រឹមចុងឆ្នាំ ២០១៩ ធៀបនឹង ៥៤១ ២២៨ TEU កាលពីឆ្នាំ ២០១៨។

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានមានប្រសាសន៍បញ្ជាក់ថា ក្រុងព្រះសីហនុបានដើរតួយ៉ាងសំខាន់ក្នុងនាមជាមជ្ឈមណ្ឌលដឹកជញ្ជូន ដែលក្នុងនោះ ដឹកជញ្ជូនពីកំពង់ផែទឹកជ្រៅទៅកាន់កំពង់ផែសម្រាប់ ដឹកជញ្ជូនតាមផ្លូវគោក ហើយដឹកជញ្ជូនពីកំពង់ផែផ្លូវគោកមកកាន់កំពង់ផែទឹកជ្រៅ។ លើសពីនេះក៏មាន ការដឹកជញ្ជូនតាមរយៈផ្លូវអាកាសផងដែរ ក្នុងការនាំយកផលិតផល ពីប្រទេសកម្ពុជាឆ្ពោះទៅកាន់ទីផ្សារក្រៅប្រទេស ហើយដឹកជញ្ជូនផលិតផលពីក្រៅប្រទេសមកផ្គត់ផ្គង់នៅទីផ្សារ ក្នុងស្រុកវិញ។ ក្រៅពីនេះ ក្រុងព្រះសីហនុ ក៏ជាតំបន់គោលដៅទេសចរណ៍ដ៏មានប្រជាប្រិយភាព ហើយនៅថ្ងៃអនាគតអាចនឹងប្រែក្លាយទៅជាមជ្ឈមណ្ឌល ហិរញ្ញវត្ថុ ប្រចាំប្រទេស ដែលគោលបំណងមួយនេះអ្នកជំនាន់ក្រោយ គេអាចមានលទ្ធភាពគ្រប់គ្រាន់ក្នុងការសម្រេចខណៈដែលនៅពេលបច្ចុប្បន្ននេះ សម្រាប់ការបម្រើឱ្យវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម។

ប្រកាន់ខ្ជាប់យុត្តិធម៌ ភាពមឺងម៉ាត់ និងសុចរិតភាព ក្នុងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌

*ឯកឧត្តម **កើត រិទ្ធ** អញ្ជើញជាអធិបតីក្នុងពិធីប្រកាសបើកយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី ខេត្ត*

នៅក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភាបានដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្រគោលនយោបាយធំៗជាអាទិភាពគោលនយោបាយអភិវឌ្ឍន៍តាមវិស័យនិងវិធានការជាក់ស្តែងជាអាទិភាព ជាច្រើន ។ នៅក្នុងនោះ ការជំរុញកំណែទម្រង់ដ៏ស៊ីជម្រៅទាំងឡាយ ដើម្បីអភិបាលកិច្ចល្អ ក៏ត្រូវបានជំរុញអនុវត្តយ៉ាងសកម្ម ជាក់ស្តែង ការពង្រឹងស្ថាប័នយុត្តិធម៌ និងតុលាការ ក៏ទទួលបានលទ្ធផលជាផ្លែផ្កាគួរឲ្យកត់សម្គាល់ ។

ក្នុងចំណោមសមិទ្ធផល ដែលសម្រេចបានក្នុងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌មានចំណុចលេចធ្លោដែលគួរឲ្យកត់សម្គាល់នោះគឺការអនុវត្តយុទ្ធនាការដោះស្រាយ ការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានីខេត្ត ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ច្បាប់ដែលត្រូវអនុវត្តចាប់ពីថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២០ ។ ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានមានប្រសាសន៍ថា ការកកស្ទះសំណុំរឿងបានក្លាយជាបញ្ហាប្រឈមចំពោះមុខដែលក្រសួងយុត្តិធម៌ចាំបាច់ត្រូវជួយដល់សាលាជម្រះក្តីដើម្បីដោះស្រាយនិងចាត់ទុកការងារនេះជាផ្នែកមួយដ៏សំខាន់នៅក្នុងកម្មវិធីកំណែទម្រង់របស់ខ្លួន ។ យុទ្ធនាការនេះមានគោលបំណងសំខាន់ៗចំនួនពីរ គឺ **ទី១-** ដោះស្រាយការកកស្ទះសំណុំរឿង ដែលមាននៅតាមសាលាដំបូងរាជធានីខេត្តដើម្បីពន្លឿនការរកយុត្តិធម៌ឱ្យបានឆាប់រហ័ស និងលើកកម្ពស់សមត្ថភាពស្ថាប័នតុលាការក្នុងការផ្តល់ សេវាយុត្តិធម៌, **ទី២-** ចូលរួមចំណែកដោះស្រាយការចង្អៀតណែននៃអ្នកជាប់ឃុំខ្លួននៅតាមពន្ធនាគារ ។ ដើម្បីធានាបាននូវភាពមឺងម៉ាត់ សុចរិតភាពនិងភាពត្រឹមត្រូវនៅក្នុងការអនុវត្តយុទ្ធនាការក្រសួងយុត្តិធម៌ក៏បានដាក់ចេញនូវអភិក្រមការងារចំនួន២ សំខាន់ៗ គឺ ៖ អភិក្រម**ទី១-** យុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនេះ ត្រូវអនុវត្តដោយផ្អែកលើមូលដ្ឋានច្បាប់ជាពិសេសចំណាត់ការដោះស្រាយសំណុំរឿងត្រូវមានភាពមឺងម៉ាត់និងត្រូវអនុវត្តឱ្យបានត្រឹមត្រូវស្របតាមច្បាប់ និងនីតិវិធីជាធរមាន បន្ថែមលើច្បាប់និងបទដ្ឋានគតិយុត្តដែលមានជាធរមាន ។ ក្រសួងយុត្តិធម៌បានដាក់ចេញសេចក្តីណែនាំផ្នែកផ្លូវច្បាប់ដើម្បីធានាដល់ការអនុវត្តអភិក្រមនេះផងដែរនិងអភិក្រមទី២-យុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនេះ ត្រូវអនុវត្តដោយផ្អែកលើមូលដ្ឋាននៃយុត្តិធម៌ សុចរិតភាព និងភាពត្រឹមត្រូវដោយមិន ត្រូវឱ្យមានជាដាច់ខាតនូវស្ថានភាព «**ត្រីងៀតឆ្លៀតពង**» នៅក្នុងយុទ្ធនាការនេះឡើយ ។ យុទ្ធនាការនេះ ជួយកាត់បន្ថយការកកស្ទះសំណុំរឿងនៅសាលាដំបូងរាជធានី-ខេត្ត គឺការងារអាទិភាពរបស់ក្រសួងនៅក្នុងការជំរុញប្រសិទ្ធភាពស្ថាប័នតុលាការ ។ ព្រមជាមួយគ្នានេះវាក៏បានផ្តល់នូវផលប្រយោជន៍បីជាសំខាន់ៗបន្ថែមទៀត គឺ **ទី១**-គឺដើម្បីពន្លឿនការស្វែងរកយុត្តិធម៌ដល់ប្រជាពលរដ្ឋ, **ទី២**-ជំរុញលើកកម្ពស់ប្រសិទ្ធភាពការងារតុលាការ និង**ទី៣**-កាត់បន្ថយការណែនចង្អៀតអ្នកជាប់ឃុំនៅក្នុងពន្ធនាគារ ។ លោកបានបញ្ជាក់បន្ថែមថា នាពេលកន្លងមកក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀន យុទ្ធនាការប្រយុទ្ធប្រឆាំងបទល្មើស ធនធានធម្មជាតិ និងបទល្មើសព្រៃឈើបានធ្វើឱ្យសំណុំរឿងព្រហ្មទណ្ឌមានការកើនឡើងជាច្រើននៅតាមសាលាដំបូងរាជធានី-ខេត្ត ហើយចំនួនអ្នកជាប់ឃុំនៅតាមពន្ធនាគារក៏មានការកើនឡើងជាច្រើន ដែលបង្កឱ្យមានភាពចង្អៀតណែន ។ ពិសេសការកើនឡើងជាច្រើនទៅលើសំណុំរឿង និងអ្នកជាប់ឃុំនៅក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។ ទាក់ទិនទៅនឹងរឿងនេះដែរ លោករដ្ឋមន្ត្រីមានបញ្ជាក់ឱ្យដឹងថា បើគេគិតត្រឹមថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២០ សាលាដំបូងរាជធានីភ្នំពេញ ខេត្ត មានសំណុំរឿងព្រហ្មទណ្ឌដែលកំពុងចាត់ការសរុប ចំនួន ៣៩.១៥២សំណុំរឿង (គ្រឿងញៀនមានចំនួន៦.២៦០សំណុំរឿង) និងមានអ្នកជាប់ឃុំសរុបចំនួន ១២.៦៥១នាក់ (អ្នកជាប់ឃុំនៅក្នុងសំណុំរឿងគ្រឿងញៀនមានចំនួន ៦.៩០០នាក់) ។ ក្នុងរយៈពេល ១ឆ្នាំៗ ចៅក្រមមួយរូបបានចាត់ការសំណុំរឿងបាន ១៣០រឿង ឬមធ្យមដែលជាការងារមួយច្រើនខ្លាំងណាស់ក្នុងចំណោមសាលាដំបូងរាជធានី-ខេត្ត ។ ហេតុនេះដោយសារសំណុំរឿងមានការកើនឡើងយ៉ាងគំហុក ហើយមានការខ្វះខាត ទាំងផ្នែកធនធានមនុស្ស និងសម្ភារៈ មិនអាចដោះស្រាយបាននោះទេ ។ ក្នុងស្ថានភាពបច្ចុប្បន្ន ដែលមិនអាចដោះស្រាយបាន ទើបធ្វើឱ្យសំណុំចាស់ៗកប់ជ្រៅទៅៗដែលធ្វើឱ្យយឺតយ៉ាវសំណុំរឿងផងដែរ ។ លោករដ្ឋមន្ត្រីបានបញ្ជាក់បន្ថែមថា ក្នុងករណីសំណុំរឿងកកស្ទះច្រើននៅតាមសាលាដំបូងរាជធានី-ខេត្តមួយចំនួនក្រសួងលើកទឹកចិត្តឱ្យចៅក្រមកន្លែងផ្សេង មកជួយដើម្បីសម្រាលកិច្ចការងារខ្លះ ។ ជាមួយគ្នាក្រសួងយុត្តិធម៌ក៏មិនលូកដៃចូលក្នុងការសម្រេចសេចក្តីរបស់ចៅក្រមនោះទេ ការដែលក្រសួងបើកយុទ្ធនាការនេះឡើងដើម្បីជួយសម្រួលក្នុងការងារមួយចំនួនដែលមិនទាន់មានភាពរលូនតែប៉ុណ្ណោះ ។

សាលាដំបូងរាជធានីភ្នំពេញ
និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

យុទ្ធនាការនេះ ត្រូវប្រើពេលប្រមាណ ៦ ដល់ ៩ខែ ទើបអាចបញ្ចប់ទៅវិញ ប៉ុន្តែយ៉ាងណាបើសិនមិនទាន់ចប់យុទ្ធនាការនេះ នឹងនៅបន្តធ្វើបន្ថែមទៀតរហូតដល់ការដោះស្រាយជូនពលរដ្ឋទទួលបានលទ្ធផលល្អប្រសើរ ។ ទន្ទឹមនឹងគ្នានេះ លោករដ្ឋមន្ត្រីបានបញ្ជាក់ដែរថាក្រសួងនឹងលើកទឹកចិត្តឲ្យសង្គមស៊ីវិល ធ្វើការងារជាមួយក្រសួង ប៉ុន្តែយ៉ាងណាសង្គមស៊ីវិលទាំងអស់ក៏មិនត្រូវលូកដៃចូលទៅក្នុងស្ថាប័នតុលាការ ហើយទៅធ្វើរបាយការណ៍មួយផ្សេងនានាដែលប្រាសចាកផ្លូវច្បាប់និងខុសការពិតនោះឡើយ ។ក្នុងយុទ្ធនាការនេះដែរឯកឧត្តម **កើត ឆែ** ក៏បានដាស់តឿនដល់ចៅក្រម ព្រះរាជអាជ្ញាក្រឡាបញ្ជី ប្រព្រឹត្តអំពើខុសច្បាប់ ឬក៏ជាអំពើមួយដើម្បីផលប្រយោជន៍ ផ្ទាល់ខ្លួននោះនឹងទទួលទោសយ៉ាងម៉ឺងម៉ាត់ និងតាមវិជ្ជាជីវៈផ្លូវច្បាប់ពុំខាន ។ ព្រមជាមួយគ្នាក្នុងយុទ្ធនាការ នេះក៏មានការចូលរួមដៃគូសំខាន់ជាមួយអង្គភាពប្រឆាំងអំពើពុករលួយដើម្បីប្រយុទ្ធប្រឆាំងរាល់អំពើពុករលួយកើតឡើងទៀតផង ។

ឯកឧត្តម **ឱម យ៉ិនឆៀង** ទេសរដ្ឋមន្ត្រី និងជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ដែលបានចាប់ដៃគ្នាសហការជាមួយក្រសួងយុត្តិធម៌ ដើម្បីទប់ស្កាត់ក្រុមឱកាសនិយម ដែលឆ្លៀតរកផល-ប្រយោជន៍ពីយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានីខេត្ត បានមានប្រសាសន៍ថា នេះជាយុទ្ធសាស្ត្រជួយដល់តុលាការក្នុងការដោះស្រាយការកកស្ទះសំណុំរឿង តែខ្លឹមសារជ្រាលជ្រៅជាងនេះទៅទៀត គឺជាការពង្រឹងនូវគុណភាពរបស់តុលាការ មានន័យថា មិនមែនត្រូវតែដោះស្រាយសំណុំរឿងគិតតែពីលឿន ហើយមិនគិតអំពីនីតិវិធី មិនគិតអំពីយុត្តិធម៌ មិនគិតពីភាពស្អាតស្អំនោះឡើយ ។ លឿនត្រឹមត្រូវ យុត្តិធម៌ និងមិន ពុក-រលួយ គឺជាស្នូល ជាខ្លឹម នៃគំនិតកែទម្រង់របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ លោកទេសរដ្ឋមន្ត្រីបានបញ្ជាក់ថា លឿន ត្រឹមត្រូវ និងយុត្តិធម៌ គឺជាកាតព្វកិច្ចរបស់ក្រសួងយុត្តិធម៌ ឯការប្រឆាំងអំពើពុករលួយ គឺជាកាតព្វកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយ ហើយកាតព្វកិច្ចជាបងប្អូនទាំង២នេះ ត្រូវការចាប់ដៃគ្នាយ៉ាងជិតស្និតដើម្បីទប់ទល់ពួកឱកាសនិយមដែលឆ្លៀតរកផលប្រយោជន៍ពីយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនេះ ។ ចង់លឿនតែមិនស្អាត ឬចង់តែស្អាតតែមិនព្រមលឿនគឺជាជម្ងឺ២យ៉ាងដែលយុទ្ធនាការនេះចង់ព្យាបាលអោយបានជាស្រឡះពីវិស័យយុត្តិធម៌កម្ពុជា ។អង្គភាពប្រឆាំងអំពើពុករលួយនឹងចែករំលែកព័ត៌មានសម្ងាត់ជូនដល់ក្រសួងយុត្តិធម៌ ដើម្បីស្រាវជ្រាវស៊ើបអង្កេតករណី និងកិច្ចការមួយចំនួនទៀត ។ គិតត្រឹមរយៈពេល ១០០ថ្ងៃ ពីថ្ងៃទី២៨ ខែឧសភា មកដល់ថ្ងៃ ២៧ ខែសីហា ក្រសួងយុត្តិធម៌បានដោះស្រាយសំណុំរឿងជាង ៨.១១៣ករណី ស្មើនឹង ៦៣% នៃសំណុំរឿងដែលបានកកស្ទះកន្លង មក ភាគច្រើនជាសំណុំរឿងដែលទាក់ទងទៅនឹងបទល្មើសគ្រឿងញៀននេសាទ ព្រៃឈើ និងបទល្មើសផ្សេងទៀត ។

ដើម្បីលើកកម្ពស់គុណភាពនៃការកាត់ក្តីឱ្យបានត្រឹមត្រូវ និងយុត្តិធម៌ ក៏ដូចជាលើកកម្ពស់ការផ្តល់សេវាយុត្តិធម៌ ឱ្យមានភាពងាយស្រួលឆាប់រហ័សនិងស្អាតស្អំនៅថ្ងៃទី២៤ខែកក្កដាឆ្នាំ២០២០ នេះ នៅទីស្តីការក្រសួងយុត្តិធម៌ ឯកឧត្តម **កើត ឆែ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌បានធ្វើការណែនាំដល់ចៅក្រមព្រះរាជអាជ្ញាមន្ត្រីតុលាការ និងមន្ត្រីរាជការទាំងអស់នៃសាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ក៏ដូចជានៅតាមសាលាជម្រះក្តីផ្សេងទៀតនៅទូទាំងប្រទេសត្រូវ **ទី១-** ប្រកាន់ខ្ជាប់នូវអភិក្រមដ៏ថ្លៃថ្លាទាំង៥របស់ សម្តេចតេជោនាយករដ្ឋមន្ត្រី គឺ «**ឆ្លុះកញ្ចក់ ងូតទឹក ជុសក្បែលព្យាបាល និងវះកាត់**» ដើម្បីធ្វើជាគោលការណ៍ក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ក៏ដូចជាក្នុងការដឹកនាំអង្គភាពសាលាជម្រះក្តី **ទី២-** ប្រកាន់ខ្ជាប់នូវភាពម៉ឺងម៉ាត់របស់ខ្លួន ក្នុងការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ ដើម្បីផ្តល់ការកាត់ក្តី មួយប្រកបដោយអនាគតិ ក្នុងការធានាឱ្យបាននូវភាពយុត្តិធម៌ ត្រឹមត្រូវ ជូនប្រជាពលរដ្ឋ ជាពិសេសគឺការរៀរចាកនូវអគតិធម៌ទាំង ៤ គឺ ឆន្ទាគតិ ទោសាគតិ ភយាគតិ និងមោហាគតិ ដូចដែលចៅក្រម ព្រះរាជអាជ្ញាទាំងអស់បានធ្វើសច្ចាប្រណិធានៅមុនពេលខ្លួនចូលកាន់តំណែង **ទី៣-**ប្រកាន់ខ្ជាប់ឱ្យបានម៉ឺងម៉ាត់នូវវិន័យ និងក្រមសីលធម៌វិជ្ជាជីវៈរបស់ចៅក្រម និងព្រះរាជអាជ្ញា ទាំងក្នុងពេលបំពេញការងារ ទាំងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។ ការប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន គឺជាការរួមចំណែកដ៏សំខាន់ក្នុងការលើកកម្ពស់កិត្តិយស សេចក្តីថ្លៃថ្នូរ និងកិត្យានុភាពនៃអង្គចៅក្រមខ្លួនឯង ហើយវាជាកត្តារួមចំណែកដ៏សំខាន់មិនអាចខ្វះបាន ក្នុងការពង្រឹងជំនឿទុកចិត្តពីសាធារណជនចំពោះវិស័យយុត្តិធម៌ **ទី៤-** ចូលរួមប្រកបដោយឆន្ទៈ និងស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការអនុវត្តនូវយុទ្ធនាការដោះស្រាយការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានី-ខេត្ត ដែលបានដាក់ចេញដោយក្រសួងយុត្តិធម៌ កាលពីថ្ងៃទី១៨ ខែឧសភា កន្លងទៅនេះ ដោយអនុវត្តឱ្យបានត្រឹមត្រូវ និងម៉ឺងម៉ាត់តាមអភិក្រម «**លឿន ត្រឹមត្រូវ យុត្តិធម៌ និងមិនពុករលួយ**» និង**ទី៥-** យកចិត្តទុកដាក់ក្នុងការបំពេញការងារ ដោយត្រូវពង្រឹងសាមគ្គីភាពផ្ទៃក្នុង និងពង្រឹង កិច្ចសហប្រតិបត្តិការល្អជាមួយអាជ្ញាធរ និងស្ថាប័នពាក់ព័ន្ធ ដើម្បីធានានូវដំណើរការល្អនៃស្ថាប័នតុលាការ ក៏ដូចជាប្រសិទ្ធភាពនៃការបម្រើសេវាយុត្តិធម៌ ឱ្យបានត្រឹមត្រូវជូនប្រជាពលរដ្ឋ ៕

ប្រវត្តិ តាខ្មៅ (ខេត្តកណ្តាល)

«**តាខ្មៅ**» ជានាមទីក្រុងមួយរបស់ខេត្តកណ្តាល មានចម្ងាយផ្លូវ ប្រមាណជា១១គ.ម ខាងត្បូងរាជធានីភ្នំពេញ ដែលមានទីតាំងនៅជាប់ប្របនឹងទន្លេបាសាក់ ។ និមិត្តរូបទីក្រុងនេះមានរូបសំណាកតាខ្មៅ មានមាឌធំក្រអាញ ដៃស្តាំកាន់ដំបង ស្ថិតនៅត្រង់ផ្លូវបំបែកច្រើនផ្លូវ ។ តាំងពីដើមរហូតមកដល់បន្តប្បន្នប្រជាពលរដ្ឋនៅតំបន់នោះ តែងមានជំនឿមុតមាំលើបារមីលោកតាខ្មៅថា ពូកែសក្តិសិទ្ធដែលក្រោយពេលបន់ស្រន់ម្តងៗតែងបានសម្រេចដូចបំណង ។ ចំពោះប្រវត្តិតាខ្មៅពុំមានឯកសារជាក់លាក់ណាបញ្ជាក់ច្បាស់ និងចាត់ទុកជាប្រវត្តិសាស្ត្រនោះឡើយ ។

យោងតាមឯកសាររបស់សាលាក្រុងតាខ្មៅ និងយោងតាមចាស់ទុំជាច្រើនទៀតដែលបានតំណាលពីប្រវត្តិតាខ្មៅឲ្យដឹងថា៖ ក្នុងសម័យកាលពីបុរាណមានគ្រួសារមួយប្តីឈ្មោះ**ចោម** ប្រពន្ធឈ្មោះ**ចៅ** ប្រសូតបានកូនភ្លោះពីរនាក់ ប្រុសម្នាក់ស្រីម្នាក់ដែលមានសម្បុរខ្មៅដូចគ្នា ខុសប្លែកពីក្មេងដទៃ អ្នកស្រុកភូមិក៏នាំគ្នាហៅថា **អាខ្មៅមីខ្មៅ** ។ តាចោមយាយចៅក៏បានយកកូនទាំងពីរនាក់ទៅថ្វាយព្រះរាជា។ ព្រះរាជាក៏សព្វព្រះរាជហឫទ័យនឹងកុមារខ្មៅទាំងពីរ ហើយទ្រង់ក៏ទទួលយកឲ្យរស់ នៅក្នុងវាំង ដើម្បីបានសិក្សារៀនសូត្រលេខនិពន្ធនឹង គេព្រមទាំង ប្រទានមាសប្រាក់ កែវកង មួយចំនួនដល់តា ចោមយាយ ចៅនោះផង ។ ក្រោយពីកូនភ្លោះទាំងពីរ មានវាសនាមករស់នៅ ក្នុងវាំងតាចោមយាយចៅក៏មានកេរ្តិ៍ឈ្មោះមានមុខមាត់ ធ្វើឲ្យអ្នកភូមិស្រុក សាទររាប់រកគោរព ស្រឡាញ់គ្រប់ៗគ្នា ។

លុះចំណេរកាលក្រោយមកតាចោមយាយចៅក៏ទទួលមរណភាពអស់ទៅ ដោយអំណាចនៃការសាងអំពើល្អរបស់តាយាយ និងដោយក្តីស្រឡាញ់រាប់អាន ពីសំណាក់ញាតិមិត្តជិតខាងអ្នកភូមិផងក៏ បានមូលមតិគ្នាដាក់ឈ្មោះភូមិដែលគាត់ធ្លាប់រស់នៅក្លាយជាឃុំ ចោមចៅ ដែលបន្តជាប់រហូតមកដល់សព្វថ្ងៃនេះ ។ និទានអំពីកុមារទាំងពីរនាក់បងប្អូនដែលរស់នៅក្នុងវាំងវិញ លុះចម្រើនវ័យពេញរូបរាងក៏បានរៀនសូត្រចេះចាំលេខនពន្ធយ៉ាងស្ទាត់ជំនាញពិសេសខាងវិជ្ជាសីលសាស្ត្រ ត្រៃយុទ្ធ ត្រៃវេទ ត្រៃភូមិ ពុំមាននរណាអាចប្រៀបផ្ទឹមបានឡើយ។

ក្រោយមកព្រះរាជាក៏បានប្រាប់អ្នកទាំងពីរថា ដល់ពេលវេលាដែលត្រូវមានភារៈការពារទឹកដីហើយទ្រង់ត្រាស់បង្គាប់ឲ្យអ្នកខ្មៅ (បងប្រុស) ត្រូវមានភារកិច្ចការពារដែនគោក ឯនាងខ្មៅ (ប្អូនស្រី) ត្រូវមានភារកិច្ចការពារដែនទឹក (សមុទ្រ) ។ នារជ្ជកាលនោះ អ្នកខ្មៅគ្រាន់តែជាមេដឹកនាំកុលសម្ព័ន្ធ ឬជាមេតំបន់មួយប៉ុណ្ណោះ។ ក្រោយពីបានពិនិត្យមើលភូមិសាស្ត្រនៅតំបន់កណ្តាលថាមានអំណោយផលល្អប្រជាជនរស់នៅច្រើនទីទួលទឹកមិនលិចផង នោះ អ្នកខ្មៅក៏សម្រេចរើទីតាំងពីភ្នំបាយ៉ង់កោមកតាំងនៅចំណុចវត្តតាខ្មៅនេះវិញ ព្រោះងាយស្រួលក្នុងការបម្រើរាស្ត្រ និងងាយស្រួលឡើងចុះទទួលរាជបញ្ជាពីស្តេច ។ អ្នកខ្មៅក៏បានរៀបចំតំបន់កណ្តាលនេះជាទីតាំងប្រមូលផ្តុំក្រុមកុលសម្ព័ន្ធ និងចងក្រងជាក្រុម ពួកខ្សែសង្វាក់ ។ ក្រោយមកអ្នកខ្មៅក៏មានកេរ្តិ៍ឈ្មោះបោះសម្លេងល្បាយជាវីរជនអង់អាចក្លាហានបង្ក្រាបខ្មាំងសត្រូវគ្រប់ទិសទី ជាពិសេសលោកពូកែខាងវេទមន្ត សិល្ប៍វិជ្ជាកំចាត់ជម្ងឺរោគាដែលមកយាយីប្រជាពលរដ្ឋដែលគាត់គ្រប់គ្រង ហើយគាត់គឺជាអ្នកថែរក្សាព្រៃភូមិសាស្ត្រការពារវប្បធម៌,ប្រពៃណីជាតិ និងការពារបូរណភាពទឹកដី ។ ក្រោយមកព្រះរាជាក៏បានប្រទានងារជាមហាឧបរាជជាមេទ័ពគ្រប់គ្រងនៅតំបន់កណ្តាលព្រមទាំងប្រទានងារជាពញាខ្មៅ ហៅ «**តាខ្មៅ**» ដើម្បីឲ្យសក្តិសមទៅនឹងកិត្តិយសរបស់គាត់ ដែលមួយជីវិតគាត់បានថ្វាយដល់ព្រះរាជា និងមាតុភូមិ ។ សម័យកាលនោះដែរលោកតាខ្មៅក៏មានបរិវាជាច្រើនដូចជា តាដែក តាខ្វាវ តាហ៊ុន និងយាយគោ ចំណែកដៃគូរួមជំនាន់មានដូចជា តាដំបងដែក តាដំបងគ្រញូង តាឃ្លាំងមឿង និងយាយម៉ៅ ។ ចំពោះលក្ខណៈភិនភាគតាខ្មៅមានមាឌធំក្រអាញរាងចង្វាមូល កាន់ដំបង គ្រញូង ពាក់អាវកាក់វែងមន្តស្លៀកខោចែវជើងខ្លី ក្រវាត់ចង្កេះក្រមាយ័ន្ត ជូតក្បាលក្រមាមានវង់តក្តែម៉ឹងម៉ាត់ និងមានពុកមាត់ក្រាស់។ ក្នុងរជ្ជកាល នោះតាខ្មៅក៏បានកសាងចេតីយមួយយ៉ាងធំនៅ ទីដែលគាត់កាន់កាប់សម្រាប់តម្កល់អដ្ឋិធាតុវីរបុរសអ្នកស្នេហាជាតិ និងសម្រាប់ជាកេរតំណែលទៅថ្ងៃខាងមុខ។

ឧបរាជខ្មៅ«**តាខ្មៅ**»គ្មានប្រពន្ធកូនទេគឺរស់នៅជាកម្លោះរហូតដល់អស់ជីវិត ព្រោះវិតវល់គិតគូរឿងប្រទេសជាតិតែម្យ៉ាងប៉ុណ្ណោះ ។ ក្រោយពីលោកតាខ្មៅ មរណៈភាពទៅវិញ្ញាណក្ខ័ន្ធរបស់គាត់មិនឃ្លាតទៅណាឆ្ងាយទេ គឺស្ថិតនៅក្នុងទីអារាមវត្តតាខ្មៅ ។ ហេតុដូច្នោះហើយតាំងពីកាលនោះមក ទីតំបន់ដែលគាត់ធ្លាប់រស់នៅក៏មានឈ្មោះថា៖ ភូមិតាខ្មៅ សង្កាត់តាខ្មៅ ក្រុង តាខ្មៅ ខេត្តកណ្តាលជាប់រហូតមកដល់ បន្តប្បន្ននេះ ៕

យោងឯកសារ *សាលាក្រុង តាខ្មៅ*

ការទម្លាក់គ្រាប់បែកបរមាណូអាមេរិក លើទីក្រុងហ៊ីរ៉ូស៊ីម៉ា និងទីក្រុងណាហ្គាសាគី បានបង្កឲ្យមានមហាវិនាសកម្មយ៉ាងធ្ងន់ធ្ងរ

កាលពី ៧០ឆ្នាំមុន នៅថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៤៥ វេលាម៉ោង ៨ និង ១៥នាទីព្រឹក គ្រាប់បែកនុយក្លេអ៊ែរទីមួយ (ដែលគេឲ្យឈ្មោះថា « Little Boy ») ត្រូវបានអាមេរិកទម្លាក់ពីលើយន្តហោះទៅលើទីក្រុងហ៊ីរ៉ូស៊ីម៉ាដែលបានសម្លាប់ប្រជាជនជប៉ុន១៤០.០០០នាក់ និង ៣ថ្ងៃក្រោយមក នៅថ្ងៃទី៩ សីហា អាមេរិកបានទម្លាក់គ្រាប់បែកនុយក្លេអ៊ែរមួយគ្រាប់ទៀត (ដែលគេឲ្យឈ្មោះថា « Fat Man ») ទៅលើទីក្រុងណាកាសាគី ដែលបានសម្លាប់មនុស្ស៧៤.០០០នាក់ (ដោយមិនទាន់រាប់អ្នកស្លាប់ក្រោយៗមកទៀត ដោយសារជាតុវិទ្យុសកម្ម)។ នៅថ្ងៃទី១៥ សីហា អធិរាជហ៊ីរ៉ូហ៊ីតូក៏បានប្រកាសចុះចាញ់សង្គ្រាមដោយឥតលក្ខខណ្ឌ។ តាមការពិត នៅមុនការទម្លាក់គ្រាប់បែកនុយក្លេអ៊ែរនៅហ៊ីរ៉ូស៊ីម៉ា និងណាហ្គាសាគី សង្គ្រាមលោកលើកទី២ បានឈានជិតមកដល់ទីបញ្ចប់រួចជាស្រេចទៅហើយ ដោយកងទ័ពក្រហមសហភាពសូវៀតបានវាយសម្រុកចូលទីក្រុងប៊ែរឡាំង ចំណែកហ៊ីត្លែរបានធ្វើអត្តឃាត នៅថ្ងៃទី២ ខែឧសភា ឆ្នាំ ១៩៤៥ ។ ថ្ងៃទី ០៩ សីហា ១៩៤៥ កងទ័ពសូវៀតបានវាយសម្រុកចូលតំបន់ឦសាននៃប្រទេសចិនកម្ទេចអង្គភាពទ័ពស្រួចខាងកើតរបស់ជប៉ុន។ ឆ្លៀតឱកាសជ័យជម្នះ ថ្ងៃទី ១១ ខែសីហា ឆ្នាំ ១៩៤៥ កងទ័ពរំដោះប្រជាជនចិន បានវាយសម្រុកកងទ័ពជប៉ុននៅប្រទេសចិនភាគខាងជើងភាគកណ្តាល រហូតដល់ភាគខាងត្បូង។ នៅពាក់កណ្តាលឆ្នាំ ១៩៤២ អាមេរិកចាប់ផ្តើមវាយសម្រុកមកលើកងទ័ពជប៉ុនដោយរបៀបវាយជាបណ្តើរៗ។ ពេលឃើញសហភាពសូវៀតចូលរួមក្នុងសង្គ្រាមនៅចុងបូព៌ា និងនៅប្រទេសចិន អាមេរិក ប្រញាប់ប្រញាល់ទម្លាក់គ្រាប់បែក២គ្រាប់ទៅលើប្រទេសជប៉ុន។ ឧបាយកលក្លែងបន្លំរបស់អាមេរិកសំដៅបង្កឡើងនូវចិត្តសាស្ត្រមួយហាក់ដូចជា អាមេរិកជាអ្នកជើរតួកំណត់ក្នុងជ័យជម្នះលើហ្វាសស៊ីសជប៉ុន។ ទន្ទឹមនឹងនោះ ទង្វើរបស់អាមេរិកគឺ សំដៅសម្តែងកម្លាំងអាវុធនុយក្លេអ៊ែរគំរាមកំហែងប្រជាជននៃប្រទេសទាំង ឡាយលើសកលលោក។ មេដឹកនាំអាមេរិកបានធ្វើការពន្យល់ថា ការសម្រេចប្រើអាវុធនុយក្លេអ៊ែរទៅលើជប៉ុននៅពេលនោះ គឺដើម្បីអាចបញ្ចប់សង្គ្រាមឲ្យបានឆាប់ ដោយមិនចាំបាច់បញ្ជូនកម្លាំងទ័ពធម្មតាឲ្យចូលឈ្លានពានប្រទេសជប៉ុន ដែលគេព្យាករណ៍ថា អាចនឹងបណ្តាលឲ្យទាហានអាមេរិកស្លាប់រហូតដល់ទៅ១លាននាក់ ដោយសារតែគេមើលឃើញពីភាពប្តូរផ្តាច់របស់ទាហានជប៉ុន នៅក្នុងសមរភូមិមុនៗ ជាពិសេស នៅកោះអ៊ីវ៉ូជីម៉ា និងអូគីណាវ៉ា ដែលកងទ័ពជប៉ុន ថ្វីដ្បិតតែទទួលបរាជ័យ តែបានបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរបំផុតដល់កងទ័ពអាមេរិក។ ក៏ប៉ុន្តែហេតុផលដែលមេដឹកនាំអាមេរិកបានលើកឡើងនេះ មិនបានធ្វើឲ្យគ្រប់គ្នាទទួលយកនោះទេ ដោយមានមនុស្សជាច្រើនរួមទាំងប្រជាជនអាមេរិកខ្លួនឯងផងយល់ថា ការទម្លាក់គ្រាប់បែកនុយក្លេអ៊ែរសម្លាប់ជនស៊ីវិលរាប់មឺននាក់ នៅហ៊ីរ៉ូស៊ីម៉ា និងណាហ្គាសាគី វាមិនមែនជារឿងចាំបាច់។ អ្នកប្រវត្តិសាស្ត្រជាច្រើន ទាំងអ្នកប្រវត្តិសាស្ត្រជប៉ុន អាមេរិក និងអង់គ្លេស បាននាំគ្នាធ្វើការកត់សម្គាល់ថា ប្រសិនបើជប៉ុនចុះចាញ់ដោយសារតែខ្លាចអាវុធនុយក្លេអ៊ែររបស់អាមេរិកមែននោះ ជប៉ុនគួរតែចុះចាញ់ភ្លាមៗតាំងពីក្រោយការ ទម្លាក់គ្រាប់បែកនៅហ៊ីរ៉ូស៊ីម៉ា នៅថ្ងៃទី៦សីហា ឬក្រោយណាហ្គាសាគី នៅថ្ងៃទី៩សីហា។ ផ្ទុយទៅវិញ រហូតទាល់តែដល់ថ្ងៃទី១៥សីហា គឺនៅក្រោយពីជប៉ុនត្រូវទទួលបរាជ័យជាបន្តបន្ទាប់នៅលើសមរភូមិទល់នឹងកងទ័ពសូវៀតនៅកូរ៉េ និងម៉ាន់ជូរី ទើបអធិរាជជប៉ុនប្រកាសចុះចាញ់សង្គ្រាម។ ហេតុដូច្នេះហើយបានជាគេសន្និដ្ឋានថា ការទម្លាក់គ្រាប់បែកនុយក្លេអ៊ែរនៅហ៊ីរ៉ូស៊ីម៉ា និងណាហ្គាសាគី វាមិនមែនជារឿងចាំបាច់ ដើម្បីបញ្ចប់សង្គ្រាមនោះទេ ៕

(តាមឯកសារបរទេស)

ទឹកឃ្មុំមានប្រយោជន៍ចំពោះស្ត្រីមានផ្ទៃពោះ តែវាក៏ផ្តល់ផលអាក្រក់ដែរ

ទឹកឃ្មុំ មានរសជាតិផ្អែមបែបធម្មជាតិល្អសម្រាប់សុខភាពនិងពោរពេញទៅដោយសារធាតុចិញ្ចឹម។ មនុស្សគ្រប់រូបទាំងចាស់និងក្មេង សុទ្ធតែអាចទទួលបានប្រយោជន៍ពីទឹកឃ្មុំតាមវិធីផ្សេងៗគ្នា ប៉ុន្តែតើអាហារផ្អែមប្រភេទនេះ អាចប៉ះពាល់ដល់សុខភាពដែរឬទេ? ចុះតើទឹកឃ្មុំល្អសម្រាប់សុខភាពស្ត្រីដែលកំពុងពរពោះដែរឬទេ ? សូមបន្តអានប្រសិនបើលោកអ្នកចង់ដឹងកាន់តែច្បាស់ អំពីគុណប្រយោជន៍របស់ទឹកឃ្មុំ៖

ទឹកឃ្មុំ ល្អ និងមានសុវត្ថិភាពចំពោះស្ត្រីដែលកំពុងមានផ្ទៃពោះ ប្រសិនបើវាត្រូវបានសម្លាប់មេរោគត្រឹមត្រូវ ហើយវាគួរតែជាប្រភេទទឹកឃ្មុំដែលទទួលស្គាល់ពីអាជ្ញាធរពាក់ព័ន្ធ។ កត្តាតែមួយគត់ដែលគួរឱ្យបារម្ភអំពីទឹកឃ្មុំធម្មជាតិ គឺវាអាចធ្វើឱ្យអ្នកទទួលទានវាពុលបាន។

ប៉ុន្តែ វាអាចប៉ះពាល់ដល់ទារកដែលមានអាយុតិចជាង ១ឆ្នាំ ព្រោះប្រព័ន្ធរំលាយអាហាររបស់ពួកគេនៅក្មេងមិនទាន់ដំណើរការល្អ ។ ទឹកឃ្មុំមានអត្ថប្រយោជន៍មួយចំនួនសម្រាប់ស្ត្រីកំពុងមានផ្ទៃពោះ ព្រោះសម្បូរជាតិស្ករធម្មជាតិ ក៏ដូចជីវជាតិចិញ្ចឹមជាច្រើន។

១.ជំរុញប្រព័ន្ធភាពស៊ាំ៖ សារធាតុប្រឆាំងជាតិពុល និងបាក់តេរីរបស់ទឹកឃ្មុំជួយជំរុញប្រព័ន្ធភាពស៊ាំរបស់រាងកាយឱ្យរឹងមាំ ។ ទឹកឃ្មុំក៏ជួយព្យាបាលរបួសការរលាកតិចតួចនិងអាការៈឆ្អល់ពោះតាមរយៈការគ្រប់គ្រងជាតិអាស៊ីតនៅក្នុងក្រពះ។

២.ជួយសម្រួលដល់អាការៈគេងមិនលក់៖ ទឹកឃ្មុំជួយឱ្យស្ត្រីមានផ្ទៃពោះ គេងលក់ស្រួល។ ការផឹកទឹកដោះគោ លាយជាមួយទឹកឃ្មុំមួយស្លាបព្រាមុនពេលចូលគេង អាចជួយឱ្យគេងលក់ស្រួល។

៣.ព្យាបាលជំងឺក្អក និងផ្តាសាយ៖ សារធាតុប្រឆាំងនឹងវីរុសរបស់ទឹកឃ្មុំ ជួយការពាររាងកាយយើងពីជំងឺក្អក និងផ្តាសាយ។ ទឹកឃ្មុំជាថ្នាំព្យាបាលជំងឺក្អកដ៏ស័ក្តិសិទ្ធ។

៤.បំបាត់អាការៈឈឺក៖ សារធាតុប្រឆាំងនឹងជំងឺរលាករបស់ទឹកឃ្មុំ ជួយកាត់បន្ថយ និងព្យាបាលអាការៈឈឺក្នុងបំពង់ក។ បន្ថែមទឹក

ឃ្មុំចូលទៅក្នុងទឹកតែខ្ចី ឬតែក្រូចឆ្មាក្តៅឧណ្ហៗ អាចកាត់បន្ថយការឈឺបំពង់ក។

៥.ជួយឱ្យស្បែកក្បាលមានសុខភាពល្អ៖ សារធាតុប្រឆាំងនឹងបាក់តេរីពីធម្មជាតិរបស់ទឹកឃ្មុំ មិនត្រឹមតែជួយព្យាបាលអាការៈឈឺបំពង់កនោះទេ ប៉ុន្តែវាក៏អាចព្យាបាលបញ្ហាអង្គែរ និងការរម៉ាស់នៅ លើស្បែកក្បាលផងដែរ។ គ្រាន់តែលាយទឹកឃ្មុំជាមួយទឹកក្តៅឧណ្ហៗ រួចលាបវានៅលើស្បែកក្បាល នោះវានឹងអាចជួយឱ្យស្បែកក្បាលមានសុខភាពល្អឡើងវិញ។

៦.កាត់បន្ថយការប្រតិកម្ម៖ ទឹកឃ្មុំជួយគ្រប់គ្រងអាការៈប្រតិកម្មតាមរដូវកាល ដូចជាប្រតិកម្មជាមួយលំអងផ្កា ឬធូលីដីជាដើម ព្រោះវាជួយឱ្យប្រព័ន្ធភាពស៊ាំរបស់រាងកាយរឹងមាំ។

ចំណុចគួរកត់ចំណាំ! ការញ៉ាំទឹកឃ្មុំច្រើនហួសកម្រិត ក៏អាចនាំឱ្យប៉ះពាល់ដល់សុខភាពដែរ៖

- ការប្រែប្រួលអាំងស៊ុយលីនហួសកម្រិត៖ ទឹកឃ្មុំអាចធ្វើឱ្យកម្រិតជាតិស្ករនៅក្នុងឈាមឡើងហួសកម្រិត និងប្រព័ន្ធគ្រប់គ្រងអាំងស៊ុយលីនចុះខ្សោយ។ ចំណុចនេះ ក៏នឹងធ្វើឱ្យប៉ះពាល់ដល់ស្ត្រីមានផ្ទៃពោះដែរ ប្រសិនបើញ៉ាំសារធាតុហ្វ្រាំចូស ដែលមាននៅក្នុងទឹកឃ្មុំលើស២៥ក្រាមក្នុងមួយថ្ងៃ។
- ប៉ះពាល់ដល់សុខភាពមាត់ធ្មេញ៖ កម្រិតជាតិស្ករនៅក្នុងទឹកឃ្មុំ អាចធ្វើឱ្យធ្មេញពុក និងដង្កូវស៊ី។
- ឡើងទម្ងន់៖ សារធាតុថាមពលនៅក្នុងទឹកឃ្មុំ អាចធ្វើឱ្យស្ត្រីមានផ្ទៃពោះឡើងទម្ងន់ខ្លាំង។

ដូច្នេះ តើនៅក្នុងអំឡុងពេលមានផ្ទៃពោះ អាចផឹកទឹកឃ្មុំបានប៉ុន្មាន? ចម្លើយគឺ ពី៣ទៅ៥ស្លាបព្រាបាយ ក្នុងមួយថ្ងៃ គឺល្អ និងមិនធ្វើឱ្យប៉ះពាល់ដល់សុខភាពស្ត្រីមានផ្ទៃពោះទេ ព្រោះទឹកឃ្មុំ១ស្លាបព្រាបាយ មានផ្ទុកថាមពលជាមធ្យម៦០កាឡូរីប៉ុណ្ណោះ៕

វឌ្ឍនភាពនៃស្រុកអូររាំងឪ.... សូមអរគុណសន្តិភាព!!

*លោក **ងួន ប៊ុណ្ណាន** អភិបាលនៃគណៈអភិបាលស្រុកអូររាំងឪ អញ្ជើញចុះពិនិត្យការដ្ឋានសាងសង់ផ្លូវនៅក្នុងមូលដ្ឋាន*

នៅក្រោម**ពន្លឺនៃសន្តិភាព** ដែលមានគណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជាដឹកនាំប្រទេស បានធ្វើឲ្យមាតុភូមិកម្ពុជាកាន់តែមានការអភិវឌ្ឍ ប្រជាជនកម្ពុជាគ្រប់ៗរូបមានសុខសុភមង្គល មានសិទ្ធិសេរីភាព និងបានរស់នៅប្រកប ដោយភាពសុខដុមរមនាយ៉ាងក្រៃលែង ។ គ្រប់មូលដ្ឋានភូមិ ឃុំ ស្រុកសុទ្ធតែមានការប្រែប្រួលមុខមាត់ថ្មីពីមួយថ្ងៃទៅមួយថ្ងៃ ដែលធ្វើឲ្យយើងកាន់តែមានមោទនភាពចំពោះការរីកចម្រើននេះ និងសូមសម្ដែងការគោរពដឹងគុណ កោតសរសើរ ផ្ដល់ជំនឿទុកចិត្តកាន់តែរឹងមាំឡើង ចំពោះមគ្គុទេសក៍ដ៏ឆ្នើមរបស់គណបក្សយើង ។ និយាយអំពីការអភិវឌ្ឍនៅមូលដ្ឋាន យើងនឹងអធិប្បាយរៀបរាប់ឲ្យឃើញអំពីសមិទ្ធផលដែលសម្រេចបាននៅស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ។

ស្រុកអូររាំងឪ ជាទឹកដីមួយសំបូរទៅដោយដំណាំ កៅស៊ូ ពោត សណ្ដែក រួមទាំងបន្លែបង្កាផ្សេងទៀត ប៉ុន្តែមុខរបរធ្វើស្រែចម្ការក៏បានផ្ដល់នូវភោគផលគួរជាទីគាប់ចិត្តជារៀងរាល់ឆ្នាំ ។ ស្រុកអូររាំងឪ ជាស្រុកមួយក្នុងចំណោមក្រុង-ស្រុកទាំង ៧ នៃខេត្តត្បូងឃ្មុំ ដែលមានព្រំប្រទល់ខាងជើងទល់នឹងស្រុកត្បូងឃ្មុំ ខាងត្បូងទល់នឹងស្រុកកញ្ជៀចខេត្តព្រៃវែង ខាងកើតទល់ នឹងស្រុកពញាក្រែកនិងខាងលិចទល់ នឹងស្រុកស៊ីធកណ្ដាលខេត្តព្រៃវែង និងស្រុកកោះសូទិន ខេត្តកំពង់ចាម ដោយមានផ្ទៃដីសរុប ៣២០,៥៤គីឡូម៉ែត្រការ៉េ មាន ៧ ឃុំ និង ១៤២ ភូមិមានប្រជាពលរដ្ឋសរុប ១០១.៤៨៨នាក់ស្រី ៥២.៦៩៥នាក់ ស្មើនឹង ២២.៧៤២គ្រួសារ ។ ប្រជាពលរដ្ឋចំនួន ៨១% ប្រកបរបរកសិកម្ម ៨% ប្រកបរបរសិប្បកម្ម និង ១៨,២% ប្រកបរបរសេវាកម្ម ។ លោក **ងួន ប៊ុណ្ណាន** អភិបាលនៃគណៈអភិបាល ស្រុកអូររាំងឪ បានគូសបញ្ជាក់អំពីកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំស្រុក ឃុំ ភូមិ ដោយមានការជួយពីក្រុមការងារដែលបានរួមចំណែកយ៉ាងសកម្ម ក្នុងការកសាងមូលដ្ឋានស្រុកអូររាំងឪ ។ ថ្វីបើមានបញ្ហាប្រឈមដោយសារជំងឺកូវីដ-១៩ ដែលធ្វើឲ្យប៉ះពាល់ទៅដល់វិស័យមួយចំនួន ក៏ដូចជាប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជន មួយផ្នែកក៏ពិតមែន ប៉ុន្តែអាស្រ័យដោយស្មារតី និងឆន្ទៈរបស់មន្ត្រីគ្រប់លំដាប់ថ្នាក់នៅក្នុងស្រុក និងការខិតខំរបស់ប្រជាជន យើងបានជម្នះនូវរាល់ឧបសគ្គទាំងឡាយ ធានាបាននូវស្ថិរភាព និងប្រក្រតីភាពនៃជីវភាពរបស់ប្រជាជន ដែលកំពុងរស់នៅក្នុងស្រុកអូររាំងឪ ។

នៅក្នុងរដូវបង្កបង្កើនផលរដូវវស្សា ឆ្នាំ ២០១៩- ២០២០កន្លងទៅ ការងារកសិកម្មក្នុងមូលដ្ឋានស្រុកអូររាំងឪ គឺល្អបង្គួរ ។ ទោះបីជាឆ្នាំនេះការងារបង្កបង្កើនផលដំណាំស្រូវវស្សាបានជួបប្រទះបញ្ហាគ្រោះទឹកជំនន់ទន្លេ មេគង្គ និងគ្រោះរាំងស្ងួតក៏ដោយតែដំណាំស្រូវវស្សាឆ្នាំនេះទទួលបាន ទិន្នផលខ្ពស់ជាងឆ្នាំមុន ហើយតម្លៃវិញក៏សមរម្យ ។ ចំណែកឯដំណាំចំការក្នុងឆ្នាំនេះ មិនមានបញ្ហាច្រើនទេ ដោយសារតែមន្ត្រីជំនាញតែងតែចុះណែនាំបច្ចេកទេស និងរៀបចំផែនការដាំដុះជាប្រចាំជូនក្រុមកសិករ ។

ការងារចិញ្ចឹមសត្វឆ្នាំនេះ ជួបប្រទះបញ្ហាជំងឺប៉េស្តជ្រូកអាហ្វ្រិក ជាហេតុបណ្ដាលឲ្យកសិករមួយចំនួនធំមានការខាតបង់ថវិកាជាច្រើនលើការងារចិញ្ចឹមជ្រូក ។ រីឯការងារចិញ្ចឹមសត្វផ្សេងទៀត ដូចជាមាន់ស្រែ ទា គោ ក្របី ពពែ មិនមានបញ្ហានោះទេ ព្រមទាំងមានតម្លៃខ្ពស់ផងដែរ ។ ផ្នែកដំណាំស្រូវ ផ្ទៃដីដាំដំណាំស្រូវសរុបចំនួន ១៧.៣៥០ហ.ត ក្នុងនោះផ្ទៃដីដាំដំណាំស្រូវវស្សាចំនួន ១៦.០០០ហ.ត ផ្ទៃដីដាំដំណាំស្រូវប្រាំងមានចំនួន ១.៣៥០ហ.ត ។ ការងារអនុវត្តដំណាំស្រូវ

ការកសាងហេដ្ឋារចនាសម្ព័ន្ធឆ្លងកាត់ពីឃុំមួយទៅឃុំមួយនៅក្នុងស្រុកអូររាំងឪ

វស្សា ផ្ទៃដីដាំដុះសរុបចំនួន ១៦.០០០ហ.ត ភ្ជួររាស់ដោយគ្រឿងយន្ត ១០០% ។ ការងារអនុវត្តលើដំណាំស្រូវវស្សា គឺបានចំនួន ១៦.០០០ហ.ត ស្មើនឹង ១០០% នៃផ្ទៃដីដាំដុះសរុប ។ ផ្ទៃដីពង្រោះរួមមាន: ពង្រោះដំណាំស្រូវស្រាល និងស្រូវបង្កើនរដូវ ចំនួន ១.៥០០ ហ.ត ប្រមូលផលបានចំនួន ១.៥០០ហ.ត ស្មើនឹង ១០០% ទិន្នផលជាមធ្យមបាន ៤,២តោន/ហ.ត ។ ពង្រោះដំណាំស្រូវកណ្តាល បានចំនួន ១០.០០០ហ.ត ប្រមូលផលបានទាំងចំនួន ១០.០០០ហ.ត ស្មើនឹង ១០០% ទិន្នផលជាមធ្យមបាន ៣,៨តោន/ហ.ត ។ ពង្រោះដំណាំស្រូវធ្ងន់បានចំនួន ៤.៥០០ ហ.ត ប្រមូលផលបានចំនួន ៣.៥០០ហ.ត ស្មើនឹង ៧៧,៧៧% ទិន្នផលជាមធ្យមបាន ៣,៩តោន/ហ.ត ។ ការងារអនុវត្តបានលើដំណាំស្រូវប្រាំង ផ្ទៃដីដាំដុះសរុបចំនួន ១.៣៥០ហ.ត ភ្ជួររាស់ដោយគ្រឿងយន្តបានចំនួន ៨៦០ហ.ត ពង្រោះដំណាំស្រូវប្រាំងបានចំនួន ១.៣៥០ហ.ត ស្មើនឹង ១០០% ។ ផ្នែកដំណាំចំការ និងបន្លែ ផ្ទៃដីដាំដុះដំណាំចំការសរុប ១.៦៦០ហ.ត ដែលក្នុងនោះផ្ទៃដីដាំដុះដំណាំចំការដូវវស្សាមានចំនួន ១. ៦៤០ ហ.ត ផ្ទៃដីដាំដុះដំណាំបន្លែដូវប្រាំងចំនួន ២០ហ.ត ។ ការងារអនុវត្តដំណាំចំការដូវវស្សា រួមមាន ៖ ផ្ទៃដីដាំដុះសរុបចំនួន ១.៦៤០ហ.ត ភ្ជួររាស់ដោយគ្រឿងយន្ត ១០០% ។ មុខដំណាំចំការដែលអនុវត្ត បានសរុបចំនួន ១.៦៤០ហ.ត ស្មើនឹង ១០០% ។ នៅក្នុងស្រុកអូររាំងឪមានសហគមន៍កសិកម្មចំនួន ២ គឺ សហគមន៍មានជ័យ មានសមាជិក ១៣២គ្រួសារអនុវត្តលើការដាំដុះដំណាំស្រូវលើផ្ទៃដី ១៣៥ហ.ត និងសហគមន៍អូររាំងឪ-មានជ័យ មានសមាជិកចំនួន ៤២គ្រួសារ អនុវត្ត លើការដាំដុះដំណាំបន្លែលើផ្ទៃដី ១៧, ១២ហ.ត ។ ដោយឡែកការងារគ្រឿងយន្តកសិកម្មនៅ ក្នុងមូលដ្ឋានស្រុកអូររាំងឪមានត្រាក់ទ័រធន់មធ្យម និងធន់ធំចំនួន ១១៦គ្រឿង គោយន្តមាន ១.៤៥១គ្រឿង ម៉ាស៊ីនបូមទឹកខ្នាតតូច ១.៧៩២គ្រឿង ម៉ាស៊ីនច្រូតស្រូវ ៦០គ្រឿង ម៉ាស៊ីនបោកស្រូវ ២៥គ្រឿង ម៉ាស៊ីនសម្ងួតស្រូវ ៦គ្រឿង ម៉ាស៊ីនកិនស្រូវ

*លោក **ជា ឈុន***

ខ្នាតតូច ៣៥៥គ្រឿង និងខ្នាតធំ ៩គ្រឿង ។ វិស័យ ធារាសាស្ត្រក៏ត្រូវបានយកចិត្តទុកដាក់ដើម្បីដោះស្រាយបញ្ហាទឹក និងផ្គត់ផ្គង់ទឹកបម្រើឲ្យការងារបង្កបង្កើនផលមិនឲ្យចោទជាបញ្ហាលំបាកណាមួយឡើយ ។

ផ្លូវគមនាគមន៍ត្រូវបានអាជ្ញាធរស្រុកឈូសឈុលយ៉ាងសកម្មធ្វើការស្ថាបនា ឆ្លង កាត់ពីឃុំមួយ ទៅឃុំមួយ ពីភូមិមួយទៅភូមិមួយ ដូចសសៃឈាម ដែលបានតភ្ជាប់គ្នានៅក្នុងសេរីរាង្គមនុស្ស បង្កលក្ខណៈសម្បត្តិជូនប្រជាជន ធ្វើចរាចរណ៍ឆ្លងកាត់ ដឹកជញ្ជូនកសិផលទៅលក់ដូរនៅតាមទីផ្សារបានងាយស្រួល កាត់បន្ថយការចំណាយ បំព្រួញបានពេលវេលាធ្វើដំណើររួមចំណែកបានយ៉ាងច្រើនក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។ លោក **ជា ឈុន** អាយុ ៥១ឆ្នាំ ជាកសិករ រស់នៅភូមិស្រែស្តៅ ឃុំគងជ័យ ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ប្រកបមុខរបរធ្វើស្រែចំការ បានឲ្យដឹងថា ជារៀងរាល់ឆ្នាំលោកតែងតែប្រកបរបរធ្វើស្រែ ដោយទទួលបានភោគផលគួរជាទីគាប់ប្រសើរ ។ សព្វថ្ងៃនេះ ជីវភាពគ្រួសាររបស់លោកមានភាពធូរធារមិនលំបាកដូចពីមុនៗទៀតទេ។ និយាយដល់ចំណុចនេះ លោកបានសម្តែងការដឹងគុណយ៉ាងក្រៃលែងចំពោះគណបក្សប្រជាជនកម្ពុជា និងរាជ-រដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំរបស់**សម្តេច-តេជោ ហ៊ុន សែន** ដែលមិនត្រឹមតែជួយសង្គ្រោះប្រទេសជាតិ និង ប្រជាជនឲ្យរួចផុតរបបប្រល័យពូជសាសន៍នាំយកប្រទេសចេញពីភ្នក់ភ្លើងសង្គ្រាមមកកាន់សុខសន្តិភាព ប៉ុន្តែបានដឹកនាំ ប្រទេសជាតិឲ្យមានការអភិវឌ្ឍរហូតមកដល់សព្វថ្ងៃ ។ ក្រោមពន្លឺនៃសុខសន្តិភាព បានធ្វើឲ្យជីវភាពរបស់លោក **ជា ឈុន** និយាយដោយឡែក និងនិយាយជារួមគឺជីវភាពរបស់ប្រជាជននៅ ស្រុកអូររាំងឪ និង

ចំការបន្លែរបស់ប្រជាកសិករនៅ ឃុំទួលសុគី

ផ្លូវគមនាគមន៍ឆ្លងកាត់ភូមិសាស្ត្រស្រុកអូររាំងឪ

*លោក **ស៊ិន អាត***

*លោកស្រី **យិន សុភាព***

នៅទូទាំងប្រទេសកាន់តែមានការរីកចម្រើនជាលំដាប់ ។ លោក **ស៊ិន អាត** អាយុ ៦២ឆ្នាំ ជាកសិកររស់នៅភូមិដូនទេស ឃុំទួលសុគី ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ ប្រកបមុខរបរដាំបន្លែវិលជុំចំនួន ៤ប្រភេទ គឺ ស្ពៃចង្កឹះ សាឡាត់ ត្រសក់ និងសណ្តែកគួរ.... បានឲ្យដឹងថា លោកមានក្តីសប្បាយរីករាយជាមួយនឹងមុខរបរនេះណាស់ ពីព្រោះវាបានផ្តល់ផលប្រយោជន៍ជាប្រាក់កាសគ្រប់គ្រាន់ សម្រាប់ទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ មិនចាំបាច់ធ្វើចំណាកស្រុក ឃ្លាតឆ្ងាយក្រុមគ្រួសារ និងឃ្លាតឆ្ងាយពីភូមិដ្ឋាន ។ លោកសូមសម្តែងការអរគុណខ្លាំងណាស់ ចំពោះសន្តិភាពដែលកំពុងគ្របដណ្តប់ទឹកដីកម្ពុជា ។ បើគ្មានសន្តិភាពទេ យើងក៏គ្មានឱកាសដើម្បីកសាងសុភមង្គលក្នុងគ្រួសាររបស់យើងដែរ ។ យើងបានឆ្លងកាត់បទពិសោធន៍ទាំងអស់នេះហើយ ។ លោក **ស៊ិន អាត** បានថ្លែងជាចុងក្រោយថា ៖ សូមអរគុណសន្តិភាព! ។ ដោយឡែក លោកស្រី **យិន សុភាព** អាយុ ៤០ ឆ្នាំ ប្រជាពលរដ្ឋរស់នៅភូមិថ្មដា ឃុំទួលសុគី ស្រុកអូររាំងឪ ខេត្តត្បូងឃ្មុំ មុខរបរជាអ្នកលក់ដូរអីវ៉ាន់ចាប់ហួយ ក៏មានប្រសាសន៍ដែរថា ពីមួយឆ្នាំទៅមួយឆ្នាំជីវភាពរបស់គ្រួសារអ្នកស្រីកាន់តែមានការប្រែប្រួលជាលំដាប់ ។ ចំណូលពីមុខរបរនេះតិចតួចមែន ប៉ុន្តែចូលជាប់ជាប្រចាំវាអាចជួយគាំពារជីវភាពរស់នៅរបស់គាត់ ។ អ្នកស្រីបានបញ្ជាក់ជាចុងក្រោយថា ៖ ខ្ញុំគាំទ្រជានិច្চគណបក្សប្រជាជនកម្ពុជា ដើម្បីដឹកនាំប្រទេសយូរអង្វែងតទៅ ។

អ្នកដែលបាន ទៅដល់ទឹកដីអូររាំងឪនាដូវវស្សានេះ ពិតជាបានឃើញនឹងភ្នែកនូវសម្រស់ ដ៏ស្រស់ត្រកាលនៃធម្មជាតិដ៏ខៀវស្រងាត់ ដែលលិចអណ្តែតឡើងជាមួយនឹងចំការកៅស៊ូដ៏ធំល្វឹងល្វើយដំណាំស្រូវនៅតាមវាលស្រែ និងចំការបន្លែដែលមានផ្លែ មានផ្កា ស្កែកស្គុះនៅតាមទ្រើង និងរងដំណាំគួរជាទីទាក់ភ្នែក ។ លោក **ងួន ប៊ុណ្ណាន** អភិបាលនៃគណៈអភិបាលស្រុកអូររាំងឪ បានសម្តែងនូវក្តីសង្ឃឹមថា ស្រុកនេះនៅតែបោះជំហានលូតលាស់ទៅមុខទៀត យ៉ាងលឿនក្រោមពន្លឺនៃសន្តិភាព ៕

ភ្ជុំបិណ្ឌ

១. យប់ដប់ប្រាំកើត ខែភទ្របទ	កំណត់សូត្រមន្ត ផ្តើមបុណ្យភ្ជុំ
ជាពិធីបុណ្យ មួយដ៏ធំ	ប្រជានិយម រួមការពារ ។
២. គ្រប់វត្តអារាម រែងអ៊ូអរ	បរិស័ទកុះករ កបសទ្ធា
នារី យុវជន ចាស់ជរា	ម្ហូម្ហាទៅវត្ត អត់អល់អែក ។
៣. ម៉ោងបួនទៀបភ្លឺ មេឃសល្អះ	មិនទាន់ភ្លឺច្បាស់ អ្នកស្ទូត្រស្រែក
រៀបរាប់ទោសទុក្ខ ទំនួញប្រេត	សង្វេគពន់ពេក ដង្ហោយហៅ ។
៤. ថាខ្លួនមានបាប ធ្លាក់អបាយ	ឈឺចាប់ចិត្តកាយ ចូរកូនចៅ
សាច់ញាតិសន្តាន ពូជពង្សដៅ	ចៅរ៉ៅធ្វើបុណ្យ រំដោះកម្ម ។
៥. ព្រមទាំងធ្វើទាន ម្ហូបអាហារ	ព្រះសង្ឃសូត្រដារ តាមចំណាំ
រួចឧទ្ទិសជូន ខ្លួនរង់ចាំ	មោទនាកម្ម ទទួលបាន ។
៦. ហូបម្ហូបអាហារ នំគ្រប់មុខ	ឆ្អែតរួចទោសទុក្ខ ទាំងប៉ុន្មាន
ជុតពីនរក ប្រេត តិរច្ឆាន	ទៅបិតទីឋាន បានសុខា ។
៧. បន្តព្រះសង្ឃ សូត្ររំលឹក	រៀងរាល់ពេលព្រឹក ធម៌បវរ
ប្រាប់ក្តីវិនាស ១២ប្រការ	គ្រប់គ្នាស្តាប់ កាន់យកជាគុណ ។
៨. បុណ្យភ្ជុំគោលធំ ឧទ្ទិសផល	ជូនដល់ បុព្វការីជន
ក្រែងចិញ្ចឹមកូន ប៉ះបាបធ្ងន់	សិយសុិន នរក ឬសូគ៌ ។
៩. ធ្វើម្តេចដឹងបាន ដោយប្រាកដ	សន្មត់ធ្វើតាម ចិត្តសទ្ធា
តាមពុទ្ធតម្រាស់ ត្រាស់ធម្មា	អង្គព្រះភគវា សម្តែងទុក ។
១០. គ្រប់ដងប្រាំថ្ងៃ វត្តអត់ស្ងាត់	បរិស័ទស្អាត់ទៅទីភូមិស្រុក
ជួបជុំបងប្អូន ម្តាយឪពុក	សម្រុកធ្វើបុណ្យ បវរណី ។
១១. អន្សម នំគម នំក្រពង	ផ្លែផ្លាផង ម្ហូបចំណី
រាប់បាត្របង្ហុកូល តាមចេតិយ	ឯកជនរួមក្តី ផ្សាយកុសល ។
១២. អានិសង្សបានសាង សព្វសទ្ធា	ភតានុមោទនា បញ្ជូនដល់
បុព្វបេតបុគ្គល ទទួលផល	ស្កប់ស្កល់ផ្តល់ពរ សាធុជន ។
១៣. ចូរពូនភ្នំខ្សាច់ រួចស្រង់ព្រះ	ទេវតានៅផ្ទះ កបគុណធ្ងន់
ផ្ងូតទឹកជូនបច្ច័យ ៤លៀងជីពជន្ម	បានបុណ្យយឺនយូរ សូរេចហោង ៕

និពន្ធ: **នឹម ណាំ**

ថាតាមសំដីម៉ាក់

ថ្ងៃមួយអ្នកស្រី**កាធឿង**ឡូឡាដាក់នាង**កាធូ**ជាកូន:

-ម៉េចក៏កូនឯងបណ្តែតបណ្តោយឲ្យខ្លួនមានផ្ទៃពោះអីចឹង? ម៉ាក់ប្រាប់ហើយប្រាប់ទៀត កុំឲ្យឆាប់ទន់ត្រចៀកដោយសារសំដីទឹកឃ្មុំរបស់បុរសៗពេក។ ជាមួយមនុស្សត្រូវកូនប្រកាន់ខ្ជាប់ពាក្យបដិសេធថា «**ទេ**» ។ ហេតុអីកូនមិនចាំសំដីម៉ាក់សោះ ?

- ចាស...កូនធ្វើតាមសំដីម៉ាក់បានយ៉ាងល្អហើយតើ! ពេលគាត់សួរបញ្ជាក់ខ្ញុំថា «**អូនបដិសេធន៍ទេ?**» ខ្ញុំនឹកឃើញសំដីម៉ាក់ប្រាប់ភ្លាម ទើបឆ្លើយភ្លែតថា ទេ អូនអត់បដិសេធទេ។ ព្រោះតែខ្ញុំធ្វើតាមសំដីម៉ាក់ទើបខ្ញុំមានផ្ទៃពោះហ្នឹងណា៎ ។

រាជើងបួនឬ?

យប់ជ្រៅបន្តិចហើយ នាយ**ភ្លាំង** ស្រវឹងខ្លាំងដើរទ្រេតទ្រោតចេញពីហាងស្រា សំដៅរថយន្តដែលចតនៅចិញ្ចើមផ្លូវ។ ទៅដល់បើកទ្វារចូលរថយន្តប្រុងបើកចេញ។ ឃើញដូច្នោះភ្នាក់ងារនគរបាលចរាចរណ៍ឈរក្បែរនោះស្រែកសួរ:

-ហ្ន៎លោក! លោកប្រុងបើកបរឡាន ទាំងកំពុងស្រវឹងអីចឹងឬ?

នាយ**ភ្លាំង**បើកភ្នែកព្រឹមៗតបទាំងកូរ:

- អ្ហេស... តើលោកនគរបាលចង់ឲ្យខ្ញុំធ្វើយ៉ាងម៉េច? ឃើញស្រាប់ហើយតើខ្ញុំដើរទ្រេតទ្រោតស្ទើរលើកជើង មិនរួចផងបើមិនឲ្យខ្ញុំបើកឡានទៅ លោកចង់ឲ្យខ្ញុំវារជើងបួនទៅមែនទេ ។

នៅតែជក់បារី

នាល្ងាចមួយ នាង**សយ** រអ៊ូជាក់នាយ**សាំ**ជាប្តី:

- បងអង្គុយមើលទូរទស្សន៍ ឮគេផ្សាយសឹងរាល់ថ្ងៃហើយតើថានៅអឺរ៉ុប មនុស្សស្លាប់រាប់លាននាក់ ដោយសារការជក់បារី ក្នុងមួយឆ្នាំៗ ហេតុអីបងនៅតែជក់ទៀត?

នាយ**សាំ** សើចញឹមៗឆ្លើយ:

- អេហ៍អូន**សយ** បងជាជនជាតិអាស៊ី មិនមែនអឺរ៉ុបឯណារឿងអីត្រូវស្លាប់ដោយសារការជក់បារីនោះ ។

តែមួយដងដែល

តា**ស្នាញ** និងតា**ស្នាន់** ជួបជជែកគ្នា:

ស្នាញ- មើលល្បងឯងកាលនៅក្មេងចូលចិត្តស្អីជាងគេ?

ស្នាន់- កាលនៅពីក្មេងពេញកម្លាំងខ្ញុំចូលចិត្តប្រមាញ់ និងស្រីស្អាត ។

ស្នាញ- តើល្បងចូលចិត្តប្រមាញ់ស្អីដែរ ?

ស្នាន- គឺប្រមាញ់ស្រីស្អាតហ្នឹងឯង ៕

បោះពុម្ពដោយ រោងពុម្ព **អរិយធម៌** ផ្ទះលេខ ៥២, ផ្លូវលេខ ៥៥៤, សង្កាត់បឹងកក់ II ខ័ណ្ឌទួលគោក-ភ្នំពេញ
H/P : 012 990 935 / Tel : 023 885 188 / Fax : 023 885 189 E-mail : ariyathoar@yahoo.com

អ្នកឧបត្ថម្ភ ទស្សនាវដ្តី ប្រជាជន លេខ ២៣១

១-	លោកជំទាវ	ម៉ែន	សំអន	សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានគណៈកម្មាធិការគណបក្សក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច	៤០០.០០០រ
២-	ឯ.ឧ	កែ	គឹមយ៉ាន	សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានក្រុមការងារចុះខេត្តបន្ទាយមានជ័យ	១០០ ដុល្លារ
៣-	លោកជំទាវ	ឃួន	សុដារី	សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល	២០០ ដុល្លារ
៤-	ឯ.ឧ	អូន	ព័ន្ធមុន្នីរ័ត្ន	សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានគណៈកម្មាធិការគណបក្សក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	២០០ ដុល្លារ
៥-	ឯ.ឧ	ជា	ចាន់តូ	សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានគណៈកម្មាធិការគណបក្សនៃធនាគារជាតិ	៤០០.០០០រ
៦-	ឯ.ឧ	អ៊ុក	រ៉ាប៊ុន	សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល ប្រធានគណៈកម្មាធិការគណបក្សក្រសួងអភិវឌ្ឍន៍ជនបទ	១០០ ដុល្លារ
៧-	ឯ.ឧ	ហ៊ីង	ប៊ុនហៀង	សមាជិកគណៈកម្មាធិការកណ្តាល ប្រធានគណៈកម្មាធិការគណបក្សខុទ្ទកាល័យសម្តេចតេជោ	២០០ ដុល្លារ
៨-	ឯ.ឧ	ស៊ុន	ចាន់ថុល	ប្រធានគណៈកម្មាធិការនៃគណបក្សក្រសួងសាធារណការនិងដឹកជញ្ជូន	៨០០.០០០ រ
៩-	ឯ.ឧ	ចម	ប្រសិទ្ធ	ប្រធានគណៈកម្មាធិការនៃគណបក្សក្រសួងឧស្សាហកម្ម និងសិប្បកម្ម	៤០០.០០០រ
១០-	ឯ.ឧ	ហ៊ុន	ណេង	ប្រធានគណៈកម្មការទី ៥ នៃរដ្ឋសភា	១០០ ដុល្លារ
១១-	ឯ.ឧ	វេង	សាខុន	ប្រធានគណៈកម្មាធិការនៃគណបក្សក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ	៦០០.០០០រ
១២-	ឯ.ឧ	ប៉ាន	សូរស័ក្តិ	ប្រធានគណៈកម្មាធិការនៃគណបក្សក្រសួងពាណិជ្ជកម្ម	១៥០ ដុល្លារ
១៣-	ឯ.ឧ	ថោង	ខុន	ប្រធានគណៈកម្មាធិការនៃគណបក្សក្រសួងទេសចរណ៍	១០០ ដុល្លារ
១៤-	ឯ.ឧ	អ៊ឹត	សំហេង	ប្រធានគណៈកម្មាធិការនៃគណបក្សក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	១០០ ដុល្លារ
១៥-	ឯ.ឧ	ព្រុំ	សុខា	ប្រធានគណៈកម្មាធិការនៃគណបក្សក្រសួងមុខងារសាធារណៈ	១០០ ដុល្លារ
១៦-	ឯ.ឧ	អ៊ូស្មាន	ហាស្សាន់	ប្រធានគណៈចលនាសាសនិកឥស្លាមនៃគណបក្សប្រជាជនកម្ពុជា	១០០ ដុល្លារ
១៧-	ឯ.ឧ	ជឹម	កេង	សមាជិកគណៈកម្មាធិការកណ្តាល	១០០ ដុល្លារ
១៨-	ឯ.ឧ	ឃុ	ប៊ុនឡេង	សមាជិកគណៈកម្មាធិការកណ្តាល	១០០ ដុល្លារ
១៩-	ឯ.ឧ	គង់	វិបុល	ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	១០០ ដុល្លារ
២០-	ឯ.ឧ	អ៊ុក	សារ៉ាតុង	ប្រធានគណៈកម្មាធិការនៃគណបក្សអាជ្ញាធរសៀនកម្មជាតិ	១០០ ដុល្លារ
២១-	ឯ.ឧ	ម៉ម	ប៊ុនឆាង	ប្រធានគណៈកម្មការទី ១០នៃព្រឹទ្ធសភា	១០០ ដុល្លារ
២២-	ឯ.ឧ	ឆង	វាសនា	អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ធំ	៤០០.០០០រ
២៣-	ឯ.ឧ	សុខ	ផល	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	១០០ ដុល្លារ
២៤-	ឯ.ឧ	ម៉ា	ឈឿន	សមាជិកគណៈកម្មាធិការកណ្តាល	១០០ ដុល្លារ
២៥-	លោកជំទាវ	អ៊ុក	ម៉ាលី	សមាជិកគណៈកម្មាធិការកណ្តាល	១០០ ដុល្លារ
២៦-	ឯ.ឧ	ឧេឍ	ឆន	រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	១០០ ដុល្លារ
២៧-	**គណៈកម្មការ ក៧១**				៤០០.០០០ រ
២៨-	**គណៈកម្មាធិការនៃគណបក្សក្រសួងបរិស្ថាន**				៤០០.០០០ រ
២៩-	**គណៈកម្មាធិការនៃគណបក្សក្រសួងកិច្ចការនារី**				១០០ ដុល្លារ
៣០-	**គណៈកម្មាធិការនៃគណបក្សខេត្តបាត់ដំបង**				១០០ ដុល្លារ
៣១-	**គណៈកម្មាធិការនៃគណបក្សខេត្តសៀមរាប**				១០០ ដុល្លារ
៣២-	**គណៈកម្មាធិការនៃគណបក្សខេត្តព្រះសីហនុ**				១០០ ដុល្លារ
៣៣-	**គណៈកម្មាធិការនៃគណបក្សខេត្តកំពង់ឆ្នាំង**				១០០ ដុល្លារ
៣៤-	**គណៈកម្មាធិការនៃគណបក្សខេត្តកណ្តាល**				១០០ ដុល្លារ
៣៥-	**គណៈកម្មាធិការនៃគណបក្សខេត្តស្ទឹងត្រែង**				១០០ ដុល្លារ
៣៦-	**គណៈកម្មាធិការនៃគណបក្សខេត្តកែប**				៤០០.០០០រ
៣៧-	ឯ.ឧ	ប៉ា	សុជាតិវង្ស	ប្រធានគណៈកម្មាធិការនៃគណបក្សរាជធានីភ្នំពេញ	១០០ ដុល្លារ
៣៨-	ឯ.ឧ	ម៉ែន	វិបុល	ប្រធានគណៈកម្មាធិការនៃគណបក្សខេត្តស្វាយរៀង	១០០ ដុល្លារ
៣៩-	ឯ.ឧ	ង៉ា	ថន	ប្រធានគណៈកម្មាធិការនៃគណបក្សខេត្តក្រចេះ	១០០ ដុល្លារ
៤០-	ឯ.ឧ	អ៊ូច	កា	ប្រធានគណៈកម្មាធិការនៃគណបក្សខេត្តតាកែវ	១០០ ដុល្លារ
៤១-	ឯ.ឧ	អ៊ុន	ចាន់ដា	ប្រធានគណៈកម្មាធិការនៃគណបក្សខេត្តកំពង់ចាម	១០០ ដុល្លារ
៤២-	ឯ.ឧ	ជាន់	ចាន់ថុល	ប្រធានគណៈកម្មាធិការនៃគណបក្សខេត្តប៉ៃលិន	១០០ ដុល្លារ
៤៣-	ឯ.ឧ	ស្វាយ	សំអ៊ាង	ប្រធានគណៈកម្មាធិការនៃគណបក្សខេត្តមណ្ឌលគិរី	១០០ ដុល្លារ
៤៤-	ឯ.ឧ	ប្រាក់	សុវណ្ណ	ប្រធានគណៈកម្មាធិការនៃគណបក្សខេត្តព្រះវិហារ	១០០ ដុល្លារ
៤៥-	ឯ.ឧ	ធឹម	សុផា	សមាជិកគណៈកម្មាធិការកណ្តាល	១០០ ដុល្លារ
៤៦-	ឯ.ឧ	ឃុ	ភិរម្យ	អនុប្រធានក្រុមការងាររបស់គណៈកម្មាធិការកណ្តាល ចុះជួយរាជធានីភ្នំពេញ	១០០ ដុល្លារ
៤៧-	ឯ.ឧ	ស្តើង	សុខុម	រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	៣០០.០០០រ
៤៨-	ឯ.ឧ	ម៉ូម	ជឹមហ៊ុយ	ប្រធានគណៈកម្មការទី៧នៃព្រឹទ្ធសភា	២០០.០០០ រ
៤៩-	ឯ.ឧ	ឈឹម	គានហោ	សមាជិកគណៈកម្មាធិការកណ្តាល និងជាប្រធានគណៈកម្មាធិការនៃគណបក្សក្រសួងធនធានទឹក និងឧតុនិយម	២០០.០០០ រ
៥០-	ឯ.ឧ	ម៉ម	ប៊ុនហេង	ប្រធានគណៈកម្មាធិការគណបក្សក្រសួងសុខាភិបាល	៥០ ដុល្លារ
៥១-	**គណៈកម្មាធិការនៃគណបក្សក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**				២០០.០០០ រ
៥២-	**គណៈកម្មាធិការនៃគណបក្សខេត្តបន្ទាយមានជ័យ**				៥០ ដុល្លារ
៥៣-	**គណៈកម្មាធិការនៃគណបក្សខេត្តកំពត**				៥០ ដុល្លារ
៥៤-	ឯ.ឧ	អាយ	ខន	សមាជិកព្រឹទ្ធសភា	៥០ ដុល្លារ
៥៥-	ឯ.ឧ	ជុំ	ឃុនឿន	អ្នកតំណាងរាស្ត្រមណ្ឌលកោះកុង	៥០ ដុល្លារ
៥៦-	លោក	អ៊ុក	ភ័ក្ត្រា	អភិបាលរងខេត្តកោះកុង	២០០.០០០រ
៥៧-	ឯ.ឧ	ជាម	ប៊េរ	អ្នកតំណាងរាស្ត្រមណ្ឌលខេត្តព្រៃវែង	២០០.០០០រ
៥៨-	ឯ.ឧ	អ៊ុក	ជាមរី	អ្នកតំណាងរាស្ត្រមណ្ឌលខេត្តកណ្តាល	២០០.០០០រ
៥៩-	ឯ.ឧ	ង៉ា	យ៉ាវ	អនុប្រធានគណៈកម្មាធិការគណបក្សធនាគារជាតិនៃកម្ពុជា	២៣៦.៤៧០រ
៦០-	ឯ.ឧ	ប៉ាវ	ហាមជាន	រដ្ឋលេខាធិការក្រសួងមហាផ្ទៃ	៥០ ដុល្លារ
៦១-	ឯ.ឧ	ម៉ៅ	ប៊ុនណារិន	សមាជិកគណៈកម្មាធិការកណ្តាល	២០០.០០០រ
៦២-	ឯ.ឧ	ចាយ	ចូរិន	អ្នកតំណាងរាស្ត្រមណ្ឌលកំពង់ចាម	៥០ ដុល្លារ
៦៣-	ឯ.ឧ	សួស	យ៉ារ៉ា	អ្នកតំណាងរាស្ត្រមណ្ឌលព្រះវិហារ	២០០.០០០រ
៦៤-	ឯ.ឧ	នរៈ	រតនៈវឌ្ឍនោ	រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា	២០០.០០០រ
៦៥-	ឯ.ឧ	ឃួន	ង៉ានីន	រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	៥០ ដុល្លារ
៦៦-	ឯ.ឧ	ហោ	សួ	រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	៥០ ដុល្លារ
៦៧-	លោកជំទាវ	មិថុនា	ភូថង	ប្រធានគណៈកម្មាធិការគណបក្សខេត្តកោះកុង	៥០ ដុល្លារ

អ្នកខ្វបត្តម្ត ចស្សនាវដ្តី ប្រជាជន លេខ ២៣១

៦៨-	ឯ.ឧ	**បូន**	**លឹមហេង**	អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	២០០.០០០៖
៦៩-	ឯ.ឧ	**សេង**	**ធ្វៀង**	អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី	២០០.០០០៖
៧០-	ឯ.ឧ	**ឆាយ**	**ឬទ្ធិសែន**	អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនគរូបនីយកម្ម និងសំណង់	២០០.០០០៖
៧១-	ឯ.ឧ	**ថោង**	**សអាត**	សមាជិកគណៈកម្មាធិការកណ្តាល	២០០.០០០៖
៧២-	ឯ.ឧបណ្ឌិត	**ហែម**	**ថេង**	អគ្គនាយករងនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍	២០០.០០០៖
៧៣-	ឯ.ឧ	**អ៊ិន**	**ឃូ៉ា**	អគ្គស្នងការរងនគរបាលជាតិ ទទួលផែននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌	២០០.០០០៖
៧៤-	ឯ.ឧ	**សុខ**	**ខេមរិន**	អនុប្រធានក្រមការងារចុះស្រកកញ្ជៀច និងប្រធានក្រមការងារចុះយុំកញ្ជៀច	២០០.០០០៖
៧៥-	ឯ.ឧ	**ខេ៉ង**	**ជូ**	ប្រធាននាយ់កដ្ឋាននគរបាល់ព្រហ្មទណ្ឌ ក្រសួងមហាផ្ទៃ	២០០.០០០៖
៧៦-	ឯ.ឧ	**យុន**	**ហេង**	ជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**	៥០ ដុល្លារ
៧៧-	ឯ.ឧ	**ឫទ្ស**	**សាម៉ុន**	រដ្ឋលេខាធិការក្រសួងផែនការ	១៥០.០០០ ៖
៧៨-	ឯ.ឧ	**ម៉ែន**	**ស៊ីផាន់**	សមាជិកព្រឹទ្ធសភា	១០០.០០០ ៖
៧៩-	**គណៈកម្មាធិការគណបក្ស ក២៥**				១០០.០០០ ៖
៨០-	**គណៈកម្មាធិការគណបក្ស ប្រជាជនក្រុងកោះរ៉ុង**				១០០.០០០ ៖
៨១-	**ក្រុមប្រឹក្សាខេត្ត បន្ទាយមានជ័យ**				១០០.០០០ ៖
៨២-	ឯ.ឧ	**ភាយ**	**សរួម**	ប្រធានគណៈប្រចាំការនៃគណៈអចិន្ត្រៃយ៍គណបក្សខេត្តកោះកុង	១០០.០០០ ៖
៨៣-	ឯ.ឧ	**ណៅ**	**ធួក**	រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	១០០.០០០ ៖
៨៤-	ឯ.ឧ	**ឫ៉ាន**	**ប៊ុនធឿន**	រដ្ឋលេខាធិការក្រសួងផែនការ	១០០.០០០ ៖
៨៥-	ឯ.ឧ	**ជ្រុន**	**ថេ៉ាឫ៉ាត**	អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ	១០០.០០០ ៖
៨៦-	ឯ.ឧ	**ប៉ែន**	**ប៉ន្ទសុខេមរា**	អគ្គាធិការ នៃអគ្គាធិការដ្ឋានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	១០០.០០០ ៖
៨៧-	ឯ.ឧ	**ស៊ឹម**	**ស៊ីថា**	អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ	១០០.០០០ ៖
៨៨-	លោក	**គឹម**	**ប៉ុណ្ណា**	សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការគណបក្សខេត្តសៀមរាបប្រធានសាខាគណបក្សមន្ទីរសាធារណការ និងដឹកជញ្ជូន	១០០.០០០ ៖
៨៩-	លោក	**ហូ**	**ជាវ៉ណា**	ប្រធានការិល័យរដ្ឋបាល នៃធនាគារជាតិ	១០០.០០០ ៖
៩០-	លោក	**ហ៊ុន**	**សុឫុឌ្ឍ**	មន្ត្រីគណៈយោសនាអប់រំនៃគណៈកម្មាធិការកណ្តាល	១០០.០០០ ៖
៩១-	លោក	**ភាត**	**ហ៊ុល**	អភិបាលក្រុងបៅយប៉ែតខេត្តបន្ទាយមានជ័យ	១០០.០០០ ៖
៩២-	ឯ.ឧ. ឧកញ៉ា	**សន**	**កុសល**	អនុប្រធាន់គណបក្សស្រកកំពង់សិលា	២០ ដុល្លារ
៩៣-	លោកជំទាវ	**មឹន**	**មាណាឫី**	រដ្ឋលេខាធិការក្រសួងស់ាធារណការ និងដឹកជញ្ជូន	៥០.០០០៖
៩៤-	ឯ.ឧ	**ពត**	**ចាន់នី**	អនុប្រធាននាយកដ្ឋានគ្រប់គ្រងអាវុធជាតិផ្ទុះ	៥០.០០០៖
៩៥-	ឯ.ឧ	**អ៊ុន**	**ឆាលី**	សមាជិកក្រមប្រឹក្សាខេត្តកោះកុង	៥០.០០០៖
៩៦-	ឯ.ឧ	**ស៊ុន**	**សុផល**	សមាជិកក្រ់មប្រឹក្សាខេត្តកោះកុង	៥០.០០០៖
៩៧-	ឯ.ឧ	**លី**	**សាវ៉េត**	សមាជិកក្រ់មប្រឹក្សាខេត្តកោះកុង	៥០.០០០៖
៩៨-	ឯ.ឧ	**ជួន**	**សាឡឿន**	សមាជិកក្រ់មប្រឹក្សាខេត្តកោះកុង	៥០.០០០៖
៩៩-	ឯ.ឧ	**ញ៉ែម**	**ជា៉ា**	សមាជិកក្រ់មប្រឹក្សាខេត្តកោះកុង	៥០.០០០៖
១០០-	លោកវេជ្ជបណ្ឌិត	**ផៅ**	**ម៉ឹន**	ប្រធានមន្ទីរសុខាភិបាលខេត្តកោះកុង	៥០.០០០៖
១០១-	លោក	**ជា**	**ឧត្តម**	អាជីវករ លក់ដូរ	៥០.០០០៖
១០២-	ឯ.ឧបណ្ឌិត	**ឧី**	**មានហេង**	ប្រធានគណៈកម្មាធិការគណបក្សមូលដ្ឋានមន្ទីរសុខាភិបាលរាជធានីភ្នំពេញ	៥០.០០០៖
១០៣-	ឯ.ឧ	**ហេង**	**ឫណ្ណា**	សមាជិកក្រមការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ	៥០.០០០៖
១០៤-	ឯ.ឧ	**ស៊ាង**	**ចាន់**	សមាជិកក្រ់មការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ	៥០.០០០៖
១០៥-	ឯ.ឧ	**ជា**	**ឫទ្ធី**	សមាជិកក្រ់មការងារគណៈកម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ	៥០.០០០៖
១០៦-	ឧកញ៉ា	**ឌេព**	**ឫសិដ្ឋ**	អនុប្រធាន់គណៈកម្មាធិការត្រតពិនិត្យ នៃគណៈកម្មាធិការគណបក្សខេត្តព្រះសីហនុ	៥០.០០០៖
១០៧-	លោក	**ឆេង**	**សុតក្រ**	សមាជិកក្រមការងារគណៈក៉ម្មាធិការកណ្តាលចុះជួយខេត្តព្រះសីហនុ	៥០.០០០៖
១០៨-	លោកជំទាវ	**នាក់**	**ណារិទ្ធ**	ប្រធានសា់ខាបក្សវិទ្យាស្ថានពហុបច្ចេកទេសខេត្ត	៥០.០០០៖
១០៩-	លោក	**គេង**	**នី**	នាយកវិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះសីហនុ	៥០.០០០៖
១១០-	លោក	**ឫទ្ស**	**ឌីណា**	ប្រធានសាខាពន្ធដារ ខេត្តកំពង់ឆ្នាំង	៥០.០០០៖
១១១-	លោកស្រី	**ស្រឿ**	**ប៉ន្ទថា**		៥០.០០០៖
១១២-	ឯ.ឧ	**លី**	**សារី**	អភិបាលរង ខេត្តបន្ទាយមានជ័យ	៥០.០០០៖
១១៣-	លោក	**គឹម**	**សុឫណ្ណ**	ប្រធានមន្ទីរសាធារណការ ខេត្តបន្ទាយមានជ័យ	៥០.០០០៖
១១៤-	ឯ.ឧ	**លឹម**	**សុថេត**	ប្រធានគណៈយោសនាអប់រំនៃគណបក្សខេត្តបន្ទាយមានជ័យ	៥០.០០០៖
១១៥-	ឯ.ឧ	**សួន**	**សុធី**	ប្រធានគណៈកម្មាធិការត្រតពិនិត្យនៃគណបក្សខេត្តបន្ទាយមានជ័យ	៥០.០០០៖
១១៦-	លោក	**ទូន**	**ណា៉ា**	ប្រធានសាលាដំបូងខេត្តប៉ន្ទាយមានជ័យ	៥០.០០០៖
១១៧-	លោក	**មាស**	**ប៉ន្ទពិសិដ្ឋ**	ព្រះរាជអាជ្ញារអមសាលាដំបូងខេត្តបន្ទាយមានជ័យ	៥០.០០០៖
១១៨-	ឯ.ឧ	**អ៊ុង**	**ស៊ីផាន**	ប្រធានអនុរក្សពន្ធនាគារខេត្តបន្ទាយមានជ័យ	៥០.០០០៖
១១៩-	លោក	**ប៉ឹង**	**គឹមសឹង**	ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តបន្ទាយមានជ័យ	៥០.០០០៖
១២០-	លោក	**ហ៊ុយ**	**ឌ្យៃង**	ប្រធានសភាពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ	៥០.០០០៖
១២១-	លោក	**អេង**	**ត្រឹន**	អាជីវករក្រុងបៅយប៉ែត ខេត្តបន្ទាយមានជ័យ	៥០.០០០៖
១២២-	លោក	**អ៊ុយ**	**ឆាយ**	អាជីវករក្រ់ងបៅយប៉ែត ខេត្តបន្ទាយមានជ័យ	៥០.០០០៖
១២៣-	លោក	**យឹម**	**ប៊ុនរ៉ុម**	ប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្តបន្ទាយមានជ័យ	៥០.០០០៖
១២៤-	លោក	**ឫ៉ាង**	**ឫណ្ណាសេដ្ឋ**	ប្រធានមន្ទីរកសិកម្មខេត្តបន្ទាយមានជ័យ	៥០.០០០៖
១២៥-	លោក	**យុត**	**ស៊ីន**	ប្រធានរតនាគារខេត្តបន្ទាយមានជ័យ	៥០.០០០៖
១២៦-	លោកស្រី	**ម៉េង**	**គឹមហួយ**	ប្រធានមន្ទីរកិច្ចការនារីខេត្តបន្ទាយមានជ័យ	៥០.០០០៖
១២៧-	លោក	**រស់**	**សារុំ**	ប្រធានមន្ទីរកិច្ចការ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តបន្ទាយមានជ័យ	៥០.០០០៖
១២៨-	លោក	**ប៊ុក**	**ឌ្យាយជី**	ប្រធានមន្ទីរពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ	៥០.០០០៖
១២៩-	លោក	**ញ៉ាល**	**ប៊ុនធឿន**	ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបន្ទាយមានជ័យ	៥០.០០០៖
១៣០-	លោក	**ថា**	**សុទ្ធា**	នាយកធនាគារជាតិ ខេត្តបន្ទាយមានជ័យ	៥០.០០០៖
១៣១-	លោក	**អាង**	**ណារឹទ្ធ**	ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសូរិយាដីខេត្តបន្ទាយមានជ័យ	៥០.០០០៖
១៣២-	លោក	**ជុំ**	**ឫណ្ណឌី**	អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ	៥០.០០០៖
១៣៣-	លោក	**ប៊ុន**	**លាងផេង**	អភិបាលរងស្រកព្រះនេត្រព្រះ	៥០.០០០៖
១៣៤-	លោក	**លី**	**ឫណ្ណារិទ្ធ**	អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តបន្ទាយមានជ័យ	៥០.០០០៖

អ្នកឲបត្តម្ភ ទស្សនាវដ្តី ប្រជាជន លេខ ២៣១

១៣៥	លោក	សិទ្ធ	ឡោះ	ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យ	៥០.០០០៤
១៣៦-	លោក	ជឹម	ប៊ុនអាន	មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តបន្ទាយមានជ័យ	៤០.០០០៤
១៣៧-	លោក	ហ្ឿន	ឌីរ:	អភិបាលរងក្រុងប៉ោលប៉ែតខេត្តបន្ទាយមានជ័យ	៤០.០០០៤
១៣៨-	ឯ.ឧ	សុវណ្ណ	សុតា	សមាជិកក្រម់ប្រឹក្សាខេត្តបន្ទាយមានជ័យ	៤០.០០០៤
១៣៩-	លោក	ជា	យុទ្ធារុណ	ប្រធានមន្ទីរអភិវឌ្ឍន៍ ជនបទខេត្តបន្ទាយមានជ័យ	៤០.០០០៤
១៤០-	លោក	លឹម	គឹមហ្ទរ	ប្រធានទីស្នាក់ការរដ្ឋសភាមណ្ឌលខេត្តបន្ទាយមានជ័យ	៤០.០០០៤
១៤១-	ឯ.ឧ	ថោ	ថេជ្ជា	រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម	៤០.០០០៤
១៤២-				**គណៈកម្មាធិការសាខាគណបក្សប្រជាជនកម្ពុជាប្រចាំគណៈកម្មាធិការសម្របសម្រួលខ្មែរកម្ពុជាក្រោម**	៤០.០០០៤
១៤៣-	លោក	សៅ	វណ្ឌឌីរ:	នាយករងខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងកិច្ចការនារី	៤០.០០០៤
១៤៤-	ឯ.ឧ	ស្ទិន	ឌុទ្ធី	រដ្ឋលេខាធិការប្រចាំការ ក្រសួងធនធានទឹក និងឧតុនិយម	៣០.០០០៤
១៤៥-	ឯ.ឧ	ប៊ី	ប្រេម	ប្រធានគណៈយោសនាអប់រំនៃគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ	៣០.០០០៤
១៤៦-	លោក	ម៉ៅ	សុខលីម	អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុក្រសួងសុខាភិបាល សមាជិកក្រុមការងារចុះជួយខណ្ឌសែនសុខ ភ្នំពេញ	៣០.០០០៤
១៤៧-	ឯ.ឧ	ប៉ុញ	សច្ច:	រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម	២០.០០០៤
១៤៨-	ឯ.ឧ	ចាន់	ស៊ីណាត	សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម	៣០.០០០៤
១៤៩-	ឯ.ឧ	ឈា	ប៊ុនរិទ្ធ	សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម	៣០.០០០៤
១៥០-	ឯ.ឧ	លឹម	ឌីរក្ស	សមាជិកគណៈកម្មាធិការគណបក្សក្រសួងធនធានទឹក និងឧតុនិយម	២០.០០០៤
១៥១-	ឯ.ឧ	ម៉ៅ	ហាក់	សមាជិកក្រុមការងារចុះខេត្តកណ្តាល	២០.០០០៤
១៥២-	លោកជំទាវ	ឈី	ឌ៉ា	សមាជិកក្រ់មប្រឹក្សាខេត្តកោះកុង	២០.០០០៤
១៥៣-	លោកជំទាវ	រស់	សុផានី	អភិបាលរង់ខេត្តបន្ទាយមានជ័យ	២០.០០០៤
១៥៤-	លោកជំទាវ	ប៉ុក	ណាឌី	អភិបាលរងខេត្តបន្ទាយមានជ័យ	២០.០០០៤
១៥៥-	ឯ.ឧ	សេក	សុខុម	ទីប្រឹក្សាក្រសួងពត៌មាន ចុះពង្រឹងមូលដ្ឋានខេត្តបន្ទាយមានជ័យ	២០.០០០៤
១៥៦-	លោក	អ៊ុត	សំអាន	អគ្គាធិការរងនៃអគ្គាធិការដ្ឋានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	២០.០០០៤
១៥៧-	លោក	ម៉ុ	ឌុទ្ធា	មន្ត្រីមន្ទីរគណបក្ស ខេត្តព្រៃវែង	២០.០០០៤
១៥៨-	លោក	ឃ្លោក	សំអាង	សមាជិកក្រុមការងារចុះខេត្តខេត្តកណ្តាល	២០.០០០៤
១៥៩-	លោក	ម៉ម	ម៉ាលី	អនុប្រធាន់គណៈយោសនាអប់រំគណៈកម្មាធិការគណបក្សរាជធានីភ្នំពេញ	២០.០០០៤
១៦០-	លោក	ឈាង	សុវណ្ណា៉ា	ប្រធានការិយាល័យរដ្ឋបាលក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជា ខេត្តព្រៃវែង	២០.០០០៤
១៦១-	លោក	ហ៊ាត	ឌ៉ាន់ធី	ប្រធានគណៈកម្មាធិការសាខា់គណបក្សផ្សារអូរឬស្សី (ភ្នំពេញ)	២០.០០០៤
១៦២-	លោក	ផូ	ឆា៉ា	ជំនួយការអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនចុះពង្រឹងមូលដ្ឋានខេត្តបន្ទាយមានជ័យ	២០.០០០៤
១៦៣-	លោក	គង់	ណាត្រី	មន្ត្រីអង្គការកិច្ចសហការដើម្បីកម្ពុជា (ក់ក្ទ) ខេត្តបន្ទាយមានជ័យ	២០.០០០៤
១៦៤-	លោក	ម៉ៅ	សូ	សមាជិកគណៈអចិន្ត្រៃយ៍គណបក្សខេត្តបន្ទាយមានជ័យ	២០.០០០៤
១៦៥-	លោក	ឃុន	ឌុទ្ធី	ប្រធានមន្ទីរសង្គមកិច្ចខេត្តបន្ទាយមានជ័យ	២០.០០០៤
១៦៦-	លោក	ឈ្ឿន	សេរីឌុធ	ប្រធានមន្ទីរទេសចរណ៍ខេត្តបន្ទាយមានជ័យ	២០.០០០៤
១៦៧-	លោក	ចាន់	ហេង	ម្ចាស់ស្ថានីយ៍ប្រេងឥន្ធន:គេលា ទីរូមខេត្តបន្ទាយមានជ័យ	២០.០០០៤
១៦៨-	លោក	ហុង	ប្រកប	អនុប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវ:ខេត្តបន្ទាយមានជ័យ	២០.០០០៤
១៦៩-	លោក	ឃូ	ពៅ	អភិបាលស្រកព្រះនេត្រព្រះខេ់ត្តបន្ទាយមានជ័យ	២០.០០០៤
១៧០-	លោក	យឹម	សំណាង	អភិបាលស្រ់កភ្នំស្រកខេត្តបន្ទាយមានជ័យ	២០.០០០៤
១៧១-	លោក	យ៉ង	តាំងកូយ	ប្រធានមន្ទីរវប្បធម៉ី និងវិចិត្រសិល្ប:ខេត្តបន្ទាយមានជ័យ	២០.០០០៤
១៧២-	លោក	ឈូន	ផាណា	ប្រធានការិយាល័យមធ្យមសិក្សានៃមន្ទីរអប់រំយុវជន និងកីឡាខេត្តបន្ទាយមានជ័យ	២០.០០០៤
១៧៣-	ឯ.ឧ	អោម	ហាក់	សមាជិកក្រុមប្រឹក្សា ខេត្តបន្ទាយមានជ័យ	១០.០០០៤
១៧៤-	លោកជំទាវ	តិន	ឌាឡ	សមាជិកក្រ់មប្រឹក្សា ខេត្តបន្ទាយមានជ័យ	១០.០០០៤
១៧៥-	លោក	ឈ្ឿន	ក្រៃយ៉ុង	នាយករដ្ឋបាល ខេត្តបន្ទាយមានជ័យ	១០.០០០៤
១៧៦-	លោក	យឹម	លឹ	ប្រធានមន្ទីរបរិស្ថាន ខេត្តបន្ទាយមានជ័យ	១០.០០០៤
១៧៧-	លោក	ឈុន	ប៊ុនឈ្ឿន	សមាជិកក្រុមការងារចុះខេត្តកណ្តាល	១០.០០០៤
១៧៨-	លោក	សុខ	ចំណាន	សមាជិកក្រ់មការងារចុះខេត្តកណ្តាល	១០.០០០៤
១៧៩-	លោក	ទូន	ពេជ្រ	សមាជិកគ់ណៈកម្មាធិការត្រួតពិនិត្យគណបក្សក្រសួងធនធានទឹក និងឧតុនិយម	១០.០០០៤
១៨០-	លោក	សែម	សំណាង	ប្រធាននាយកដ្ឋានទឹកស្អាត៉ និងអនាម័យ នៃក្រសួងធានធានទឹក និងឧតុនិយម	១០.០០០៤
១៨១-	លោក	ម៉ម	ប្រុស	ប្រធាននាយកដ្ឋានរដ្ឋបាល និងធនធានមនុស្សនៃក្រសួងធានធានទឹក និងឧតុនិយម	១០.០០០៤
១៨២-	លោក	ជូន	ឌណ្ណរិទ្ធ	សមាជិកក្រុមការងារចុះខេត្តកណ្តាល	១០.០០០៤
១៨៣-	លោក	ជា	ឌណ្ណ:	សមាជិកក្រ់មការងារចុះខេត្តកណ្តាល	១០.០០០៤
១៨៤-	លោក	សៅ	សម្ភារ	អនុប្រធាន់នាយកដ្ឋានរដ្ឋបាល និងធនធានមនុស្ស នៃក្រសួងធានធានទឹក និងឧតុនិយម	១០.០០០៤
១៨៥-	លោក	សៅ	សម្ធស្ស	អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធានធានទឹក និងឧតុនិយម	១០.០០០៤
១៨៦-	លោក	ថេង	ប៊ុនតេង	សមាជិកក្រុមការងារចុះខេត្តកណ្តាល	១០.០០០៤
១៨៧-	លោក	ស្ថាយ	សុគន្ធី	សមាជិកក្រ់មការងារចុះខេត្តកណ្តាល	១០.០០០៤
១៨៨-	លោក	ទិត	ចរិយា	ប្រធានការិយាល័យគណនេយ្យនាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងធានធានទឹក និងឧតុនិយម	១០.០០០៤
១៨៩-	លោក	សុខ	តារា	សមាជិកក្រុមការងារចុះខេត្តកណ្តាល	១០.០០០៤
១៩០-	លោក	សូ	ផល្លី	សមាជិកក្រ់មការងារចុះខេត្តកណ្តាល	១០.០០០៤
១៩១-	លោក	ហ្ទត	ឆាន	សមាជិកក្រ់មការងារចុះខេត្តកណ្តាល	១០.០០០៤
១៩២-	លោក	ទីម	ឌុជ្ជារី	សមាជិកក្រ់មការងារចុះខេត្តកណ្តាល	១០.០០០៤
១៩៣-	លោក	ណុប	រៀមណី	សមាជិកក្រ់មការងារចុះខេត្តកណ្តាល	១០.០០០៤
១៩៤-	លោក	សារុន	សម្បត្តិ	សមាជិកក្រ់មការងារចុះខេត្តកណ្តាល	១០.០០០៤
១៩៥-	លោក	ទូច	សុផល្លា	សមាជិកក្រ់មការងារចុះខេត្តកណ្តាល	១០.០០០៤
១៩៦-	លោក	ជុ	ឧត្តរា	សមាជិកក្រ់មការងារចុះខេត្តកណ្តាល	១០.០០០៤
១៩៧-	លោក	ឈ្លាង	ប៊ុយ	សមាជិកក្រ់មការងារចុះខេត្តកណ្តាល	១០.០០០៤
១៩៨-	លោក	កេត	ចាន់សាឌុធ	សមាជិកក្រ់មការងារចុះខេត្តកណ្តាល	១០.០០០៤
១៩៩-	លោក	ជីឌ	ស៊ុនហេង	សមាជិកក្រ់មការងារចុះខេត្តកណ្តាល	១០.០០០៤
២០០-	លោក	យស់	ឆុល	សមាជិកក្រ់មការងារចុះស្រកពោធិរៀង ខេត្តព្រៃវែង	១០.០០០៤
២០១-	លោក	ឌ្បាច	តឺ៉ាត់	សមាជិកក្រ់មការងារចុះស្រ់កបាភ្នំ ខេត្តព្រៃវែង	១០.០០០៤

ប្រជាជនធើរកំសាន្តនៅតំបន់ទេសចរណ៍នានានៅក្នុងប្រទេស

ចែកជូនដោយឥតគិតថ្លៃ